# ការសិក្សាស៊ីជម្រៅអំពី សេរីភាព សាសនា និងជំនឿ

## ស្វែងយល់ពីឧបសគ្គ និងក្តីសង្ឃឹមរបស់សហគមន៍



មិថុនា ២០២៤

# ការសិក្សាស៊ីជម្រៅអំពីសេរីភាពសាសនា និងជំនឿ៖ ស្វែងយល់ពីឧបសគ្គ និងក្តីសង្ឃឹមរបស់សហគមន៍

របាយការណ៍នៃការស្រាវជ្រាវតាមបែបចូលរួមរបស់អង្គការនារីដើម្បីសន្តិភាព
ក្រោមកិច្ចសហការជាដៃគូជាមួយ អង្គការស្ពានសន្តិភាព អង្គការបន្តការអប់រំ
និង អង្គការដានមីសិនប្រចាំប្រទេសកម្ពុជា


**ក្រុមស្រាវជ្រាវអង្គការនារីដើម្បីសន្តិភាព**

គ្រី ស៊ុយហៀង | លី រតនៈ | យឿម យ៉េត | ស៊ឹម សុម្ពីរក្ស | ភួង សុធីនី

**អ្នកស្រាវជ្រាវសហគមន៍៖**

ជា សំណាង
ឈឹម សុខា
ហារ ស្រីម៉ាក់
ហ៊ាន សុចាបញ្ញពណ៌
ខេង ខូ
ឃិន ម៉ី
គង់ សុខា
អ៊ូច រដ្ឋា
ប្លង់ សំរិទ្ធ
សែម សាងហ៊ាន់
ស៊ូហ្វីយ៉ាន តូយ៉េប
យ៉េម យាត

**អ្នកនិពន្ធ៖**

Rev. SP Bhagwat (Raju) និង លី រតនៈ

**ពិនិត្យ និងកែសម្រួលដោយ៖**

Laura Rickard និង Joseph Mayer

**រចនាក្របមុខ និងទំព័រដោយ៖**

Malia Imayama



**បោះពុម្ពផ្សាយលើកទី១ ក្នុងប្រទេសកម្ពុជា ឆ្នាំ២០២៤**
**ដោយអង្គការនារីដើម្បីសន្តិភាព**
www.wpmcambodia.org



**© អង្គការនារីដើម្បីសន្តិភាព ២០២៤**



**រាជធានីភ្នំពេញ**

ទស្សនៈបង្ហាញក្នុងរបាយការណ៍នេះទទួលបានផ្ទាល់ពីអ្នកចូលរួមស្រាវជ្រាវដែលបានចែករំលែកទស្សនៈខ្លួន ពីអ្នកអនុវត្តស្រាវជ្រាវដែលបានឆ្លុះបញ្ចាំងលើរបកគំហើញ និងពីអ្នកនិពន្ធដែលយកមកបកស្រាយជាទម្រង់សំណេរ។ ទស្សនៈទាំងនេះពុំបានឆ្លុះបញ្ចាំងពីជំហររបស់អង្គការនារីដើម្បីសន្តិភាព ឬអង្គការ ឬដៃគូណាមួយដែលពាក់ព័ន្ធនឹងការអនុវត្ត ឬការបោះពុម្ពផ្សាយការងារនេះទេ។ អ្នកចូលរួមផ្តល់ព័ត៌មានទាំងអស់បានយល់ព្រមក្នុងលិខិតយល់ព្រមជាមុន ហើយពួកគេបានដឹងច្បាស់ពីវិសាលភាពគម្រោង និងផែនការបោះពុម្ពផ្សាយព័ត៌មានដែលខ្លួនបានផ្តល់។

ឈ្មោះ និងព័ត៌មានលម្អិតអំពីអត្តសញ្ញាណមួយចំនួនត្រូវបានប្តូរដើម្បីរក្សាឯកជនភាពរបស់បុគ្គល។

យើងសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមផ្តល់ព័ត៌មានតាមសហគមន៍នីមួយៗ និងអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ។ យើងក៏សូមថ្លែងអំណរគុណដល់អង្គការសង្គមស៊ីវិលដៃគូ ដូចជា អង្គការដានមីសិនប្រចាំប្រទេសកម្ពុជា អង្គការស្ពានសន្តិភាព និងអង្គការបន្ទការអប់រំ ដែលបានណែនាំ សហការ និងផ្តល់ព័ត៌មានធាតុចូលក្នុងការអភិវឌ្ឍ និងការអនុវត្តការស្រាវជ្រាវនេះ។ យើងសូមថ្លែងអំណរគុណជាពិសេសដល់សមាជិកសហគមន៍ អ្នកស្ម័គ្រចិត្ត និងអ្នកគាំទ្រគំនិតផ្តួចផ្តើមនេះទាំងអស់ដែលបានរួមចំណែកធ្វើឱ្យការសិក្សានេះប្រព្រឹត្តទៅដោយរលូន។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកស្រាវជ្រាវសហគមន៍ទាំងអស់ដែលជួយសហការដឹកនាំ សហការរចនា និងសហការអនុវត្តការសិក្សានេះប្រកបដោយការជំរុញចិត្ត និងការតាំងចិត្ត ដែលជាកត្តាចម្រើនដល់ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមទាំងមូល។

ការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រសប្បុរសពី

Center for Church-Based Development ហៅកាត់ថា CKU។

CKU

Center for Kirkeligt Udviklingssamarbejde

SAMMEN SKABER VI HÅB

# មាតិកា


**មូលន័យសង្ខេប** ........................................................................1

**១**.សេចក្ដីផ្ដើម .........................................................................6

**១.១**.បរិបទសាសនាក្នុងប្រទេសកម្ពុជា .......................................8

**១.២**.ទិដ្ឋភាពច្បាប់ទាក់ទងនឹង ស.ស.ជ ..................................... 10

**២**.រំលឹកទ្រឹស្ដីពាក់ព័ន្ធសេរីភាពសាសនា ឬជំនឿនៅកម្ពុជា...........................14

**៣**.វិធីសាស្ត្រស្រាវជ្រាវ ..............................................................34

**៣.១**.បញ្ហាស្រាវជ្រាវ និងកម្មវត្ថុ.....................................................36

**៣.២**.ការរចនាការស្រាវជ្រាវ ........................................................39

**៣.៣**.ដែនកំណត់ក្នុងការស្រាវជ្រាវ ................................................45

**៣.៤**.ការពិចារណាអំពីក្រមសីលធម៌នៅក្នុងការចុះស្រាវជ្រាវក្នុងសហគមន៍ ..... 47

**៤**.ការវិភាគទិន្នន័យ.....................................................................52

**៤.១**.ទិន្នន័យប្រជាសាស្ត្រ ..........................................................53

**៤.២**.ភាពលម្អៀងនៃសំណាកគំរូប្រជាសាស្ត្រ.......................................55

**៥**.របកគំហើញនៃការស្រាវជ្រាវ........................................................59
**៥.១**.បទបញ្ញត្តិ និងការអនុវត្តច្បាប់ ស.ស.ជ នៅមូលដ្ឋាន ..........................61
**៥.២**.ស្ថានភាព ស.ស.ជ ក្នុងសហគមន៍សាសនា/ជំនឿផ្សេងៗគ្នា...............68
**៥.៣**.ស្ថានភាព ស.ស.ជ នៅក្នុងសហគមន៍សាសនា/ជំនឿផ្ទាល់ខ្លួន...........79
**៥.៤**.ទំនាក់ទំនងអន្តរជំនឿ ..........................................................92
**៥.៥**.សារៈសំខាន់នៃការផ្សព្វផ្សាយ ស.ស.ជ....................................... 102

**៦**.អនុសាសន៍..................................................................... 116
**៦.១**. គោលការណ៍គ្រឹះនៃយុទ្ធសាស្ត្រសម្រាប់ ស.ស.ជ ........................... 117
**៦.២**. អនុសាសន៍សម្រាប់សកម្មភាព...............................................122

**សេចក្ដីសន្និដ្ឋាន** ........................................................... 129

**គន្ថនិទ្ទេស** ..................................................................133

# មូលន័យសង្ខេប

របាយការណ៍ក្រោមចំណងជើងថា “ការសិក្សាស៊ីជម្រៅអំពីសេរីភាពសាសនា និងជំនឿ៖ ស្វែងយល់ពីឧបសគ្គ និងក្ដីសង្ឃឹមរបស់សហគមន៍” បង្ហាញពីការវិភាគសព្វជ្រុងជ្រោយទៅលើស្ថានភាពសេរីភាពសាសនា និងជំនឿ (ស.ស.ជ) នៅកម្ពុជា ដោយផ្ដោតលើបរិបទប្រវត្តិសាស្ត្រ បទប្បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ ស្ថានភាពនិងបញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ន និងចំណុចពាក់ព័ន្ធនានានៃ ស.ស.ជ នៅតាមក្រុមសាសនាចម្រុះ។ ទោះបីជាមានការធានាពីរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិពីកម្ពុជាក៏ដោយ ក៏បញ្ហាប្រឈមគួរឱ្យកត់សម្គាល់នានានៅបន្តកើតមានជាពិសេសទៅលើក្រុមសាសនាភាគតិច។ ការស្រាវជ្រាវនេះស្វែងរកមើលថាការគាំទ្រផ្លូវច្បាប់មានការសម្របសម្រួល និងមានការរារាំងបែបណាដល់សេរីភាពសាសនានិងជំនឿនៅក្នុងសហគមន៍។ ការស្រាវជ្រាវនេះពិនិត្យមើលថាតើក្របខ័ណ្ឌច្បាប់ត្រូវបានអនុវត្តបែបណានៅថ្នាក់មូលដ្ឋាន ដោយផ្ដោតលើទាំងទំនាក់ទំនងអន្តរសាសនា និងទំនាក់ទំនងនៅក្នុងសហគមន៍សាសនានីមួយៗទាក់ទងនឹងសេរីភាពសាសនា និងជំនឿ។

ប្រជាជនកម្ពុជាភាគច្រើនលើសលុបជាពុទ្ធសាសនិក ដោយប្រមាណ៩៥%កាន់ព្រះពុទ្ធសាសនាថេរវាទ។ ក្រៅពីនោះ ក្នុងចំណោម៥%ទៀត គឺសាសនានិងជំនឿភាគតិចរួមមានសាសនាឥស្លាម គ្រិស្ដសាសនា ជំនឿបាហៃ និងការប្រតិបត្តិរបស់ជនជាតិដើមភាគតិច។ ក្នុងប្រវត្តិសាស្ត្រ វត្តមានសាសនាទាំងនេះបានជួបប្រទះនូវការបង្ក្រាប ជាពិសេសក្នុងរបបខ្មែរក្រហម។ ទោះមានការធានាការពារពីរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ សេរីភាពសាសនាជារឿយៗជួបការប្រឈមនៅក្នុងការអនុវត្តជាក់ស្ដែង ជាពិសេសសម្រាប់ក្រុមសាសនានិងជំនឿភាគតិច។

ដោយមានការគាំទ្រដោយរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិមួយចំនួនដូចជា ICCPR, ICESCR, CEDAW, CRC, ICERD និង CAT ក្របខ័ណ្ឌច្បាប់នៅកម្ពុជាធានាការពារសេរីភាពសាសនា និងជំនឿតាមរយៈទ្រឹស្តី។ ដោយឡែកការអនុវត្តជាក់ស្តែង បានបង្ហាញថានៅមានវិសមភាពគួរឱ្យកត់សម្គាល់មួយចំនួន។ សាសនាភាគតិច ជាពិសេសគ្រិស្តសាសនិក និងសាសនិកឥស្លាម បានបង្ហាញថាមានបទពិសោធន៍ទទួលរងការរើសអើង ការឃាំឃី និងការដាក់កម្រិតលើសកម្មភាពសាសនា។ រដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដល់ព្រះពុទ្ធសាសនាថេរវាទ ដែលដាក់កំហិតដោយប្រយោលលើសិទ្ធិរបស់ក្រុមសាសនាដទៃទៀត ជាហេតុបង្កទៅជាបរិយាកាសមួយដែលសេរីភាពសាសនា និងជំនឿ មិនមានលក្ខណៈពេញលេញសម្រាប់ប្រជាពលរដ្ឋទាំងអស់ឡើយ។

ការរំលឹកទ្រឹស្តី បានរំលេចនូវបញ្ហាមួយចំនួនដូចជា ការហាមប្រាមការបង្រៀនអំពីសាសនាផ្សេងពីពុទ្ធសាសនានៅសាលារដ្ឋ ការរឹតបន្តឹងលើការផ្សព្វផ្សាយសាសនា និងបញ្ហាប្រឈមនានាដែលក្រុមសាសនាភាគតិចជួបប្រទះក្នុងការប្រតិបត្តិជំនឿរបស់ខ្លួនដោយបើកចំហ។ គោលការណ៍ទាំងនេះ ពង្រឹងឥទ្ធិពលព្រះពុទ្ធសាសនា និងដាក់កំហិតលើការអប់រំសាសនា និងសិទ្ធិរបស់សិស្សមកពីក្រុមសាសនាភាគតិច។ ជាងនេះទៅទៀត ការបំផ្លិចបំផ្លាញទីកន្លែងពិសិដ្ឋ និងការឈូសឆាយដីពីសំណាក់បុគ្គល និងក្រុមហ៊ុនមានអំណាច ធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិចជួបការលំបាកក្នុងការប្រតិបត្តិជំនឿប្រពៃណីរបស់ខ្លួន។

បើពិនិត្យមើលចំណុចប្រសព្វគ្នានៃសិទ្ធិយេនឌ័រ និងសេរីភាពសាសនា និងជំនឿ ឃើញថាមានបញ្ហាប្រឈមជាច្រើន។ ជារឿយៗ ជំនឿបែបប្រពៃណី និងសាសនាបង្កឱ្យមានវិសមភាពយេនឌ័រ ហើយវិសមភាពនេះហើយជាអ្នកដាក់កំហិតលើការចូលរួមរបស់

ស្ត្រីក្នុងផ្លូវសាសនា និងជីវិតសាធារណៈ។ ស្ត្រីមកពីក្រុមសាសនាភាគតិចប្រឈមនឹងការរើសអើងផ្ទួនគ្នា ដោយកត្តាយេនឌ័រ និងអត្តសញ្ញាណសាសនាខ្លួន។ ជាក់ស្តែង កង្វះការព្រមបំបួសស្ត្រីក្នុងពុទ្ធសាសនាដាក់កំហិតខ្លាំងដល់សិទ្ធិអំណាចសាសនារបស់ស្ត្រី និងបង្កើនវិសមភាពយេនឌ័រក្នុងសង្គមកាន់តែខ្លាំង។

តាមលទ្ធផលស្រាវជ្រាវពីការធ្វើសម្ភាសផ្ទាល់ជាមួយអាជ្ញាធរខេត្ត អ្នកដឹកនាំសាសនា និងការស្ទង់មតិពីសហគមន៍ បានបង្ហាញថា រដ្ឋធម្មនុញ្ញទទួលស្គាល់ និងធានាការពារសេរីភាពសាសនា និងជំនឿ។ ទោះជាយ៉ាងណាក៏ដោយ របកគំហើញទាំងនេះក៏បង្ហាញពីគម្លាតនៅក្នុងការអនុវត្តជាក់ស្តែង។ គេនៅសង្កេតឃើញមានភាពមិនស៊ីសង្វាក់គ្នា នៅពេលចុះឈ្មោះ និងសាងសង់ទីសាសនា ការលើកកម្ពស់ជំនឿសាសនា និងការចូលរួមរបស់មេដឹកនាំសាសនាក្នុងដំណើរការសម្រេចចិត្ត។ លើសពីនេះ បញ្ហានានាពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជំនឿ ដូចជាកង្វះការយល់ដឹង និងការប្រាស្រ័យទាក់ទងគ្នារវាងក្រុមសាសនាផ្សេងៗគ្នា បង្ហាញឱ្យឃើញថាត្រូវការមានការធ្វើសន្ទនា និងការអប់រំអន្តរជំនឿ ដើម្បីលើកកម្ពស់ការគោរពគ្នាទៅវិញទៅមក និងភាពសុខដុមរមនា។

បញ្ហាប្រឈមធំៗឃើញមានទាក់ទងនឹងផលប៉ះពាល់នៃការប្រតិបត្តិសាសនា និងជំនឿរបស់សហគមន៍ និងក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី បុគ្គលស្រលាញ់ភេទដូចគ្នា និងជនជាតិដើមភាគតិច។ ជារឿយៗ ស្ត្រីប្រឈមនឹងការរឹតបន្តឹងតួនាទីដឹកនាំសាសនា និងទទួលបានការកំណត់ឱ្យមិនស្មើភាពគ្នាក្នុងគោលការណ៍ចែកមរតកផ្អែកទៅលើអត្តសញ្ញាណភេទ។ បុគ្គលស្រលាញ់ភេទដូចគ្នាខ្វះការទទួលស្គាល់ និងរងការរើសអើងជាញឹកញាប់។ សហគមន៍ជនជាតិដើមភាគតិចប្រឈមជាមួយការបាត់បង់ទីកន្លែងសក្ការៈ ដោយសារគម្រោងអភិវឌ្ឍន៍ និងការជ្រៀតជ្រែកពីខាងក្រៅ ដែលប៉ះពាល់ដល់ការប្រតិបត្តិខាងព្រលឹងវិញ្ញាណ និងវប្បធម៌របស់ខ្លួន។

អ្នកដឹកនាំសាសនាដើរតួនាទីសំខាន់ក្នុងការជំរុញការយល់ដឹងពីអន្តរជំនឿ ការលើកកម្ពស់ការគោរពគ្នាទៅវិញទៅមក និងការដោះស្រាយវិវាទនៅក្នុងសហគមន៍របស់ពួកគេ។ កិច្ចខិតខំរបស់ពួកគេមានសារៈសំខាន់ណាស់ដើម្បីពង្រឹងភាព ចុះសម្រុងគ្នា និងសុខដុមរមនាក្នុងសហគមន៍ ដែលរួមចំណែកដល់សង្គមមួយប្រកបដោយបរិយាបន្ន និងកាន់តែមានការយោគយល់គ្នា។ ទោះមានការ ខិតខំប្រឹងប្រែងទាំងនេះក្តី ក៏បញ្ហានៅតែបន្តកើតមាន ដូចជាការបំផ្លិចបំផ្លាញទីកន្លែងសក្ការៈ ការកម្រិតការអប់រំសាសនា និងការរើសអើងក្រុមងាយរងគ្រោះ។ នេះសឱ្យឃើញថាត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីគាំទ្រអ្នកដឹកនាំសាសនាក្នុងការការពារ និងលើកកម្ពស់សេរីភាពសាសនាសម្រាប់បុគ្គលគ្រប់រូប។

ដើម្បីបង្កើនការការពារ និងលើកកម្ពស់សេរីភាពសាសនា និងជំនឿ ( ស.ស.ជ ) នៅកម្ពុជា គប្បីពិចារណាអនុសាសន៍ខ្លះៗដូចខាងក្រោម៖

1. អនុវត្តកំណែទម្រង់ច្បាប់ដើម្បីធានាការប្រព្រឹត្តស្មើភាពមកលើគ្រប់ក្រុមសាសនា។
2. កែលម្អការចែករំលែកព័ត៌មាន និងធានាការអនុវត្តជាប់លាប់នូវសិទ្ធិ ស.ស.ជ។
3. ដោះស្រាយការរើសអើងយេនឌ័រ និងអ្នកស្រលាញ់ភេទដូចគ្នា នៅក្នុងបរិបទសាសនា។
4. ជំរុញកិច្ចសន្ទនា និងការអប់រំអន្តរជំនឿ។
5. ការពារកន្លែងសក្ការៈរបស់ជនជាតិដើមភាគតិច។
6. ជំរុញការចូលរួមសកម្មភាពរបស់ស្ត្រី និងក្រុមភាគតិចក្នុងផ្លូវសាសនា និងជាសាធារណៈ។

ជំហានទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើតសង្គមប្រកបដោយបរិយាបន្ន និងសមធម៌ ដើម្បីឱ្យបុគ្គលទាំងអស់អាចប្រតិបត្តិជំនឿរបស់ខ្លួនដោយសេរី។

សរុបមក ខណៈពេលដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជាមានការគាំទ្រជាទ្រឹស្តីលើសេរីភាពខាងសាសនានិងជំនឿ ការអនុវត្តជាក់ស្តែងនៅតែមានបញ្ហាប្រឈមផ្សេងៗ។ ការដោះស្រាយបញ្ហាទាំងនេះ តម្រូវឱ្យមានវិធីសាស្រ្តចម្រុះនិងបែបពហុវិស័យ ដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ ការអប់រំសង្គម និងការលើកកម្ពស់សិទ្ធិមនុស្សជាសកលមួយឱ្យមានប្រសិទ្ធភាពខ្ពស់។ តាមរយៈការជំរុញឲ្យមានការគោរព និងការយោគយល់គ្នាទៅវិញទៅមក ការលើកកម្ពស់ការប្រតិបត្តិសាសនាប្រកបដោយបរិយាបន្ន និងការការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ ប្រទេសកម្ពុជាអាចក្លាយជាសង្គមមួយដែលមានសុខដុមរមនា និងមានភាពធន់ថែមទៀត ដោយចេះសាទរភាពចម្រុះនៃសាសនានិងជំនឿ។



# ១.

# សេចក្តីផ្តើម

*“សេរីភាពសាសនា និងជំនឿ”* នៅក្នុងប្រទេសកម្ពុជា មានការប្រែប្រួលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ រដ្ឋធម្មនុញ្ញកម្ពុជាធានានូវសេរីភាពខាងសាសនានិងជំនឿ ប៉ុន្តែ នៅក្នុងរបត់ប្រវត្តិសាស្ត្រ យើងធ្លាប់ជួបបទពិសោធន៍នៃការរគាបសង្កត់ផ្នែកសាសនាជាពិសេសក្នុងរបបខ្មែរក្រហម។ ក្រោយពីរបបខ្មែរក្រហមបានដួលរលំប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិ សេរីភាពសាសនា និងជំនឿ ប៉ុន្តែ បញ្ហាប្រឈមនៅតែមាន ដោយសារផ្នត់គំនិតសង្គម ឥទ្ធិពលនយោបាយ និងបញ្ហាប្រឈមនានាលើក្រុមសាសនានិងជំនឿភាគតិច។

ប្រវត្តិសាស្ត្រប្រទេសកម្ពុជាត្រូវបានកត់សម្គាល់តាមរយៈការប្រតិបត្តិសាសនាចម្រុះ។ ការការពារសេរីភាពសាសនា ទោះបីជាមានចែងក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏មានប្រឈមនឹងបញ្ហាជាច្រើនក្នុងប្រវត្តិសាស្ត្រជាតិ។ ការសិក្សាស្រាវជ្រាវនេះពិនិត្យមើលបរិបទប្រវត្តិសាស្ត្រ ការការពារផ្លូវច្បាប់ ការប្រឈមក្នុងពេលបច្ចុប្បន្ន និងផលប៉ះពាល់ទៅលើសេរីភាពសាសនានិងជំនឿនៅក្នុងបរិបទកម្ពុជា ដែលចម្រុះទៅដោយសាសនា និងជំនឿផ្សេងៗគ្នា។

# ១.១. បរិបទសាសនាក្នុងប្រទេសកម្ពុជា

ប្រជាជនកម្ពុជាប្រមាណ៩៥%ជាពុទ្ធសាសនិក ភាគច្រើនកាន់ព្រះពុទ្ធសាសនាថេរវាទ។ ទីវត្តអារាមមានប្រមាណ៤៤០០កន្លែង នៅទូទាំងប្រទេស។ ប្រជាជននៅសល់៥% ជាអ្នកកាន់សាសនាឥស្លាម គ្រិស្តសាសនា ជំនឿព្រលឹងវិញ្ញាណរបស់ជនជាតិដើមភាគតិច ជំនឿបាហៃ ជំនឿជនជាតិជ្វីហ្វ និងសាសនាការដាយ។

ទិដ្ឋភាពសាសនានៅប្រទេសកម្ពុជាបានរងឥទ្ធិពលខ្លាំងពីពុទ្ធសាសនាថេរវាទដែលជាសាសនារបស់រដ្ឋតាំងពីសតវត្សទី១៣ (លើកលែងតែក្នុងសម័យខ្មែរក្រហម)។ ប្រជាជនប្រហែល៩៥%ប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់នេះ ដោយចាក់ឫសគល់តាំងពីសតវត្សទី៥ នៃគ.ស។ ទម្រង់ដើមនៃពុទ្ធសាសនាមហាយានក៏មាននៅក្នុងប្រទេសកម្ពុជាផងដែរ ដែលគេឃើញចូលមកតាមរយៈចរន្តផ្សេងៗ ដូចជាឥទ្ធិពលនគរមនក្នុងសម័យអាណាចក្រអង្គរ។

ក្នុងប្រវត្តិសាស្ត្រ សាសនាឥស្លាមមានវត្តមាននៅក្នុងប្រទេសកម្ពុជា តាមការនាំចូលមកពីពាណិជ្ជករឥស្លាមនៅខ្ទង់សតវត្សទី១២ដល់១៧។ សាសនានេះត្រូវបានផ្សាយបន្តដោយជនជាតិចាម ហើយសព្វថ្ងៃនេះ អ្នកកាន់សាសនាឥស្លាមមានប្រហែល៣%ក្នុងចំណោមប្រជាជនសរុប។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួនវិហារឥស្លាមបានកើនឡើងយ៉ាងឆាប់រហ័ស។

នៅក្នុងប្រទេសកម្ពុជា គ្រិស្តសាសនាពុំសូវមានឥទ្ធិពលជាលក្ខណៈប្រវត្តិសាស្ត្រឡើយ។ បេសកកម្មគ្រិស្តសាសនិកកាតូលិកដំបូងឃើញកើតមានចន្លោះឆ្នាំ១៥៥៥ និង១៥៥៦ ប៉ុន្តែឥទ្ធិពលសាសនានៅមានតិចតួចរហូតដល់ចុងសតវត្សទី១៩។ សព្វថ្ងៃនេះ គ្រិស្តសាសនិក

មានត្រឹមតែ២% ក្នុងចំណោមប្រជាជនប៉ុណ្ណោះ ក្នុងនោះច្រើនឃើញមាននិកាយកាតូលិក និងនិកាយប្រូតេស្តង់ចំនួន២១ផ្សេងទៀតដែលលេចធ្លោ។ សាសនាចក្រព្រះយេស៊ូគ្រិស្តនៃក្រុមបរិសុទ្ធថ្ងៃចុងក្រោយ និងទីបន្ទាល់ព្រះយេហូវ៉ា ក៏មានវត្តមាននៅប្រទេសកម្ពុជាចាប់តាំងពីចុងសតវត្សទី២០ មកផងដែរ។

ជំនឿបាហៃបានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩២០ ហើយបានប្រឈមនឹងបញ្ហានានា ជាពិសេសក្នុងសម័យខ្មែរក្រហម។ ទោះជាយ៉ាងណាក៏ដោយ ប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញជំនឿនេះលេចឡើងវិញ ក្នុងនោះមានកំណើនច្រើននៅតាមតំបន់ក្រុង ដូចជានៅបាត់ដំបងជាដើម។ ក្នុងឆ្នាំ២០១៧ ទីសក្ការបូជាបាហៃដំបូងគេបង្អស់ត្រូវបានសង់បញ្ចប់នៅខេត្តបាត់ដំបង។

ជំនឿជនជាតិដើមភាគតិចក៏មានវត្តមាននៅតាមក្រុមរស់នៅតំបន់ខ្ពង់រាបផងដែរ ដែលអាចសម្គាល់បានតាមរយៈប្រព័ន្ធសាសនាតាមមូលដ្ឋាន និងការអនុវត្តបែបព្រលឹងវិញ្ញាណ។ ក្រុមទាំងនេះគេច្រើនហៅថាខ្មែរលើ ហើយពួកគេជឿថាពិភពលោកនេះពោរពេញដោយវិញ្ញាណផ្សេងៗ ហើយជារឿយៗពួកគេពឹងលើអ្នកស្នងរូបបញ្ជាន់អារក្សដើម្បីបង្ហាញដំណោះស្រាយលើបញ្ហាផ្សេងៗ និងការព្យាបាលនានា។

ជាចុងក្រោយ ប្រទេសកម្ពុជាក៏មានសហគមន៍ជ្វីហ្វតូចមួយដែលមានសមាជិកជាង១០០នាក់ និងមណ្ឌលឆាបាត (Chabad) មួយដែលបានបង្កើតឡើងនៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ២០០៩។

## ១.២. ទិដ្ឋភាពច្បាប់ទាក់ទងនឹង ស.ស.ជ

រដ្ឋធម្មនុញ្ញកម្ពុជាធានាការពារសេរីភាពសាសនា និងជំនឿជាសិទ្ធិមូលដ្ឋាន ដោយធានាឱ្យសាសនាទាំងអស់ទទួលបានការប្រព្រឹត្តស្មើភាពគ្នាចំពោះមុខច្បាប់ និងហាមឃាត់ការរើសអើងផ្អែកតាមសាសនា។ ការប្តេជ្ញាចិត្តអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជាក៏ពង្រឹងការការពារទាំងនេះបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង ជួនកាលសិទ្ធិទាំងនេះមានការរឹតបន្តឹង ឬរំលោភបំពាន ជាពិសេសដល់ក្រុមសាសនាភាគតិច។

ម្យ៉ាងទៀត ក្នុងនាមជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិមួយចំនួន កម្ពុជាប្តេជ្ញារក្សាសិទ្ធិ និងសេរីភាពផ្សេងៗ រួមទាំងសេរីភាពសាសនា និងជំនឿ (ស.ស.ជ)។ សន្ធិសញ្ញាទាំងនេះចែងពីក្របខ័ណ្ឌច្បាប់រឹងមាំដែលគាំទ្រដល់ការការពារ និងការលើកកម្ពស់សេរីភាពសាសនានិងជំនឿ។ សន្ធិសញ្ញានីមួយៗរៀបរាប់អំពីសិទ្ធិ និងគោលការណ៍ដែលស្របតាមគោលដៅទូទៅដើម្បីធានាថាបុគ្គលម្នាក់ៗអាចប្រតិបត្តិសាសនារបស់ខ្លួនដោយសេរី មិនភ័យខ្លាចការរើសអើង ឬការធ្វើទុក្ខបុកម្នេញ។

ផ្នែកខាងក្រោមនឹងសង្ខេបថាសន្ធិសញ្ញាអន្តរជាតិសំខាន់ៗទាំងនេះចូលរួមបែបណាក្នុងការគាំទ្រការអនុវត្ត ស.ស.ជ នៅកម្ពុជា៖

1. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ធានានូវសិទ្ធិពលរដ្ឋ និងនយោបាយជាច្រើន រួមទាំងសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ សាសនា និងជំនឿ។ មាត្រា១៨នៃកតិកាសញ្ញានេះបញ្ជាក់ជាពិសេសអំពីសេរីភាពក្នុងការបង្ហាញពីសាសនា ឬជំនឿរបស់បុគ្គលម្នាក់ៗ

តាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្ត និងការបង្ហាត់បង្រៀន ជាលក្ខណៈបុគ្គល ឬជាសហគមន៍រួមជាមួយអ្នកដទៃទៀត។ សន្ធិសញ្ញានេះគាំទ្រការអនុវត្ត ស.ស.ជ ដោយធានាថាបុគ្គលម្នាក់ៗអាចអនុវត្ត និងបង្ហាញជំនឿសាសនារបស់ពួកគេដោយសេរី ដោយមិនខ្លាចការធ្វើទុក្ខបុកម្នេញ។

2. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ផ្តោតលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចជាសិទ្ធិការងារ អប់រំ និងសុខភាព។ កតិកាសញ្ញានេះមិនបានបញ្ជាក់ច្បាស់ៗអំពី ស.ស.ជ ទេ ក៏ប៉ុន្តែសិទ្ធិសេរីភាពខាង ការគិត សតិសម្បជញ្ញៈ និងសាសនា ត្រូវបានគាំទ្រដោយប្រយោលតាមរយៈ បរិបទទូទៅនៃសិទ្ធិ និងសេរីភាពខាងវប្បធម៌។ ចំណុចនេះជួយដល់ការលើកកម្ពស់ និងការពារការអនុវត្តវប្បធម៌ និងសាសនាចម្រុះ។

3. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) មានគោលបំណងលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីគ្រប់ទិដ្ឋភាពនៃជីវិត។ ទោះឃើញផ្តោតជាចម្បងលើសមភាពយេនឌ័រក៏ដោយ អនុសញ្ញានេះគាំទ្រដោយប្រយោលដល់ ស.ស.ជ តាមការលើកកម្ពស់សមភាព និងការមិនរើសអើង ដែលរាប់បញ្ចូលសេរីភាពពីការរើសអើងផ្អែកតាមសាសនា ឬជំនឿ។ ចំណុចនេះធានាថាស្ត្រីអាចប្រតិបត្តិសាសនារបស់ខ្លួនដោយសេរីដោយមិនប្រឈមមុខនឹងការរើសអើងយេនឌ័រ។

4. អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ចែងអំពីសិទ្ធិទទួលបានការការពារ ការអប់រំ ការថែទាំសុខភាព និងសិទ្ធិមូលដ្ឋានផ្សេងទៀត។ ទោះជាមិននិយាយចំៗអំពី ស.ស.ជ អនុសញ្ញានេះបានលើកកម្ពស់សិទ្ធិកុមារក្នុងការមានសេរីភាពខាង

ការគិត សតិសម្បជញ្ញៈ និងសាសនា ស្របតាមសមត្ថភាពវិវត្តន៍ទៅមុខរបស់ពួកគេ។ ចំណុចនេះធានាថាកុមារអាចអភិវឌ្ឍ និងបង្ហាញជំនឿសាសនារបស់ពួកគេដោយសេរី និងសុវត្ថិភាព។

5. អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) មានគោលបំណងទប់ស្កាត់ការរើសអើងពូជសាសន៍ និងលើកកម្ពស់ការយល់ដឹងសម្រាប់ជាតិសាសន៍ទាំងអស់។ ដោយអនុសញ្ញាផ្តោតជាចម្បងលើសមភាពជាតិសាសន៍ ឃើញថាមានការគាំទ្រដោយប្រយោលដល់ ស.ស.ជ ដោយសង្កត់ធ្ងន់លើសមភាព ការមិនរើសអើង និងការយោគយល់រវាងក្រុមសាសនា និងជនជាតិផ្សេងៗគ្នា។ ចំណុចនេះបង្កើតបរិយាកាសសន្តិសហវិជ្ជមានក្នុងការប្រតិបត្តិសាសនាចម្រុះ។

6. អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT) មានគោលបំណងទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប។ ទោះជាអនុសញ្ញានេះ មិននិយាយចំៗដល់ ស.ស.ជ ឃើញថាមានការគាំទ្រដល់ក្របខ័ណ្ឌសិទ្ធិមនុស្សជាលក្ខណៈទូលាយ ដែលរួមមានសេរីភាពសាសនា និងជំនឿ ជាសិទ្ធិមនុស្សមូលដ្ឋាន។ ចំណុចនេះធានាថាបុគ្គលម្នាក់ៗទទួលបានការការពារពីការធ្វើទារុណកម្ម និងការធ្វើបាបដោយផ្អែកលើជំនឿសាសនារបស់ខ្លួន។

ទោះមានការគាំទ្រផ្នែកច្បាប់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងក្នុងសន្ធិសញ្ញាអន្តរជាតិទាំងនេះក៏ដោយ ក៏មានករណីខ្លះឃើញថាសិទ្ធិទទួលបាន ស.ស.ជ ត្រូវបានរឹតបន្តឹង ឬរំលោភបំពានពេលអនុវត្តជាក់ស្តែង។ សាសនាភាគតិច ជាពិសេសគ្រិស្តសាសនិក និងអ្នកកាន់សាសនាឥស្លាម បានរាយការណ៍ថាបានជួបបទពិសោធន៍នៃការរើសអើង ការយាយី និងការរឹតបន្តឹង ពេលពួកគេធ្វើសកម្មភាពសាសនា។ បន្ថែមលើនេះ បក្ខានុគ្រោះ ដល់ពុទ្ធសាសនាថេរវាទរបស់រដ្ឋាភិបាលដែលជាសាសនាមានការប្រតិបត្តិភាគច្រើនលើសលុប ត្រូវបានរិះគន់ដោយប្រយោលថាបានដាក់កំហិតលើសិទ្ធិរបស់សាសនាភាគតិចដទៃទៀត។ ការរឹតបន្តឹងការប្រតិបត្តិទាំងនេះ បង្ហាញឱ្យឃើញមានគម្លាតរវាងការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ប្រទេសកម្ពុជា និងស្ថានភាពជាក់ស្តែងដែលសាសនាភាគតិចបានប្រឈម ហើយបង្កើតជាបរិយាកាសមួយដែល ស.ស.ជ មិនមានលក្ខណៈពេញលេញសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ឡើយ។

*បក្ខានុគ្រោះ តាមវចនានុក្រមខ្មែរ២០២២ មានន័យពីរ។ អត្ថន័យនៃពាក្យនេះនៅក្នុងរបាយការណ៍នេះ ត្រូវនឹងន័យទី១គឺ សេចក្តីលម្អៀងដោយអនុគ្រោះចំពោះមនុស្ស ឬក្រុមណាមួយ; ការកាន់ជើង។*



# ២.

# រំលឹកទ្រឹស្តីពាក់ព័ន្ធ សេរីភាពសាសនា ឬជំនឿនៅកម្ពុជា

សេរីភាពសាសនា ឬជំនឿ (ស.ស.ជ) គឺជាសិទ្ធិរបស់មនុស្សដ៏សំខាន់ ដែលធានាថាបុគ្គលម្នាក់ៗអាចប្រតិបត្តិសាសនាខ្លួនដោយពុំមានការរៀតត្បិត ឬការរើសអើង។ ក្នុងផ្នែករំឭកទ្រឹស្តីនេះស្ទាបស្ទង់ និងពិនិត្យមើលឯកសារទាក់ទងនឹង ស.ស.ជ នៅកម្ពុជា វិភាគបញ្ហាចម្បងៗ និងផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវបន្ថែម។

តាមទ្រឹស្តី ក្របខ័ណ្ឌច្បាប់នៅកម្ពុជាគាំទ្រដល់សេរីភាពសាសនានិងជំនឿ។ រដ្ឋធម្មនុញ្ញកម្ពុជាធានាសិទ្ធិសេរីភាពក្នុងការគោរពបូជាតាមជំនឿ និងសាសនា ក្នុងនោះក៏បានទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

> ***រដ្ឋាភិបាលលើកកម្ពស់ពិធីបុណ្យជាតិតាមបែបពុទ្ធសាសនា ផ្តល់ការបណ្តុះបណ្តាល និងការអប់រំពុទ្ធសាសនា ហើយគាំទ្រសមរម្យទៅដល់វិទ្យាស្ថានដែលធ្វើការស្រាវជ្រាវវប្បធម៌ និងប្រពៃណីពុទ្ធសាសនាខ្មែរ។***
>
> (ឯកសារ Wikipedia, ២០២៣)

ក្នុងច្បាប់ចែងថា ក្រុមអ្នកកាន់សាសនាទាំងអស់ត្រូវចុះឈ្មោះនៅក្រសួងធម្មការ និងសាសនា ដើម្បីសាងសង់ទីសក្ការបូជា និងធ្វើសកម្មភាពសាសនា។ ទោះមានចែងពីតម្រូវការទាំងនេះក៏ដោយ ក៏មិនមានការពិន័យធ្ងន់ធ្ងរដល់ករណីខកខានចុះឈ្មោះឡើយ លើកលែងតែម្យ៉ាងគឺមិនមានសិទ្ធិទទួលបានការលើកលែងពន្ធ។ សេចក្តីណែនាំស្តីពីការគ្រប់គ្រងសាសនាមកពីប្រទេសក្រៅបានកំណត់ឱ្យមានការចុះឈ្មោះដើម្បីបង្ការក្រុមសាសនាមិនឱ្យចូលរួមសកម្មភាពនយោបាយ ឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ (ឯកសារ U.S. Department of State, ២០២២)។

ទោះជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរដ្ឋាភិបាលមានឥទ្ធិពលខ្លាំងលើការប្រតិបត្តិសាសនា ជាពិសេសនៅក្នុងស្ថាប័នអប់រំរបស់រដ្ឋ។ មានគោលការណ៍ដ៏លេចធ្លោមួយគឺការហាមប្រាមការបង្រៀនសាសនាផ្សេងពីពុទ្ធសាសនានៅតាមសាលារដ្ឋ។ គោលនយោបាយនេះកំណត់ថា ទោះបីជាការបង្រៀនបែបពុទ្ធសាសនាអាចជាផ្នែកមួយនៃកម្មវិធីសិក្សាតាមសាលារដ្ឋក៏ដោយ ក៏ការបង្រៀនសាសនាផ្សេងទៀតមិនត្រូវបានអនុញ្ញាតឡើយ។ ការផាត់ចេញនេះអាចដាក់កំហិតលើការអប់រំសាសនា និងសិទ្ធិរបស់សិស្សមកពីក្រុមសាសនាភាគតិច ដូចជាគ្រិស្តសាសនិក និងអ្នកកាន់សាសនាឥស្លាម ដែលទំនងជាត្រូវស្វែងរកការអប់រំសាសនានៅក្រៅប្រព័ន្ធសាលារដ្ឋ។

***“ការបង្រៀនសាសនាផ្សេងពីពុទ្ធសាសនាត្រូវបានហាមឃាត់នៅតាមសាលារដ្ឋ ប៉ុន្តែទទួលបានការអនុញ្ញាតនៅស្ថាប័នឯកជន។ សិស្សពុំមែនជាពុទ្ធសាសនិកនៅតាមសាលារដ្ឋអាចជ្រើសរើសមិនចូលរៀនពុទ្ធសាសនាបាន ព្រោះនោះមិនមែនជាផ្នែកនៃកម្មវិធីសិក្សាស្នូល”***

(ឯកសារ អង្គការ ACN International, ២០២៣)។

គោលនយោបាយនេះធានាថា ការបង្រៀនពុទ្ធសាសនាមានច្រើនក្នុងទីអប់រំសាធារណៈ ជាហេតុពង្រឹងពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

នៅពេលលើកពីសិទ្ធិ ស.ស.ជ ក្នុងការផ្សព្វផ្សាយ ច្បាប់កម្ពុជាក៏ចែងតឹងរឹងលើការផ្សព្វផ្សាយ ដែលជាទង្វើប៉ុនប៉ងប្តូរនរណាម្នាក់ពីសាសនាមួយទៅសាសនាមួយផ្សេងទៀត។ ក្រុមអ្នកកាន់សាសនាផ្សេងពីពុទ្ធសាសនាបានទទួលរងជាពិសេសពីការរឹតត្បិតទាំងនេះ ដោយសារពួកគេមិនអាចធ្វើពិធីសាសនារបស់ខ្លួននៅទីសាធារណៈ។ ផ្ទុយទៅវិញ ពួកគេអាចចែករំលែកតែទ្រឹស្តីសាសនានៅក្នុងស្ថាប័នសាសនារៀងៗខ្លួនណាដែលចុះបញ្ជី

រួចប៉ុណ្ណោះ។ ការរឹតបន្តឹងនេះមានបំណងបង្ការភាពតានតឹងខាងសាសនា និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែការធ្វើបែបនេះក៏ដាក់កំហិតលើសេរីភាពបញ្ចេញមតិខាងសាសនាចំពោះក្រុមភាគតិចផងដែរ។ របាយការណ៍ស្តីពីសេរីភាពសាសនាអន្តរជាតិ ឆ្នាំ២០២២ របស់ស្ថានទូតសហរដ្ឋអាមេរិក បង្ហាញពីការរឹតបន្តឹងទាំងនេះថា៖

> ***ក្រុមផ្សេងពីពុទ្ធសាសនិកមិនអាចផ្សព្វផ្សាយជាសាធារណៈបានទេ ប៉ុន្តែទ្រឹស្តីសាសនាផ្សេងពីពុទ្ធសាសនាអាចចែកចាយបាននៅក្នុងស្ថាប័នសាសនារៀងៗខ្លួន***
>
> (ឯកសារ U.S. Department of State, ២០២២)។

ការរឹតបន្តឹងខាងផ្លូវច្បាប់ទាំងនេះត្រូវបានរៀបចំឡើង ដើម្បីគ្រប់គ្រងសកម្មភាពសាសនា និងធានាថាមិនរំខានដល់សម្ព័ន្ធសង្គមពុទ្ធសាសនាដែលមានច្រើនលើសលុបក្នុងប្រទេសកម្ពុជា។

គោលនយោបាយហាមប្រាមទាំងនេះមានផលប៉ះពាល់ខ្លាំងដល់សាសនាភាគតិចនៅកម្ពុជា។ ការហាមប្រាមការបង្រៀនសាសនាផ្សេងពីពុទ្ធសាសនានៅតាមសាលារដ្ឋមានន័យថា កុមារក្នុងសាសនាភាគតិចត្រូវពឹងផ្អែកលើសាលាសាសនាឯកជន ឬការអប់រំសាសនាតាមសហគមន៍។ ចំណុចនេះអាចបង្កើនចំណាយប្រាក់កាស និងប្រាក់ធ្វើដំណើរបន្ថែមដល់គ្រួសារដែលស្វែងរកការអប់រំសាសនាស្របតាមជំនឿរបស់ខ្លួន។

ជាងនេះទៅទៀត ការរឹតបន្តឹងលើការផ្សព្វផ្សាយបានដាក់កំហិតលើក្រុមសាសនាភាគតិចមិនឱ្យរីកលូតលាស់ និងអនុវត្តជំនឿខ្លួនបានដោយបើកចំហ។ នេះអាចបង្កអារម្មណ៍នៃការផាត់ចេញ និងរារាំងការបង្ហាញអត្តសញ្ញាណសាសនា។ បណ្តុំនៃគោលនយោបាយ

ទាំងនេះ ពង្រឹងនូវតួនាទីលេចធ្លោរបស់ព្រះពុទ្ធសាសនានៅក្នុងសង្គមកម្ពុជា និងបានបង្កជាបញ្ហាប្រឈមដល់សាសនាភាគតិច។

> ***ផ្អែកលើបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ និងច្បាប់នានា ជាទូទៅប្រជាជនកម្ពុជាទទួលបានកម្រិតសេរីភាពសាសនាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ការរឹតបន្តឹងលើការផ្សព្វផ្សាយ និងការបង្រៀនសាសនានៅតាមសាលារដ្ឋ បង្ហាញពីការផ្តល់អាទិភាពពិសេសដល់ពុទ្ធសាសនា***
>
> (ឯកសារអង្គការ ACN International, ២០២៣)។

បរិបទទំនាក់ទំនងសង្គមក្នុងប្រទេសកម្ពុជា មានការឃោគយល់ខាងសាសនាខ្លាំង ប៉ុន្តែបញ្ហាប្រឈមចម្បងៗនៅតែមាន។ ប្រជាជនភាគច្រើនប្រតិបត្តិពុទ្ធសាសនា តែក៏ឃើញមានច្រើនគួរកត់សម្គាល់នូវសហគមន៍គ្រិស្តបរិស័ទ ឥស្លាមសាសនិក និងជំនឿព្រលឹងវិញ្ញាណជនជាតិដើមភាគតិចផងដែរ។ ក្រុមទាំងនេះច្រើនប្រឈមនឹងភាពលម្អៀងក្នុងសង្គម និងធនធានមានកំណត់សម្រាប់ការប្រតិបត្តិសាសនារបស់ខ្លួន។ ឧទាហរណ៍៖

នៅព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ក្រុមពុទ្ធសាសនិកមួយក្រុមបានវាយកម្ទេចព្រះវិហារគ្រិស្តសាសនាកំពុងសង់មួយកន្លែងក្នុងខេត្តកណ្តាល ដោយសារពុំមានលិខិតអនុញ្ញាតសាងសង់អគារសាសនា។ តាមសេចក្តីរាយការណ៍ អាជ្ញាធរខេត្តបានបដិសេធមិនឱ្យវិហារ Wesleyan សង់ព្រះវិហារទើបក្រុមនេះបានសាងសង់ផ្ទះសម្រាប់គ្រូបង្រៀនសាសនាដែលក្រោយមកបំលែងទៅជាព្រះវិហារ។ តាមសេចក្តីរាយការណ៍ អភិបាលស្រុកនៃតំបន់នោះបានចរចាផ្សះផ្សារវាងពុទ្ធសាសនិក និងគ្រិស្តសាសនិកក្នុងតំបន់នោះ ព្រោះផ្ទះអាចសង់ឡើងវិញបាន ហើយក៏ពុំមានការ

ប្តឹងផ្តល់លើអ្នកដែលចូលរួមកុបកម្មនោះដែរ (ឯកសារ United States Bureau of Democracy, Human Rights and Labour, ២០០៧)។

ក្រោយមកអ្នកដឹកនាំព្រះវិហារក្នុងមូលដ្ឋានបានបញ្ជាក់ថា ផ្ទះនេះមិនទាន់ត្រូវបានសាងសង់ឡើងវិញនៅឡើយទេ ប៉ុន្តែពួកគេគ្រោងនឹងបំប្លែងអគារនោះទៅជាសាលាគ្រិស្តសាសនា។

ក្រុមសិទ្ធិមនុស្សបានចោទប្រកាន់បុគ្គល និងក្រុមហ៊ុន “អ្នកមាន និងអ្នកមានអំណាច” ថាដើម្បីបំរើគោលដៅពាណិជ្ជកម្ម ខ្លួនបានឈូសឆាយព្រៃខុសច្បាប់ដែលជាទីកន្លែងសក្ការៈសម្រាប់ជនជាតិដើមភាគតិច។

> *ក្រុមសិទ្ធិមនុស្សជនជាតិដើមភាគតិចបានចោទប្រកាន់ក្រុមហ៊ុននានា ដែលបានទទួលសម្បទានក្នុងព្រៃការពារ ថាបានកាប់ឆ្ការព្រៃដោយខុសច្បាប់ដែលជាទីគោរពបូជាសម្រាប់ជនជាតិដើមភាគតិចមួយចំនួន*
>
> (ឯកសារ US State Department, ២០២៣)។

ផលប៉ះពាល់នៃការឈូសឆាយដីខុសច្បាប់ពីសំណាក់បុគ្គល ឬក្រុមហ៊ុនអ្នកមាន និងមានអំណាចនៅទីសក្ការបូជារបស់ជនជាតិដើមភាគតិចគឺជាបញ្ហាដ៏ធំមួយ។ សកម្មភាពទាំងនេះគំរាមកំហែងដល់ទីកន្លែងរូបវន្តផង និងដល់ការប្រតិបត្តិវប្បធម៌ និងជំនឿនៅកន្លែងនោះផង។

តួនាទីរបស់រដ្ឋាភិបាលសម្រាប់សេរីភាពសាសនាមានភាពស្មុគស្មាញ។ ខណៈពេលដែលក្របខ័ណ្ឌច្បាប់ការពារសេរីភាពសាសនា ជួនកាលគោលនយោបាយរដ្ឋាភិបាលបានរំលោភបំពានសិទ្ធិទាំងនេះ។ ជាក់ស្តែង ច្បាប់ស្តីពីវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩បានចែងពីការរឹតបន្តឹងធ្ងន់ធ្ងរ ហើយបានប៉ះពាល់ដល់ក្រុមភាគតិចក្នុងកម្រិតខុសៗគ្នា។ ជាងនេះទៅទៀត សំណើច្បាប់ដែលដាក់ទោសទណ្ឌដល់ការចូលរួមនយោបាយរបស់ឥស្សរជនសាសនា (រួមទាំងព្រះសង្ឃដែលរងការគំរាម 'ផ្សឹក' ករណីជាសកម្មជន) បានបង្កការគំរាមកំហែងខ្លាំងដល់សេរីភាពបញ្ចេញមតិខាងសាសនា និងនយោបាយ។

> ***សំណើច្បាប់នឹងដាក់ទោស 'អ្នកកាន់សាសនា' ដែលចូលរួមសកម្មភាពនយោបាយ រួមទាំងសកម្មភាពរៀបចំប្រឆាំងគណបក្សនយោបាយណាមួយ***
>
> (ឯកសារអង្គការ ACN International, ២០២៣)។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាក៏រងការរិះគន់ចំពោះការនិរទេសជនភៀសខ្លួនសាសនា ជាពិសេសពួកគ្រិស្តសាសនាម៉ុងតាញ៉ាពីប្រទេសវៀតណាម និងពួកឥស្លាមអ៊ុយហ្គួពីប្រទេសចិន។ សកម្មភាពទាំងនេះបង្កក្តីបារម្ភផ្នែកសិទ្ធិមនុស្សយ៉ាងខ្លាំង។

កាលពីឆ្នាំ២០០៩ កម្ពុជាបានធ្វើឱ្យក្រុមសិទ្ធិមនុស្សអន្តរជាតិចាប់អារម្មណ៍ នៅពេលជនជាតិអ៊ុយហ្គួតស្លាម២០នាក់ត្រូវប៉ូលិសកម្ពុជាចាប់ខ្លួន និងនិរទេសទៅប្រទេសចិនវិញ។ ជនជាតិអ៊ុយហ្គួបានសុំសិទ្ធិជ្រកកោននៅប្រទេសកម្ពុជា ដើម្បីគេចពីការគាបសង្កត់នៅក្នុងតំបន់ស៊ីងជាំង របស់ប្រទេសចិន។ បើទោះជាមានការអំពាវនាវពី

អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិក្តី ក៏កម្ពុជាបន្តការនិរទេសដដែល។ ស្ថានទូតសហរដ្ឋអាមេរិកបានសម្តែង "ការព្រួយបារម្ភយ៉ាងខ្លាំង" ចំពោះការនិរទេសដោយកត់សម្គាល់ថា៖

> ***ជនជាតិអ៊ុយហ្គួដែលនិរទេសទៅវិញទំនងជាប្រឈម នឹងទណ្ឌកម្មធ្ងន់ធ្ងរនៅពេលត្រឡប់ទៅដល់ប្រទេសចិនវិញ***
>
> (ឯកសារ U.S. Department of State, ២០០៩)។

ហេតុការណ៍គួរឱ្យកត់សម្គាល់មួយទៀតទាក់ទងនឹងការនិរទេសពួកគ្រិស្តសាសនាម៉ុងតាញ៉ា នៅឆ្នាំ២០១៧។ ជនជាតិម៉ុងតាញ៉ា ដែលជាក្រុមជនជាតិដើមមកពីតំបន់ខ្ពង់រាបភាគកណ្តាលរបស់វៀតណាម បានភៀសខ្លួនមកប្រទេសកម្ពុជាដើម្បីសុំសិទ្ធិជ្រកកោនដោយសារតែការធ្វើទុក្ខបុកម្នេញ នៅប្រទេសវៀតណាម។ ទោះបីជាមានការគាបសង្កត់ពីអន្តរជាតិ និងការអំពាវនាវពីអង្គការសិទ្ធិមនុស្សក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបាននិរទេសជនជាតិម៉ុងតាញ៉ាជាច្រើននាក់ត្រឡប់ទៅប្រទេសវៀតណាមវិញទាំងបង្ខំ ហើយនៅទីនោះពួកគេប្រឈមនឹងការជាប់ពន្ធនាគារ និងការធ្វើទុក្ខបុកម្នេញបន្ថែមទៀត។ របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានគូសបញ្ជាក់ថា៖

> ***កម្ពុជាបានរំលោភកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនដោយបញ្ជូនជនភៀសខ្លួនត្រឡប់ទៅវិញ ដែលប្រឈមការធ្វើទុក្ខបុកម្នេញធ្ងន់ធ្ងរ***
>
> (ឯកសារ Human Rights Watch, ២០១៧)។

ហេតុការណ៍ទាំងនេះបង្ហាញពីលំនាំមិនល្អនៃការមិនយកចិត្តទុកដាក់របស់កម្ពុជាទៅលើ ពិធីសារស្តីពីសិទ្ធិជ្រកកោនអន្តរជាតិ និងកាតព្វកិច្ចសិទ្ធិមនុស្សដែលរងឥទ្ធិពលជារឿយៗពីចំណងនយោបាយ និងសេដ្ឋកិច្ចជាមួយប្រទេសជិតខាង។

## យេនឌ័រ និង ស.ស.ជ នៅកម្ពុជា

ចំណុចប្រសព្វនៃសមភាពយេនឌ័រ និងសេរីភាពសាសនា ឬជំនឿនៅកម្ពុជាមានលក្ខណៈពហុវិស័យ ហើយពាក់ព័ន្ធទៅនឹងទិដ្ឋភាពផ្នែកច្បាប់សង្គម និងវប្បធម៌។ ចំណុចប្រសព្វនេះជះឥទ្ធិពលលើការប្រតិបត្តិសាសនា ការដឹកនាំរបស់ស្ត្រីក្នុងវិស័យសាសនា និងស្ថានភាពសមភាពយេនឌ័រនៅក្នុងប្រទេស។

រដ្ឋធម្មនុញ្ញកម្ពុជាធានាសេរីភាពសាសនា និងហាមប្រាមការរើសអើងដោយផ្អែកលើយេនឌ័រ។

> ***រដ្ឋធម្មនុញ្ញបានចែងពីសេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ និងសាសនាដទៃទៀត ឬសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ***
>
> (ឯកសារ US State Department, ២០២៣)។

ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តការការពារផ្លូវច្បាប់ទាំងនេះអាចមានភាពមិនស៊ីចង្វាក់គ្នា ជាពិសេសនៅក្នុងបរិបទនៃការប្រតិបត្តិសាសនា និងបទដ្ឋានយេនឌ័រ។ សេរីភាពសាសនានៅកម្ពុជាជាទូទៅទទួលបានការគោរព ប៉ុន្តែឥទ្ធិពលនៃជំនឿប្រពៃណី និងជំនឿសាសនាជួនកាលនៅតែបង្កជាវិសមភាពយេនឌ័រ។

ក្នុងសង្គមកម្ពុជា ទំនាក់ទំនងឥទ្ធិពលសង្គមនិងវប្បធម៌ និងការកំណត់តួនាទីយេនឌ័រតាមបែបប្រពៃណី មានទំនាក់ទំនងស៊ីជម្រៅជាមួយជំនឿសាសនា ជាពិសេសជំនឿក្នុងពុទ្ធសាសនាដែលជាសាសនាមានអ្នកប្រតិបត្តិច្រើន។ ការបង្រៀនតាមបែបពុទ្ធសាសនាតែងតែសង្កត់ធ្ងន់លើសារៈសំខាន់ស្ត្រីក្នុងការបំពេញតួនាទីបែបប្រពៃណីជាភរិយា និងជាម្តាយ។ កត្តានេះហើយដែលរឹតត្បិតការចូលរួមរបស់ស្ត្រីក្នុងផ្លូវសាសនា និងជីវិតទូទៅប្រចាំថ្ងៃ។ ចំណុចនេះអាចធ្វើឱ្យផ្នត់គំនិតយេនឌ័រនៅតែបន្តកើតមាន និងរឹតត្បិតឱកាសរបស់ស្ត្រីក្នុងការក្លាយជាអ្នកដឹកនាំនៅក្នុងសហគមន៍សាសនា។

ការអនុវត្ត "ច្បាប់ស្រី" ដែលជាក្រមសីលធម៌ប្រពៃណីសម្រាប់ស្ត្រី បានជម្រុញបន្ថែមនូវការរំពឹកទុកទៅលើតួនាទីយេនឌ័រខាងលើនេះ។ គួរកត់សម្គាល់ថា ច្បាប់ស្រីចាក់ឫសគល់តែនៅក្នុងទំនៀមទម្លាប់វប្បធម៌ប៉ុណ្ណោះ តែមិនមានឫសគល់នៅក្នុងលទ្ធិសាសនាទេ។ ក៏ប៉ុន្តែ ច្បាប់នេះមានឥទ្ធិពលខ្លាំងលើរបៀបយល់ឃើញ និងអនុវត្តតួនាទីយេនឌ័រនៅក្នុងបរិបទសាសនា។

> ***ច្បាប់ស្រី ដែលជាក្រមសីលធម៌ប្រពៃណីសម្រាប់ស្ត្រី បានបង្កើនការរំពឹងទុកពីស្ត្រីថាត្រូវចេះស្តាប់បង្គាប់ និងបំពេញតួនាទីក្នុងផ្ទះសម្បែង ហើយចំណុចនេះអាចរឹតត្បិតការចូលរួមរបស់ស្ត្រីនៅក្នុងផ្លូវសាសនា និងជីវិតទូទៅប្រចាំថ្ងៃ***
>
> (ឯកសារ Cambodia Gender Assessment, ២០១៤)។

បញ្ហាទាក់ទងនឹងយេនឌ័រក្នុងការប្រតិបត្តិសាសនា ជារឿយៗធ្វើឱ្យស្ត្រីកម្ពុជាប្រឈមនឹងការរាំងស្ទះដល់ការចូលរួមសកម្មភាពសាសនា និងតួនាទីជាអ្នកដឹកនាំបានពេញលេញ។ នៅក្នុងពុទ្ធសាសនាថេរវាទ ការបំបួសស្ត្រីជាសង្ឃ (ភិក្ខុនី) មិនត្រូវបានទទួលយកជាទូទៅទេ ជាហេតុមានការកំណត់សិទ្ធិអំណាច និងតួនាទីស្ត្រីក្នុងសាសនានៅក្នុងសហគមន៍សង្ឃ។

ការផាត់ចេញការចូលរួមដឹកនាំសាសនានេះ បានបង្កើនវិសមភាពយេនឌ័រក្នុងសង្គម ដែលធ្លាប់មានពីមុនឱ្យកាន់តែធំទៅៗ។

> ***ការខ្វះខាតការទទួលយកការបំបួសស្ត្រីនៅក្នុងព្រះពុទ្ធសាសនាបាន ដាក់កំហិតលើសិទ្ធិអំណាច និងតួនាទីរបស់ស្ត្រីក្នុងសាសនានៅក្នុង សហគមន៍សង្ឃ ជាហេតុបង្កើនវិសមភាពយេនឌ័រ ក្នុងសង្គមកាន់តែធំៗទៅៗ***
>
> (ឯកសារ UN Women, ២០១៦)។

លើសពីនេះ ស្ត្រីមកពីក្រុមសាសនាភាគតិច ដូចជាសាសនាឥស្លាម និង គ្រិស្តសាសនា អាចប្រឈមនឹងការរើសអើងផ្ទួន ដោយសារអត្តសញ្ញាណយេនឌ័រ និងសាសនារបស់ខ្លួន។ គេឃើញមានដូចជាការរឹតបន្តឹងសិទ្ធិទទួលបានការអប់រំ ការងារ និងការប្រតិបត្តិសាសនា ជាពិសេសនៅតាមតំបន់ជនបទ ព្រោះទីនោះ មានការប្រកាន់តឹងរ៉ឹងជាងនូវបទដ្ឋានប្រពៃណី និងសាសនា។

## ឥទ្ធិពលនៃគោលនយោបាយសាសនាទៅលើសមភាពយេនឌ័រ

គោលនយោបាយរបស់រដ្ឋាភិបាល និងឥរិយាបថសង្គមស្តីពីការប្រតិបត្តិ សាសនាអាចប៉ះពាល់ដល់សមភាពយេនឌ័រយ៉ាងខ្លាំង។ ឧទាហរណ៍ ការហាមប្រាម ការបង្រៀនសាសនាផ្សេងពីពុទ្ធសាសនានៅតាមសាលារដ្ឋ និងការរឹតបន្តឹងលើការ ផ្សព្វផ្សាយសាសនា អាចប៉ះពាល់ដល់ស្ត្រីក្រុមភាគតិច ដោយមានការកម្រិត លទ្ធភាពទទួលបានការអប់រំខាងសាសនា និងការគាំទ្រសហគមន៍។

*គោលនយោបាយរបស់រដ្ឋាភិបាលដែលរឹតបន្តឹងការប្រតិបត្តិសាសនា ដូចជាការហាមប្រាម ការបង្រៀនសាសនាផ្សេងពីពុទ្ធសាសនា នៅតាមសាលារដ្ឋ អាចប៉ះពាល់ដល់ស្ត្រីមកពីក្រុមសាសនាភាគតិច*

(ឯកសារ ACN International, ២០២៣)។

ជាងនេះទៅទៀត ច្បាប់ និងគោលនយោបាយដែលប្រសព្វជាមួយការប្រតិបត្តិសាសនា ដូចជាការកំណត់បែបបទនៃការស្លៀកពាក់ ឬការចូលរួមក្នុងពិធីសាសនា ក៏អាចប៉ះពាល់ដល់សេរីភាព និងស្វ័យភាពរបស់ស្ត្រីផងដែរ។ ឧទាហរណ៍ ស្ត្រីដែលកាន់សាសនាឥស្លាមអាចប្រឈមនឹងបញ្ហាស្លៀកពាក់បែបសាសនា ដូចជាការពាក់ហ៊ីចាប់នៅទីសាធារណៈ ឬកន្លែងធ្វើការ។

ចំណុចប្រទាក់ក្រឡាគ្នានៃសមភាពយេនឌ័រ និងសេរីភាពសាសនាឬជំនឿនៅកម្ពុជា កើតមានឡើង នៅពេលដែលមានភាពប្រសព្វគ្នានៃកត្តាច្បាប់ សង្គម និងវប្បធម៌។ ខណៈពេលក្របខណ្ឌច្បាប់បានផ្តល់សេរីភាពសាសនា និងសមភាពយេនឌ័រ បទដ្ឋានប្រពៃណី និងសាសនាតែងបង្កឱ្យមានវិសមភាពយេនឌ័រ។ ការដោះស្រាយបញ្ហាទាំងនេះតម្រូវឱ្យមានការប្រើវិធីសាស្ត្រដែលមានលក្ខណៈសព្វជ្រុងជ្រោយ រួមមានកំណែទម្រង់ច្បាប់ ការអប់រំសង្គម និងការប្រតិបត្តិសាសនាប្រកបដោយបរិយាបន្ន។

ការរំឭកទ្រឹស្តីខាងលើបង្ហាញយ៉ាងច្បាស់អំពីបញ្ហាមួយចំនួនសម្រាប់ការស្រាវជ្រាវបន្ថែម។

នៅក្នុងបរិបទនៃប្រទេសកម្ពុជា សម្រាប់ការស្រាវជ្រាវបន្ថែមទៀត គឺចាំបាច់ត្រូវស្វែងយល់ពីផលប៉ះពាល់នៃក្របខ័ណ្ឌច្បាប់ទៅលើការអនុវត្តសេរីភាពសាសនា។

ខណៈពេលរដ្ឋធម្មនុញ្ញកម្ពុជាធានាសេរីភាពសាសនា និងទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ខ្លឹមសារនិងផលប៉ះពាល់ជាក់ស្តែងនៃការធានានិងទទួលស្គាល់ទន្ទឹមគ្នានេះ ទាមទារឱ្យមានការពិនិត្យស៊ីជម្រៅ។ គប្បីពិនិត្យមើលថាតើបទប្បញ្ញត្តិផ្លូវច្បាប់ទាំងនេះមានការអនុវត្តបែបណា ហើយតើវាបង្កើតទំនោរគាំទ្រទៅរកពុទ្ធសាសនាជាងសាសនាផ្សេងទៀតឬទេ។ ការពិនិត្យនេះនឹងជួយផ្តល់ការយល់ដឹងស៊ីជម្រៅនិងមានតម្លៃសម្រាប់ប្រសិទ្ធភាពនិងយុត្តិធម៌នៃក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជាមកលើសេរីភាពសាសនា។

វិស័យដ៏សំខាន់មួយសម្រាប់ការស្រាវជ្រាវបន្ថែម គឺអន្តរកម្មដ៏ស្មុគស្មាញរវាងសេរីភាពសាសនា និងគោលនយោបាយអប់រំនៅកម្ពុជា។ ប្រព័ន្ធអប់រំបច្ចុប្បន្ន អនុញ្ញាតឱ្យមានការបង្រៀនអំពីព្រះពុទ្ធសាសនា ប៉ុន្តែហាមមិនឱ្យបង្រៀនសាសនាផ្សេងទៀតនៅតាមសាលារដ្ឋ។ ចំណុចនេះបង្កការព្រួយបារម្ភដល់បរិយាបន្នភាព និងយុត្តិធម៌។ ការសិក្សាស៊ីជម្រៅគឺចាំបាច់ ដើម្បីស្វែងយល់ពីផលប៉ះពាល់នៃគោលនយោបាយនេះមកលើសិស្សដែលប្រកាន់ជំនឿភាគតិច តាមរយៈការពិនិត្យមើលថាតើគោលនយោបាយនេះប៉ះពាល់បែបណាដល់សិទ្ធិទទួលបានការអប់រំសាសនារបស់សិស្ស ហើយប៉ះពាល់បែបណាដល់គោលបំណងជាទូទៅដើម្បីឱ្យមានភាពចុះសម្រុងគ្នាក្នុងសង្គមនិងការយល់ដឹងអន្តរសាសនា ហើយតើប៉ះពាល់យ៉ាងណាដល់ការចំណាយចរិកាសម្រាប់ការអប់រំនៅស្ថាប័នសាសនាឯកជននៅកម្ពុជា។

ការរឹតបន្តឹងលើការផ្សព្វផ្សាយសាសនា និងផលប៉ះពាល់នៃការរឹតបន្តឹងនេះទៅលើសាសនាភាគតិចក៏ជាបច្ច័យសម្រាប់ការសិក្សាបន្ថែមទៀតផងដែរ។ ច្បាប់កម្ពុជាដាក់កំហិតលើលទ្ធភាពផ្សព្វផ្សាយសាសនានៅទីសាធារណៈសម្រាប់ក្រុមអ្នកមិនកាន់ពុទ្ធសាសនាដែលអាចរារាំងដល់ការរីកចម្រើន និងការបញ្ចេញមតិនៃសាសនាភាគតិច។ ការស្រាវជ្រាវ

គួរស្វែងយល់ថាតើ ការរឹតបន្តឹងទាំងនេះប៉ះពាល់ដល់សហគមន៍សាសនាភាគតិចកម្រិតណា ប៉ះពាល់ដល់លទ្ធភាពក្នុងការប្រតិបត្តិ និងផ្សព្វផ្សាយជំនឿរបស់ខ្លួនកម្រិតណា ហើយប៉ះពាល់ដល់ទំនាក់ទំនងសង្គមរវាងក្រុមសាសនាផ្សេងៗគ្នាកម្រិតណា។ ការថ្លឹងថ្លែងតុល្យភាពរវាងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការធានាសេរីភាពសាសនាគឺមានសារៈសំខាន់ក្នុងបរិបទនេះ។

យេនឌ័រ និងសេរីភាពសាសនានៅកម្ពុជាទាមទារឱ្យមានការស្រាវជ្រាវបន្ថែមទៀត។ បទដ្ឋានប្រពៃណី និងសាសនា ជាពិសេសបទដ្ឋានដែលចាក់ឫសគល់នៅក្នុងពុទ្ធសាសនា ជារឿយៗអាចរារាំងតួនាទីយេនឌ័រ ដែលរឹតត្បិតការចូលរួមរបស់ស្ត្រីទាំងក្នុងផ្លូវសាសនា និងជីវិតទូទៅប្រចាំថ្ងៃ។

## ការស្រាវជ្រាវស៊ីជម្រៅគឺចាំបាច់ដើម្បីពិនិត្យមើល៖

- តើបទដ្ឋានយេនឌ័រទាំងនេះប៉ះពាល់ដូចម្តេចដល់ឱកាសរបស់ស្ត្រីក្នុងសហគមន៍សាសនា និងសង្គមទូទៅ?
- តើអ្វីទៅជាឧបសគ្គរារាំងស្ត្រីមិនឱ្យទទួលបានតំណែងជាអ្នកដឹកនាំក្នុងប្រពៃណីជំនឿរបស់ពួកគេ?
- តើចំណុចប្រសព្វនៃអត្តសញ្ញាណយេនឌ័រ និងសាសនាភាគតិចបង្កើតឱ្យមានការរើសអើងផ្ទួនគ្នាបែបណាខ្លះ?

តាមរយៈការឆ្លើយសំណួរទាំងនេះ យើងអាចទទួលបានការយល់ដឹងស៊ីជម្រៅដែលជួយក្នុងការបង្កើតលំហសមធម៌បន្ថែមទៀតសម្រាប់ស្ត្រីនៅក្នុងសង្គមកម្ពុជា ជាពិសេសនៅក្នុងវិស័យសាសនា។

នៅប្រទេសកម្ពុជា ការព្រួយបារម្ភមួយដែលកំពុងកើនឡើងលើទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយប្រទេសចិន។ ឥទ្ធិពលផ្នែកហិរញ្ញវត្ថុ និងនយោបាយដែលកំពុងកើនឡើងរបស់ចិននៅប្រទេសកម្ពុជា បង្កើនក្តីបារម្ភដល់បញ្ហាសិទ្ធិមនុស្ស និងសេរីភាពសាសនា។ ការស្រាវជ្រាវបែបប្រៀបធៀបគឺសំខាន់ក្នុងករណីនេះ។ តាមរយៈការពិនិត្យមើលច្បាប់ស្រដៀងគ្នានៅក្នុងប្រទេសទាំងពីរ យើងអាចកំណត់រកភាពស្រដៀងគ្នា និងភាពខុសគ្នា រវាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់កម្ពុជា (LANGO) និងបទប្បញ្ញត្តិរបស់ប្រទេសចិនស្តីពីការប្រតិបត្តិសាសនា។ នោះវានឹងបង្ហាញឱ្យឃើញថាតើនយោបាយអន្តរជាតិក្នុងសហគមន៍អាស៊ានមានឥទ្ធិពលបែបណាលើគោលនយោបាយក្នុងស្រុករបស់កម្ពុជាទៅលើក្រុមសាសនា ហើយក្រោយមកកំណត់នូវទិដ្ឋភាពសិទ្ធិមនុស្សទាំងមូល។

ជាចុងក្រោយ ផលប៉ះពាល់នៃគោលនយោបាយរបស់រដ្ឋាភិបាលមកលើសាសនាភាគតិច ជាពិសេសក្នុងបរិបទនៃសិទ្ធិដីធ្លី និងការផ្លាស់ទីលំនៅ គឺទាមទារឱ្យមានការពិនិត្យហ្មត់ចត់។ របាយការណ៍អំពីការឈូសឆាយដីខុសច្បាប់ដែលប៉ះពាល់ដល់ទីកន្លែងសក្ការៈរបស់ជនជាតិដើមភាគតិច បង្ហាញឱ្យឃើញពីបញ្ហាចម្បងៗ នៅពេលផលប្រយោជន៍សេដ្ឋកិច្ច និងនយោបាយទៅប៉ះគ្នានឹងសិទ្ធិសាសនា។ ការស្រាវជ្រាវគួរតែផ្តោតលើការចងក្រងឯកសារពាក់ព័ន្ធឧប្បត្តិហេតុទាំងនេះ ការយល់ដឹងអំពីយន្តការច្បាប់ និងយន្តការសង្គមដែលជំរុញឱ្យមានសកម្មភាពបែបនេះកើតឡើង និងស្នើវិធានការការពារបេតិកភណ្ឌសាសនានិងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច។ ចំណុចនេះផ្សារភ្ជាប់ច្រើនទៅនឹងកង្វល់ទាក់ទងនឹងសិទ្ធិមនុស្ស និងតម្រូវឱ្យមានការការពារផ្លូវច្បាប់ដែលមានប្រសិទ្ធភាពដល់ក្រុមងាយរងគ្រោះ។

ការពង្រឹងទិដ្ឋភាពសេរីភាពសាសនានៅកម្ពុជា ទាមទារឱ្យមានការស្រាវជ្រាវស៊ីជម្រៅក្នុងផ្នែកធំៗមួយចំនួន។ ការពិនិត្យមើលក្របខ័ណ្ឌច្បាប់ គោលនយោបាយអប់រំ ការរីតបន្តឹងការផ្សព្វផ្សាយសាសនា សមភាពយេនឌ័រក្នុងការប្រតិបត្តិសាសនា និងការកើនឡើងឥទ្ធិពលរបស់ចិននៅកម្ពុជា នឹងជួយរំលេចចេញកំណែទម្រង់ចាំបាច់ដើម្បីធានាឱ្យមានយុត្តិធម៌សម្រាប់ក្រុមសាសនាទាំងអស់។

## ការស្រាវជ្រាវនេះអាចដោះបញ្ហា និងផ្ដល់អត្ថប្រយោជន៍សំខាន់ៗដូចជា៖

- ការលើកកម្ពស់ការគោរព និងការយល់ដឹងពីគ្នាទៅវិញទៅមក។ តាមរយៈការដោះស្រាយវិសមភាពអប់រំផ្នែកសាសនា និងបញ្ហាប្រឈមនានារបស់សហគមន៍ភាគតិច យើងអាចជំរុញឱ្យមានបរិយាកាសប្រកបដោយការគោរព និងយល់ដឹងពីគ្នាទៅវិញទៅមកសម្រាប់ជំនឿចម្រុះ។
- ការពង្រឹងភាពរស់រវើកខាងវប្បធម៌របស់ប្រទេសកម្ពុជា។ ការពង្រឹងសិទ្ធិស្ត្រីក្នុងការអនុវត្តសាសនានឹងចម្រើនដល់ផ្នែកជំនឿ និងជំរុញសង្គមឱ្យកាន់តែមានបរិយាបន្នជាងមុន។ ការដករបាំងនានានឹងធានាថាមានការទទួលយកការបញ្ចេញមតិជាហេតុជួយប្រពៃណីឱ្យរីកចម្រើន។
- ការកសាងប្រជាជាតិដែលសាទរភាពចម្រុះ។ ការការពារទីសក្ការសាសនាជនជាតិដើមភាគតិច ត្រូវដើរទន្ទឹមគ្នាជាមួយនឹងការរក្សាការពារសេរីភាពសាសនា។ ការចេះថ្លឹងថ្លែងរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការគោរពកន្លែងសក្ការៈ ជំរុញឱ្យមានសង្គមកាន់តែមានការអបអរភាពចម្រុះ និងកាត់បន្ថយការរើសអើង។

សរុបមក ខណៈពេលក្របខ័ណ្ឌច្បាប់របស់ប្រទេសមានការគាំទ្រដល់សេរីភាពសាសនាតាមរយៈទ្រឹស្ដី ក៏បញ្ហាប្រឈមធំៗនៅតែកើតមានពេលអនុវត្តជាក់ស្ដែង។ ការដោះស្រាយបញ្ហា

ទាំងនេះតម្រូវឱ្យមានវិធីសាស្ត្រចម្រុះនិងបែបពហុវិស័យ ដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ ការអប់រំក្នុងសង្គម និងការលើកកម្ពស់សិទ្ធិមនុស្សជាសកលមួយឱ្យមានប្រសិទ្ធភាពខ្ពស់។

យ៉ាងណាមិញ គួរកត់សម្គាល់ផងដែរថា របាយការណ៍របស់ Freedom House ក្នុងឆ្នាំ២០២៣ បានវាយតម្លៃប្រទេសកម្ពុជា *"៣ពិន្ទុលើ៤ ផ្នែកសេរីភាពសាសនា"*។

## <u>ទស្សនៈផ្លូវច្បាប់ស្ដីពីសេរីភាពប្រតិបត្តិ ឬជំនឿលើសាសនាណាមួយ</u>

ក្នុងការពិនិត្យមើលស្ថានភាពនៃសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) នៅកម្ពុជា លទ្ធផលបង្ហាញឱ្យឃើញថា ខណៈពេលក្របខ័ណ្ឌច្បាប់ការពារសេរីភាពសាសនា ការអនុវត្តជាក់ស្ដែងមានលក្ខណៈខុសគ្នាខ្លាំង។ រដ្ឋធម្មនុញ្ញកម្ពុជានិងច្បាប់នានា ជាទូទៅគាំទ្រសិទ្ធិប្រតិបត្តិសាសនា ប៉ុន្តែបទពិសោធន៍របស់សហគមន៍សាសនាផ្សេងៗ បង្ហាញពីការប្រព្រឹត្តមិនស្មើភាពគ្នា និងការរឹតបន្តឹង។ ក្នុងការវិភាគនេះ យើងស្វែងយល់ពីបញ្ហាប្រឈមស្មុគស្មាញដែលក្រុមសាសនានៅកម្ពុជាជួប តាមរយៈការបង្ហាញថាតើការប្រតិបត្តិដោយរើសអើង និងឧបសគ្គផ្នែករដ្ឋបាលពេលខ្លះប៉ះពាល់បែបណាដល់ការការពារផ្នែកច្បាប់។

នៅកម្ពុជា ទោះជាមិនមានច្បាប់ច្បាស់លាស់ហាមឃាត់ការប្រតិបត្តិសាសនាណាមួយក៏ដោយ ក៏មានភស្តុតាងបង្ហាញថាមានការប្រព្រឹត្តិ ឬការទទួលស្គាល់សាសនាផ្សេងៗមិនស្មើភាពគ្នា។ ព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ទទួលបានសិទ្ធិមួយចំនួនខុសពីសាសនាដទៃ។ ឧទាហរណ៍ វត្តអារ៉ាមទទួលបានការចុះឈ្មោះជាអចិន្ត្រៃយ៍ដោយមិនចាំបាច់ចុះឈ្មោះឡើងវិញ ចំណែកទីគោរពបូជារបស់គ្រិស្តសាសនិក និងឥស្លាមសាសនិកវិញ មានពេលវេលាកំណត់សម្រាប់ការចុះឈ្មោះ (ដប់ឆ្នាំសម្រាប់វិហារសាសនាឥស្លាម

និងពីរឆ្នាំសម្រាប់វិហារគ្រិស្តសាសនា)។ លើសពីនេះ ការជ្រើសរើស និងការតែងតាំងអ្នកដឹកនាំពុទ្ធសាសនាមានដំណើរការផ្លូវការ និងតម្លាភាពច្រើន ផ្ទុយពីគ្រិស្តសាសនា និងសាសនាឥស្លាមដែលមានដំណើរការផ្លូវការតិចតួច។

ទោះបីជាមានការរក្សាការពារផ្លូវច្បាប់ដល់សេរីភាពសាសនាក៏ដោយ ក៏បញ្ហាប្រឈមសាំញ៉ាំ និងដោយប្រយោលរបស់សហគមន៍សាសនានៅតែឃើញមាន កើតឡើង។ ឧទាហរណ៍ក្នុងប្រវត្តិសាស្ត្រ ដូចជាការរឹតបន្តឹងលើជំនឿអរូបីក្នុងរបប **ប៉ុល ពត** បង្ហាញថា សម័យនោះ ជំនឿសាសនាត្រូវបានគេរារាំង ទោះបីជាមិនត្រូវបានអនុវត្តដូចសព្វថ្ងៃនេះក្តី។ សហគមន៍មួយចំនួនទទួលរងការរឹតបន្តឹងដោយប្រយោលទៅលើសេរីភាពសាសនាខ្លួន ដូចជាគម្រោងអភិវឌ្ឍន៍បានដាក់កំហិតលើការចូលប្រើប្រាស់ទីសក្ការៈ និងការប្រឈមក្នុងការរក្សាកន្លែងពិសិដ្ឋរបស់ពួកគេ។ នៅក្នុងតំបន់ដែលមានការប្រមូលផ្តុំក្រុមសាសនាជាក់លាក់ បញ្ហា ឬភាពលម្អៀងក្នុងមូលដ្ឋានអាចកើតមាន ទោះពុំមានការរាយការណ៍ក្នុងលទ្ធផលស្ទង់មតិអំពីការរើសអើងជ្រុលនិយមក្តី។ មានករណីដែល ការរើសអើងក្រុមសាសនា ឬការរើសអើងវណ្ណៈសង្គមសេដ្ឋកិច្ចខ្លះ បង្កឱ្យមានការខ្វះខាត ក្នុងការផ្តល់ជំនួយ ដែលរារាំងដោយប្រយោលដល់ការប្រតិបត្តិសាសនា។

មិនមានការហាមឃាត់ផ្លូវច្បាប់ច្បាស់លាស់ប្រឆាំងនឹងការប្រមូលផ្តុំដោយសេរី ដើម្បីគោរពបូជា ពិភាក្សា ឬបង្រៀនសាសនាទេ។ ទោះបីជាយ៉ាងនេះក្តី សហគមន៍ជំនឿខ្លះប្រឈមនឹងបញ្ហាចូលប្រើប្រាស់ ឬថែរក្សាកន្លែងពិសិដ្ឋ ដោយសារតែគម្រោងអភិវឌ្ឍន៍ ឬការរឹតបន្តឹងពីអាជ្ញាធរ។ អ្នកផ្តល់សម្ភាសបានលើកឡើងពីការលំបាកក្នុងការប្រតិបត្តិពិធីសែនព្រេនដោយមានមន្ត្រីប៉ូលីសតាមដាន និងមើលពួកគេ ដែលប្រៀបបាននឹងការឃាំឃើ ឬការឃ្លាំមើល។ សកម្មភាពទាំងនេះបង្កជាបរិយាកាសមួយធ្វើឱ្យសេរីភាពសាសនានិងជំនឿរងការរារាំងដោយប្រយោល ទោះបីពុំមានការរារាំងផ្នែកច្បាប់ជាក់លាក់ណាមួយក៏ដោយ។

ខណៈពេលទិន្នន័យរបស់យើងមិនបង្ហាញច្បាស់លាស់ ថាតើសហគមន៍សាសនាទទួលបានកន្លែងគោរពបូជាដោយរបៀបណានោះ ការស្រាវជ្រាវឯកសារមានស្រាប់បង្ហាញឱ្យឃើញទិដ្ឋភាពលាយឡំគ្នា។ សាសនាភាគតិច ជាពិសេសគ្រិស្តសាសនិកហាក់ដូចជាមិនមានឧបសគ្គក្នុងការជួលកន្លែងសម្រាប់ប្រតិបត្តិសាសនាឡើយ។

ទោះយ៉ាងនេះក្តី កង្វល់ទាក់ទងនឹងសមភាព និងយុត្តិធម៌នៅតែបន្តមាន។ ដំណើរការចុះឈ្មោះ មានភាពមិនស្មើគ្នា។ ការផ្តល់សិទ្ធិអនុញ្ញាតដល់វត្តអារ៉ាមមានលក្ខណៈអចិន្ត្រៃយ៍ រីឯទីសក្ការសាសនាឥស្លាម និងគ្រិស្តសាសនា គឺមានលក្ខណៈ បណ្តោះអាសន្ន។ លើសពីនេះ មានករណីច្រើនបង្ហាញថាទីកន្លែងពិសិដ្ឋធំៗរបស់សហគមន៍ជំនឿមួយចំនួនត្រូវរងការបំផ្លាញពីគម្រោងអភិវឌ្ឍន៍។ ស្ថានភាពនេះ គេអាចមើលឃើញថាជាការយាយី ឬការរំលោភបំពានការប្រតិបត្តិ និងទីកន្លែងជំនឿរបស់ពួកគេ។

ខណៈពេលបុគ្គលទាំងឡាយមានសិទ្ធិប្រតិបត្តិសាសនាឬជំនឿរបស់ខ្លួន ក៏មានដែរការរឹតបន្តឹងលើការផ្សព្វផ្សាយជំនឿសាសនារបស់ខ្លួនដោយបើកចំហ។ អ្នកចូលរួមផ្តល់ព័ត៌មានមួយភាគធំបង្ហាញថា បុគ្គលឬក្រុមដែលចង់ផ្សព្វផ្សាយសាសនារបស់ខ្លួន ដំបូងត្រូវសុំលិខិតអនុញ្ញាត ឬរត់ការ ក្នុងនោះគឺវិធានការច្បាប់តម្រូវឱ្យអ្នកផ្សព្វផ្សាយសាសនាសុំការឯកភាពជាផ្លូវការ មុននឹងធ្វើការផ្សព្វផ្សាយខ្លឹមសារ ឬសារសាសនា។ នៅខេត្តតាកែវ បុគ្គលដែលផ្សព្វផ្សាយសាសនាដោយមិនមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបានរងការផាកពិន័យមួយចំនួន ដែលនេះបង្ហាញពីផលវិបាកនៃការផ្សព្វផ្សាយដោយគ្មានលិខិតអនុញ្ញាត។ ទោះបីជាមានការអនុញ្ញាតក៏ដោយ ក៏នៅមានកម្រិតដែរ ដោយសារបុគ្គលម្នាក់ៗមិនអាចចេញពីផ្ទះមួយទៅផ្ទះមួយ ដើម្បីផ្សាយជំនឿសាសនា ដែលសឱ្យឃើញថាមានដែនកំណត់សម្រាប់វិធីសាស្រ្ត និងទីកន្លែងសម្រាប់ផ្សព្វផ្សាយសាសនា។

សរុបមក ខណៈពេលដែលរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ផ្សេងៗអនុញ្ញាតជាទូទៅឱ្យមានសេរីភាពសាសនាឬជំនឿយ៉ាងណាក្តី ក៏នៅតែមានភាពមិនស្មើគ្នានៅក្នុង ការអនុវត្តជាក់ស្តែង។ អាចមានឧបសគ្គខ្លះៗក្នុងការចូលរួមក្នុងសកម្មភាពមួយចំនួន ដូចជាបញ្ហាប្រឈមនឹងការជួបជុំគ្នាដោយសេរីដើម្បីគោរពបូជា និងដើម្បីពិភាក្សាអំពីសាសនា ការរឹតបន្តឹងសេរីភាពក្នុងការផ្សព្វផ្សាយសាសនាណាមួយ និងករណីយាឃីដល់អ្នកគោរពបូជា និងទីកន្លែងគោរពបូជា ជាពិសេសសម្រាប់សាសនាផ្សេងពីសាសនារបស់រដ្ឋ ដូចជាគ្រិស្តសាសនា និងប្រព័ន្ធជំនឿរបស់ជនជាតិដើមភាគតិច។



# ៣.

# វិធីសាស្ត្រស្រាវជ្រាវ

ការវាយតម្លៃសេរីភាពសាសនា និងជំនឿ (ស.ស.ជ) នៅក្នុងសហគមន៍គោលដៅ មានពិពណ៌នាលម្អិតដូចខាងក្រោម។ វិធីសាស្ត្រស្រាវជ្រាវពីមួយជំហានទៅមួយជំហាន គឺប្រើវិធីសាស្ត្របែបគុណវិស័យ និងបែបចូលរួមទាំងស្រុង ក្នុងនោះមានតំណាងពីដៃគូនីមួយៗដែលជ្រើសតាំងជាក្រុមស្រាវជ្រាវស្នូល។

នៅគ្រប់ជំហានក្នុងដំណើរការស្រាវជ្រាវ ដៃគូបានចូលរួមពេញលេញតាំងពីការសម្រេចចិត្តរើសវិធីសាស្ត្រស្រាវជ្រាវ ការកំណត់បញ្ហាស្រាវជ្រាវកម្មវត្ថុស្រាវជ្រាវ និងសំណួរស្រាវជ្រាវ បង្កើតកម្រងសំណួរស្ទង់មតិ ការបណ្តុះបណ្តាល ការពិនិត្យ និងការណែនាំរបស់អ្នកស្រាវជ្រាវសហគមន៍ ការចូលរួមដាក់កូដទិន្នន័យ និងដំណើរការផ្ទៀងផ្ទាត់ទិន្នន័យ។ ក្រុមការងារមកពីអង្គការនារីដើម្បីសន្តិភាព និងអ្នកប្រឹក្សាបានរួមគ្នាពិនិត្យការងារជាទៀងទាត់។

# ៣.១. បញ្ហាស្រាវជ្រាវ និងកម្មវត្ថុ

បញ្ហានៃការស្រាវជ្រាវក្នុងសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) នៅកម្ពុជា គឺភាពខុសគ្នារវាង ក្របខ័ណ្ឌច្បាប់រដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិ ដែលធានាការពារសេរីភាពសាសនា និងបទពិសោធន៍ ជាក់ស្តែងរបស់សាសនាភាគតិច។ ទោះបីជាមានបទប្បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញដែលធានាសមភាពដល់សាសនាទាំងអស់ និងហាមឃាត់ការរើសអើងដោយផ្អែកលើសាសនា និងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងសន្ធិសញ្ញាអន្តរជាតិដែលគាំទ្រដល់ ស.ស.ជ ក្តី ក៏មានរបាយការណ៍ធំៗបង្ហាញពី ការរើសអើងការយាយី និងការរឹតបន្តឹងជាពិសេសប្រឆាំងនឹងគ្រិស្តសាសនា និងសាសនាឥស្លាម។

លើសពីនេះ ភាពលម្អៀងរបស់រដ្ឋាភិបាលទៅលើព្រះពុទ្ធសាសនាថេរវាទ ធ្វើឱ្យបញ្ហាទាំងនេះកាន់តែខ្លាំង ដែលបង្កឱ្យមានការប្រព្រឹត្តមកលើក្រុមសាសនាដទៃមិនស្មើភាពគ្នា និងដាក់កំហិតលើសិទ្ធិរបស់ពួកគេ ជាពិសេសជនជាតិដើមភាគតិច នៅក្នុងតំបន់ព្រៃ។ ការស្រាវជ្រាវនេះមានបំណងស្វែងយល់ និងចងក្រងភាពខុសគ្នាទាំងនេះពិនិត្យមើលការអនុវត្ត និងវិសាលភាពនៃការអនុវត្ត ស.ស.ជ នៅថ្នាក់ មូលដ្ឋាន និងការយល់ដឹងពីអន្តរកម្មសង្គម និងនយោបាយដែលជះឥទ្ធិពលលើសេរីភាពសាសនានៅកម្ពុជា។

ការស្រាវជ្រាវនេះសិក្សាស៊ីជម្រៅពីភាពស្មុគស្មាញនៃសេរីភាពសាសនា ឬជំនឿ (ស.ស.ជ)នៅកម្ពុជា។ ការស្រាវជ្រាវនឹងផ្តើមពិនិត្យមើលកម្មវត្ថុសំខាន់ៗប្រាំដូចខាងក្រោម៖

- **ពិនិត្យមើលទិដ្ឋភាពច្បាប់៖** វាយតម្លៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ ស.ស.ជ នៅកម្ពុជា។ ក្នុងទិដ្ឋភាពច្បាប់ គឺយើងស្វែងរកការគាំទ្រផ្លូវច្បាប់ដល់សេរីភាពសាសនា និងការរឹតបន្តឹងដែលកំពុងកើតមានណាមួយ។ លើសពីនេះ យើងស្វែងយល់ពីរបៀបដែលច្បាប់ទាំងនេះត្រូវបានអនុវត្តនៅថ្នាក់មូលដ្ឋាន។
- **ស.ស.ជ នៅក្នុងសហគមន៍៖** ស្វែងយល់ពីស្ថានភាព ស.ស.ជ នៅក្នុងសហគមន៍សាសនា និងជំនឿនានានៅក្នុងប្រទេសកម្ពុជា។
- **ការបំពានក្នុងសហគមន៍៖** ផ្តោតលើការស្វែងរក និងការពិពណ៌នាករណីស្តីពីការបំពានលើ ស.ស.ជ របស់សមាជិកក្នុងសហគមន៍សាសនា។
- **ទំនាក់ទំនងអន្តរជំនឿ៖** កំណត់សម្គាល់ និងពណ៌នាអំពីទំនាក់ទំនង និងអន្តរកម្មបច្ចុប្បន្ន រវាងសហគមន៍ជំនឿផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។
- **តួនាទីនៃការប្រតិបត្តិសាសនា៖** ផ្តោតលើការរួមចំណែកដ៏សំខាន់ និងការបំផុសគំនិតនៃការប្រតិបត្តិសាសនានៅក្នុងសហគមន៍កម្ពុជា។

ក្នុងការដោះស្រាយកម្មវត្ថុខាងលើ ការស្រាវជ្រាវនេះផ្តល់នូវការរួមចំណែកដ៏មានតម្លៃដល់កិច្ចពិភាក្សាដែលកំពុងជជែកគ្នាបន្តស្តីពីសេរីភាពសាសនា និងសិទ្ធិមនុស្សនៅកម្ពុជា។

យោងតាមបញ្ហាស្រាវជ្រាវ និងកម្មវត្ថុដូចបានរៀបរាប់ខាងលើ ការស្រាវជ្រាវនឹងដោះស្រាយចំណោទស្រាវជ្រាវធំៗមួយចំនួន។

ទាក់ទងនឹងទិដ្ឋភាពច្បាប់ ការសិក្សានឹងស្វែងរកមើលថាតើច្បាប់អនុញ្ញាតឱ្យមានសេរីភាពសាសនានិងជំនឿឬទេ ថាតើច្បាប់មានរឹតបន្តឹងសេរីភាពនេះចំពោះសាសនាជាក់លាក់ណាមួយដែរឬទេ ហើយថាតើមានការរឹតបន្តឹងផ្លូវច្បាប់លើការសម្តែងសាសនា

ឬជំនឿបែបណាមួយឬទេ។ តាមរយៈការពិនិត្យមើលការអនុវត្តច្បាប់នេះនៅថ្នាក់មូលដ្ឋាន យើងនឹងស្វែងយល់ថាតើច្បាប់ទាំងនេះអនុគ្រោះហួសហេតុដល់សាសនាណាមួយឬទេ តើសាសនាណាទទួលសិទ្ធិអនុញ្ញាតឱ្យចូលរួមក្នុងការធ្វើសកម្មភាពអ្វី តើមនុស្សអាចប្រមូលផ្តុំដើម្បីគោរពបូជា ពិភាក្សា និងបង្រៀនសាសនារបស់ខ្លួនដោយសេរីឬទេ ហើយតើពួកគេអាចជួល ឬទិញទីតាំងសម្រាប់ការជួបជុំគ្នាបានដោយមិនមានការឃាយឺដែរឬយ៉ាងណា។

យើងពិនិត្យមើលការអនុវត្ត ស.ស.ជ ផ្ទាល់ខ្លួនរបស់បុគ្គលនៅតាមសហគមន៍មូលដ្ឋាន និងស្វែងយល់ថាតើបុគ្គលម្នាក់ៗអាចជ្រើសរើស និងផ្លាស់ប្តូរសាសនារបស់ខ្លួនដោយសេរីឬទេ តើអាចបង្ហាញថាខ្លួនមិនមានជំនឿសាសនាណាមួយ ឬអាចប្រកាន់យកជំនឿដែលមិនមែនជាសាសនាដោយបើកចំហឬទេ ហើយតើការផ្លាស់ប្តូរ ឬបោះបង់សាសនាណាមួយ ត្រូវរងការពិន័យឬការរើសអើងដែរឬទេ។

ក្នុងការពិនិត្យមើលការអនុវត្ត ស.ស.ជ ក្នុងសហគមន៍ និងផលប៉ះពាល់នៃការអនុវត្តមកលើយេនឌ័រ និងទំនោរផ្លូវភេទ យើងនឹងពិនិត្យមើលថាតើស្ត្រីរងការរើសអើងដោយសារសាសនារបស់ខ្លួនឬទេ តើពួកគេទទួលបានសិទ្ធិដូចគ្នានឹងបុរសពាក់ព័ន្ធបញ្ហានានាដូចជាសិទ្ធិទទួលមរតក ឬសិទ្ធិលែងលះឬទេ ហើយតើបុគ្គលស្រលាញ់ភេទដូចគ្នាប្រឈមនឹងការរើសអើងដែលចាក់ឫសគល់នៅក្នុងជំនឿសាសនាដែរឬទេ។ ការស្រាវជ្រាវនឹងពិនិត្យមើលដែរដល់ការរឹតបន្តឹងផ្លូវសាសនាលើសិទ្ធិរំលូតកូន និងសេរីភាពសម្រេចចិត្តទាក់ទងនឹងរូបកាយរបស់បុគ្គលម្នាក់ៗ។

លើសពីនេះ ការសិក្សានេះនឹងស្វែងយល់អំពីទំនាក់ទំនងអន្តរជំនឿនិងសាសនា និងការអនុវត្ត ស.ស.ជ តាមការពិនិត្យមើលការអនុវត្តកិច្ចសន្ទនាអន្តរសាសនា ស្ថានភាពនៃការគោរពនិងភាពសុខដុមរមនា រវាងសាសនានានា និងការសិក្សាស្វែងយល់អំពីជំនឿ

និងការប្រតិបត្តិសាសនារបស់គ្នាទៅវិញទៅមក។ ចំណោទស្រាវជ្រាវទាំងនេះនឹងបង្ហាញផ្លូវសម្រាប់ការសិក្សាស្វែងយល់ ដែលនឹងផ្តល់ការយល់ដឹងសព្វជ្រុងជ្រោយអំពីស្ថានភាព ស.ស.ជ នៅកម្ពុជា។

ជាចុងក្រោយ ការស្រាវជ្រាវនេះនឹងសិក្សាពីការរួមចំណែកនៃការប្រតិបត្តិសាសនា និងគុណតម្លៃជាលក្ខណៈសង្គម។ យើងនឹងសង្កត់ធ្ងន់លើសារៈសំខាន់នៃការរួមចំណែកទាំងនោះ និងគូសបញ្ជាក់ពីភាពចាំបាច់នៃសេរីភាពសាសនា ឬជំនឿ។

## ៣.២. ការរចនាការស្រាវជ្រាវ

ការរចនាការស្រាវជ្រាវក្នុងការសិក្សានេះពិនិត្យផ្ទៀតផ្ទាត់រវាងវិស័យផ្សេងៗគ្នា ដើម្បីចាប់យកទិដ្ឋភាពជារួមនៃសេរីភាពសាសនានិងជំនឿ ( ស.ស.ជ ) នៅក្នុង សហគមន៍គោលដៅដោយតតព្រៀងទុក។ ជំហានដំបូងគឺពាក់ព័ន្ធនឹងការស្រាវជ្រាវសព្វជ្រុងជ្រោយលើឯកសារមានស្រាប់ ដែលជួយបង្ហាញផ្លូវដល់ដំណើរការស្រាវជ្រាវបន្តបន្ទាប់។ យើងបានប្រើគោលវិធីសាស្ត្របែបបរិយាបន្នក្នុងការយល់ដឹងអំពី ស.ស.ជ ក្នុងសហគមន៍ទាំងនោះ ដើម្បីធានាថាយើងទទួលបានប្រជាសាស្ត្រចម្រុះ។ យោងតាមបញ្ហារកឃើញក្នុងការស្ទង់មើលតាមរយៈប្រវត្តិសាស្ត្រ និងតាមរយៈការរំឭកទ្រឹស្តី ការចុះស្រាវជ្រាវក្នុងសហគមន៍គឺតម្រូវចាំបាច់ឱ្យមានគោលការអនុវត្តក្រមសីលធម៌។

### ៣.២.១. ការកំណត់សំណាកគំរូស្រាវជ្រាវ

បច្ចេកទេសសំណាកគំរូបែបចម្រុះត្រូវបានយកមកប្រើ ដើម្បីទទួលបានទិន្នន័យតំណាងពីក្រុមប្រជាសាស្ត្រផ្សេងៗគ្នាតាមសហគមន៍គោលដៅ។ ទំហំសំណាកគំរូ

សម្រាប់ការស្ទង់មតិត្រូវបានកំណត់ដោយផ្អែកតាមទំហំប្រជាជនក្នុងសហគមន៍នីមួយៗ ដោយធានាថាទិន្នន័យដែលប្រមូលបាននឹងឆ្លុះបញ្ចាំងពីប្រជាជនទូទៅ។

### ៣.២.២. ការអភិវឌ្ឍនកម្រងសំណួរ

កម្រងសំណួរត្រូវបានបង្កើតឡើងដោយផ្អែកតាមក្របខ័ណ្ឌគំរូសម្រាប់ការវាយតម្លៃ ស.ស.ជ ដោយមានការចូលរួមសហការពីអង្គការដៃគូ រួមមានអង្គការនារីដើម្បីសន្តិភាព អង្គការស្ពានសន្តិភាព អង្គការបន្ទការអប់រំ និងអង្គការដានមីសិន។ សំណួរត្រូវបានតាក់តែងឡើងដើម្បីវាយតម្លៃវិមាត្រផ្សេងៗរបស់ ស.ស.ជ រួមទាំងការការពារផ្លូវច្បាប់ តវិយាបថសង្គម ការអនុវត្តតាមស្ថាប័ន និងបទពិសោធន៍បុគ្គល។ កម្រងសំណួរដែលបានរៀបចំមានសំណួរបិទ និងសំណួរបើក ដែលជួយផ្តល់ព័ត៌មានលក្ខណៈបរិមាណវិស័យ និងគុណភាពវិស័យ។

### ៣.២.៣. ការធ្វើតេស្តសាកល្បង

មុនពេលចុះប្រមូលទិន្នន័យ យើងបានដាក់កម្រងសំណួរឆ្លងកាត់ការធ្វើតេស្តសាកល្បងជាមួយនឹងសំណាកគំរូតូចមួយ តាមសហគមន៍គោលដៅ និងបុគ្គលិក និងអ្នកស្ទង់មតិពីដៃគូផ្ទាល់។ ព័ត៌មានត្រឡប់បានពីការធ្វើតេស្តសាកល្បងនេះត្រូវបានយកប្រើដើម្បីកែលម្អកម្រងសំណួរ ដោយធានាថាកម្រងសំណួរមានភាពច្បាស់លាស់ មានភាពពាក់ព័ន្ធគ្នា និងមានការគិតគូរពីភាពរសើបខាងវប្បធម៌។ នេះគឺជាជំហានដ៏សំខាន់មួយក្នុងការបង្កើនភាពជឿជាក់ និងសុពលភាពនៃឧបករណ៍ស្ទង់មតិ។

### ៣.២.៤. ការប្រមូលទិន្នន័យ

អ្នកស្រាវជ្រាវសហគមន៍ និងក្រុមការងារស្រាវជ្រាវពីអង្គការដៃគូ និងពីក្រុមស្ម័គ្រចិត្ត។ ពួកគេចូលរួមពិនិត្យកម្រងសំណួរដោយផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិក អាស្រ័យទៅលើលទ្ធភាពនៃការធ្វើទំនាក់ទំនងដែលអាចធ្វើទៅបានជាមួយក្រុមអ្នកស្រាវជ្រាវសហគមន៍។ កិច្ចខិតខំត្រូវបានធ្វើឡើងដើម្បីធានាឱ្យមានការចូលរួមពីក្រុមចម្រុះនៅក្នុងសហគមន៍ ជាពិសេសផ្តោតលើស្ត្រី ក្រុមភាគតិច និងក្រុមដែលមិនសូវទទួលបានយកចិត្តទុកដាក់។ ការប្រមូលទិន្នន័យប្រព្រឹត្តិទៅក្នុងរយៈពេលជាក់លាក់មួយគឺ៦០ថ្ងៃ ដើម្បីរក្សាភាពស៊ីសង្វាក់គ្នា និងភាពជឿជាក់។

### ៣.២.៥. ការកំណត់កូដ ការវិភាគ និងការផ្ទៀងផ្ទាត់ទិន្នន័យ

#### ការវិភាគទិន្នន័យហ្មត់ចត់៖

ការស្ទង់មតិរបស់យើងចេញលទ្ធផលជាទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យ។ សម្រាប់ទិន្នន័យបែបបរិមាណវិស័យ យើងប្រើកម្មវិធីកុំព្យូទ័រដែលមានសមត្ថភាពវិភាគទិន្នន័យស្ថិតិទាំងបែបពិពណ៌នា និងបែបសន្និដ្ឋាន។ បន្ទាប់មកទិន្នន័យត្រូវបានសង្ខេប ហើយសន្និដ្ឋានជារួម។

សម្រាប់ទិន្នន័យបែបគុណវិស័យទទួលបានពីសំណួរបើក យើងបានធ្វើការវិភាគតាមប្រធានបទ។ វិធីសាស្ត្រនេះបានជួយយើងកំណត់រកបាននូវទម្រង់ទិន្នន័យដែលកើតឡើងញឹកញាប់ ប្រធានបទ និងព័ត៌មានសំខាន់ៗចេញពីពាក្យសម្តីរបស់អ្នកចូលរួមផ្តល់ព័ត៌មាន។

### ការវិភាគប្រៀបធៀប និងការផ្ទៀងផ្ទាត់៖

យើងបង្កើនការវិភាគបន្ថែមទៀតតាមការប្រៀបធៀបរបកគំហើញនៅតាមក្រុមប្រជាសាស្ត្រ និងសហគមន៍ផ្សេងៗគ្នា។ ការវិភាគបានជួយឱ្យយើងកំណត់រកឃើញភាពខុសគ្នា និងនិន្នាការដែលអាចកើតមាននៅក្នុងទិន្នន័យ។

ដើម្បីធានាថាការវិភាគរបស់យើងត្រឹមត្រូវ និងពេញលេញ យើងបានបង្ហាញរបកគំហើញបឋមទៅកាន់អ្នកស្រាវជ្រាវសហគមន៍ និងអ្នកតំណាងអង្គការដៃគូ តាមរយៈសិក្ខាសាលាផ្ទៀងផ្ទាត់ទិន្នន័យល្អិតល្អន់។ យើងបានដាក់បញ្ចូលមតិតបរបស់ពួកគេទាំងផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរទៅក្នុងការវិភាគចុងក្រោយ ដើម្បីធានាថារបកគំហើញរបស់យើងមានភាពត្រឹមត្រូវ។

## ៣.២.៦. ការបកស្រាយប្រធានបទ និងការរាយការណ៍

លទ្ធផលស្រាវជ្រាវត្រូវបានបកស្រាយក្នុងក្របខ័ណ្ឌសិក្សា សម្រាប់ការវាយតម្លៃ ស.ស.ជ និងទស្សនៈទ្រឹស្តីពាក់ព័ន្ធ។ របាយការណ៍នេះផ្តល់នូវការវិភាគសព្វជ្រុងជ្រោយអំពីស្ថានភាព ស.ស.ជ នៅសហគមន៍គោលដៅ តាមរយៈការបង្ហាញពីចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចកែលម្អ។ បន្ទាប់មក អនុសាសន៍នានាត្រូវបានផ្តល់ ដើម្បីជាព័ត៌មានសម្រាប់ការពិចារណាផ្នែកគោលនយោបាយ ការងារជំរុញនិងលើកកម្ពស់ ស.ស.ជ និងគំនិតផ្តួចផ្តើមកម្មវិធីនានាដោយអង្គការដៃគូ។ វិធីសាស្ត្រនេះមានបំណងផ្តល់ការយល់ដឹងស៊ីជម្រៅបែបសកម្មភាព ដើម្បីគាំទ្រដល់ ស.ស.ជ នៅក្នុងសហគមន៍គោលដៅ។

ជំហានដំបូងទាក់ទងនឹងការផ្សាំខ្លួនយើងជាមួយនឹងទិន្នន័យសិន។ នេះមានន័យថា យើងចម្លងខ្សែអាត់សំឡេងនៃបទសម្ភាសទៅជាអត្ថបទសំណេរ ហើយបន្ទាប់មកពិនិត្យមើលខ្លឹមសារទាំងអស់។ ក្នុងដំណាក់កាលដំបូងនេះ យើងចាប់ផ្ដើមស្គាល់ប្រធានបទសំខាន់ៗ និងដាក់កូដសម្គាល់។

ឧទាហរណ៍ យើងបានស្វែងរកមើលការលើកឡើងអំពីក្រុមសាសនាជាក់លាក់ (គ្រិស្តសាសនិក អ្នកកាន់សាសនាឥស្លាម ពុទ្ធសាសនិក) និងការរៀបរាប់បង្ហាញពីបទពិសោធន៍នៃការរើសអើង ឬការទទួលស្គាល់ ទាក់ទងនឹងក្រុមទាំងនោះពីអ្នកចូលរួមផ្តល់ព័ត៌មាន។ ដំណើរការដាក់កូដសម្គាល់ដំបូងនេះបង្កើតឡើងដោយសហការជាមួយអ្នកស្រាវជ្រាវសហគមន៍ និងក្រុមការងារស្រាវជ្រាវ។ ការពិគ្រោះយោបល់ជាមួយគ្នានេះធានាថា ការសម្រេចចិត្តដាក់កូដរបស់យើងមានលក្ខណៈជាប្រព័ន្ធ មានតម្លាភាព និងសមហេតុផលល្អ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការវិភាគដ៏រឹងមាំ។

បន្ទាប់មក យើងផ្ដោតទៅលើការកំណត់រកទម្រង់ព័ត៌មានឬប្រធានបទ ជាមួយនឹងកូដសម្គាល់ដំបូង។ ពេលការយល់ដឹងរបស់យើងលើទិន្នន័យបានវិវត្ត យើងចាប់ផ្ដើមឃើញមានប្រធានបទ ដូចជា “បក្ខានុគ្រោះរបស់រដ្ឋាភិបាល” “ការរើសអើងសាសនា” និង *“ភាពសុខដុមរមនាក្នុងសហគមន៍”* ។ ប្រធានបទរាយរងក៏ត្រូវបានកំណត់ផងដែរ ដូចជាករណីជាក់លាក់នៃការឃាឃី ដែលស្ថិតនៅក្រោមប្រធានបទធំ *“ការរើសអើងសាសនា”*។ ឧទាហរណ៍ ក្នុងដំណាក់កាលនេះ យើងបានកត់សម្គាល់ឃើញមានទម្រង់នៃការឃាឃី ដែលរាយការណ៍ពីសហគមន៍ឥស្លាមទាក់ទងនឹងការរឹតបន្តឹងលើការប្រតិបត្តិសាសនារបស់ខ្លួន។ កូដសម្គាល់នានាត្រូវបានចងជាក្រុម និងបកស្រាយដើម្បីបង្កើតចេញជាប្រធានបទ សម្រាប់ជំនួយដល់ភាពស៊ីសង្វាក់គ្នា និងជម្រៅនៃការវិភាគ។

នៅពេលប្រធានបទដំបូងៗត្រូវបានរកឃើញហើយ ប្រធានបទទាំងនោះត្រូវបាន យកមកពិនិត្យ និងកែសម្រួល។ ចំណុចនេះមានការពិនិត្យមើលថា ប្រធានបទនិងទិន្នន័យមានលក្ខណៈស៊ីចង្វាក់គ្នា និងធានាថាមិនមានការមើលរំលងប្រធានបទធំៗណាមួយឡើយ។ ជាឧទាហរណ៍ ប្រធានបទដូចជា *"ការបំផ្លិចបំផ្លាញទីសក្ការៈរបស់ជនជាតិដើមភាគតិច"* ត្រូវបានផ្ទៀងផ្ទាត់ដោយមានឧទាហរណ៍ជាក់លាក់នៅក្នុងទិន្នន័យដូចជាការរាយការណ៍អំពីសម្បទានព្រៃឈើ ដែលក្រុមហ៊ុនឯកជនធ្វើអាជីវកម្មជាដើម។ នៅពេលប្រធានបទលេចឡើងទូលាយពេក យើងធ្វើការចាត់ថ្នាក់បន្ថែមទៀតដើម្បីឱ្យការវិភាគកាន់តែច្បាស់លាស់។ យើងបង្កើតមូលដ្ឋានទិន្នន័យក្នុងកម្មវិធី Excel ជាទីរក្សាទុកឯកសារភស្តុតាងជំនួយដល់ប្រធានបទនីមួយៗ និងភាពពាក់ព័ន្ធនៃភស្តុតាងទាំងនោះទៅនឹងសំណួរស្រាវជ្រាវ ដោយធានាថាទិន្នន័យមានភាពហ្មត់ចត់ និងត្រឹមត្រូវ។

ជាចុងក្រោយ ប្រធានបទនីមួយៗត្រូវបានកំណត់យ៉ាងច្បាស់ និងដាក់ឈ្មោះឱ្យសមស្របទៅនឹងខ្លឹមសារ។ ចំណុចនេះពាក់ព័ន្ធនឹងការពិពណ៌នាលម្អិតនៃប្រធានបទនីមួយៗ ដោយលៃយ៉ាងណាឱ្យការពិពណ៌នានោះត្រូវគ្នាទៅនឹងបំណង និងចំណោទនៃការស្រាវជ្រាវ។ ជាឧទាហរណ៍ ប្រធានបទ *"បក្ខានុគ្រោះរបស់រដ្ឋាភិបាល"* ត្រូវបានកែសម្រួលទៅជា *"បក្ខានុគ្រោះចំពោះពុទ្ធសាសនាថេរវាទ"* ដើម្បីឱ្យស៊ីគ្នាទៅនឹងលក្ខណៈជាក់លាក់នៃទិន្នន័យដែលបានវិភាគ។ ប្រធានបទដែលបានកំណត់ឃើញត្រូវបានបង្ហាញដល់អ្នកដែលបានចុះប្រមូលទិន្នន័យក្នុងសហគមន៍ តាមរយៈសិក្ខាសាលារយៈពេលកន្លះថ្ងៃ។ ក្នុងនោះមតិតបរបស់ពួកគេត្រូវបានដាក់បញ្ចូល ការកែសម្រួលចាំបាច់មួយចំនួនត្រូវបានធ្វើឡើង ដែលជួយឱ្យការវិភាគតាមប្រធានបទមួយៗមានលក្ខណៈគ្រប់គ្រាន់ និងមានការផ្ទៀងផ្ទាត់គ្រប់ជំហាន។

តាមរយៈជំហានជាប់ៗគ្នាយ៉ាងល្អិតល្អន់ទាំងនេះ ការវិភាគប្រធានបទផ្តល់ការរៀបចំ និងបកស្រាយទិន្នន័យជាប្រព័ន្ធ ដោយផ្តល់ការយល់ដឹងស៊ីជម្រៅប្រកបដោយអត្ថន័យ ស្តីពីស្ថានភាពសេរីភាពសាសនានៅកម្ពុជា។

# ៣.៣. ដែនកំណត់ក្នុងការស្រាវជ្រាវ

ទោះបីជាមានវិធីសាស្ត្រហ្មត់ចត់ប្រើក្នុងការសិក្សានេះក៏ដោយ យើងបានជួបប្រទះដែនកំណត់ជាច្រើនក្នុងអំឡុងពេលស្ទង់មតិនៅសហគមន៍គោលដៅ។ ដែនកំណត់ទាំងនេះបានជះឥទ្ធិពលលើភាពជឿជាក់បាន និងសុពលភាពជារួមនៃលទ្ធផលស្រាវជ្រាវស្តីពីសេរីភាពសាសនា និងជំនឿ (ស.ស.ជ) នៅប្រទេសកម្ពុជា។ បញ្ហាធំៗរួមមានភាពលម្អៀងនៃសំណាកគំរូ ភាពលម្អៀងតាមទំនោរសង្គម ភាពរសើបនយោបាយនៃប្រធានបទស្រាវជ្រាវ ការពឹងផ្អែកលើទិន្នន័យស្វ័យរាយការណ៍ និងកត្តាបរិបទផ្សេងៗ។ ដែនកំណត់ទាំងនេះមានរៀបរាប់លម្អិតនៅខាងក្រោម ដើម្បីផ្តល់នូវការយល់ដឹងទូលំទូលាយអំពីបញ្ហាប្រឈមដែលបានជួប និងឥទ្ធិពលដែលអាចកើតមានរបស់ដែនកំណត់មកលើលទ្ធផលស្រាវជ្រាវ។

## ៣.៣.១. ភាពលម្អៀងនៃសំណាកគំរូ

ទោះបីមានការខិតខំប្រើយុទ្ធសាស្ត្រសំណាកគំរូតំណាងក៏ដោយ ភាពលម្អៀងនៃសំណាកគំរូ នៅតែអាចកើតមាន ដោយសារកត្តាដូចជាការមិនឆ្លើយតប ឬភាព តំណាងតិចតួចនៃក្រុមប្រជាសាស្ត្រមួយចំនួន។ ស្ថានការណ៍នេះរឹតតែស្មុគស្មាញថែម ព្រោះការបញ្ចប់ការស្ទង់មតិមានចំនួន១៣៥ធៀបនឹងគោលដៅចំនួន២៨០ ហើយការបាត់បង់ការស្ទង់មតិពេញលេញចំនួន១៥ និងម៉ាស៊ីនថតសម្លេងមួយនៅកណ្តាលទី។ កិច្ចខិតខំស្វែងរកកម្រង

សំណួរស្ទង់មតិដែលមានផ្នែកទិន្នន័យ និងឧបករណ៍ថតសំឡេងដែលបាត់បង់គឺមិនទទួលបានជោគជ័យ ជាហេតុបង្កឱ្យប៉ះពាល់ដល់សំណុំទិន្នន័យទាំងមូល។

### ៣.៣.២. ការលម្អៀងតាមទំនោរសង្គម

អ្នកចូលរួមផ្តល់ព័ត៌មានដែលមានការភ័យខ្លាចចំពោះផលវិបាកដែលអាចមានបានផ្តល់ចម្លើយស្របតាមអ្វីដែលសង្គមចង់បាន ឬស្របតាមគោលការណ៍ច្បាប់ ជាហេតុនាំឱ្យមានការប៉ាន់ប្រមាណលើសពីស្ថានភាពជាក់ស្តែងនៃ ស.ស.ជ។ អ្នកចូលរួមផ្តល់ព័ត៌មានមានការស្ទាក់ស្ទើរខ្លះក្នុងការបង្ហាញព័ត៌មានរសើប ដែលការណ៍នេះអាចបង្កភាពលម្អៀងដល់របកគំហើញ។ ភាពលម្អៀងនេះឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងការទទួលបានចម្លើយត្រឹមត្រូវ និងច្បាស់លាស់អំពីបញ្ហារសើប។

### ៣.៣.៣. ទិន្នន័យស្វ័យរាយការណ៍ និងឥទ្ធិពលតាមបរិបទ

ទិន្នន័យស្វ័យរាយការណ៍បានមកពីសហគមន៍គោលដៅ ដែលទទួលបានការយល់ដឹងអំពីភាពរសើបនៃបញ្ហាទាក់ទងនឹង *"សិទ្ធ"* តាមរយៈអង្គការដៃគូដែលបានធ្វើការជាមួយសហគមន៍ទាំងនេះរាប់ឆ្នាំមកហើយ។ ភាពរសើបនេះអាចជះឥទ្ធិពលដល់ចម្លើយដែលបង្កជាភាពលម្អៀង។ លើសពីនេះ ភាពត្រឹមត្រូវនៃចម្លើយ អាចរងផលប៉ះពាល់ពីការភ័ន្តច្រឡំឬការចងចាំស្រពេចស្រពិល ភាពលម្អៀងនៃការបកស្រាយសំណួរ ឬការយល់ទៅលើសំណួរស្ទង់មតិមិនបានត្រឹមត្រូវ។ បរិបទទំនាក់ទំនងឥទ្ធិពលសង្គម នយោបាយ និងវប្បធម៌នៅក្នុងសហគមន៍គោលដៅ អាចជះឥទ្ធិពបន្ថែមទៀតដល់ការបកស្រាយលទ្ធផលស្រាវជ្រាវ និងបន្តប៉ះពាល់ដល់ការសន្និដ្ឋានរួមនៃលទ្ធផលទាំងនេះ។

## ៣.៤. ការពិចារណាអំពីក្រមសីលធម៌នៅក្នុងការចុះស្រាវជ្រាវក្នុងសហគមន៍

ការអនុវត្តការស្រាវជ្រាវលើស្ថានភាពសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) នៅក្នុងសហគមន៍គោលដៅក្នុងប្រទេសកម្ពុជា ទាមទារឱ្យមានក្របខ័ណ្ឌក្រមសីលធម៌រឹងមាំមួយដើម្បីធានាថាដំណើរការស្រាវជ្រាវមានភាពសុច្ចរិត និងសេចក្តីគោរព។ ដោយមើលឃើញទិដ្ឋភាពប្រវត្តិសាស្ត្រ និងសាសនាដ៏ស្មុគស្មាញរបស់កម្ពុជា ការស្រាវជ្រាវចាំបាច់ត្រូវគិតដល់ភាពរសើប និងយកចិត្តទុកដាក់ពីផលប៉ះពាល់។ ក្រមសីលធម៌ចាំបាច់ត្រូវគិតគូរដើម្បីរក្សាការពារសិទ្ធិ និងសុខុមាលភាពរបស់អ្នកចូលរួមផ្តល់ព័ត៌មាន ធានាភាពត្រឹមត្រូវ និងភាពជឿជាក់នៃទិន្នន័យប្រមូលបាន និងកសាងទំនុកចិត្តរវាងអ្នកស្រាវជ្រាវ និងសហគមន៍ពាក់ព័ន្ធ។ ការពិចារណាទាំងនេះរួមមានការទទួលបានការយល់ព្រមជាមុន ការរក្សាភាពអនាមិក និងភាពសម្ងាត់ ការគោរពភាពខុសគ្នានៃវប្បធម៌ និងការដោះស្រាយតទ្ធិពលនៃអំណាច និងការលម្អៀងតាមទំនោរសង្គម។ តាមរយៈការរួមបញ្ចូលគោលការណ៍ក្រមសីលធម៌ទាំងនេះ អ្នកស្រាវជ្រាវអាចចុះធ្វើការសិក្សាស្រាវជ្រាវដែលផ្តល់នូវការយល់ដឹងស៊ីជម្រៅដ៏មានអត្ថន័យ និងលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់អ្នកចូលរួមផ្តល់ព័ត៌មានទាំងអស់។

### ៣.៤.១. ការព្រមព្រៀង

អ្នកចូលរួមផ្តល់ព័ត៌មានទាំងអស់ត្រូវផ្តល់ការព្រមព្រៀងរបស់ខ្លួនជាមុន។ មុននឹងទទួលការព្រមព្រៀងពីពួកគេ អ្នកស្រាវជ្រាវបានធ្វើការពន្យល់ច្បាស់អំពីបំណងនៃការស្ទង់មតិ លក្ខណៈនៃសំណួរ និងរបៀបដែលយើងប្រប្រាស់ទិន្នន័យដែលប្រមូលបាន។ ក្រុមការងារស្រាវជ្រាវបានជូនដំណឹងអំពីសិទ្ធិរបស់ពួកគេក្នុងការដកខ្លួនចេញពីការសិក្សានៅពេលណាក៏បានដោយសេរី ហើយមិនតម្រូវឱ្យផ្តល់ហេតុផលអ្វីឡើយ។ រឿងសំខាន់គឺត្រូវធានាថាអ្នកចូលរួមយល់ច្បាស់អំពីអត្ថន័យនិងផលនៃការចូលរួមរបស់ពួកគេ។

## ៣.៤.២. ភាពរសើបនៃវប្បធម៌

វិធីសាស្រ្តស្ទង់មតិមានការគិតគូរពីភាពរសើបនៃវប្បធម៌ ដើម្បីបង្កលក្ខណៈសមស្របជាមួយការប្រតិបត្តិសាសនា និងវប្បធម៌របស់អ្នកចូលរួមផ្តល់ព័ត៌មាន។ ការងារនេះពាក់ព័ន្ធនឹងការរចនាសំណួរដែលគិតគូរដល់ជំនឿ និងការប្រតិបត្តិសាសនាផ្សេងៗ។ អ្នកសម្របសម្រួលការស្ទង់មតិបានទទួលការបណ្តុះបណ្តាលដើម្បីសិក្សាពីប្រធានបទបែបរសើប ជៀសវាងភាសា ឬឥរិយាបថដែលអាចគិតថាជាការមិនគោរព ឬការរំខាន។ ការទទួលស្គាល់ និងទទួលយកភាពខុសគ្នានៃវប្បធម៌ គឺមានសារៈសំខាន់ក្នុងការទទួលបានទំនុកចិត្តពីអ្នកចូលរួមផ្តល់ព័ត៌មាន និងធានាថាចម្លើយដែលទទួលបាន មានភាពត្រឹមត្រូវ និងស្មោះត្រង់។

## ៣.៤.៣. ភាពអនាមិក និងការសម្ងាត់

ការរក្សាភាពអនាមិក និងការសម្ងាត់របស់អ្នកចូលរួមផ្តល់ព័ត៌មានជារឿងសំខាន់បំផុត។ អ្នកស្រាវជ្រាវមានវិធានការដើម្បីការពារអត្តសញ្ញាណរបស់អ្នកចូលរួម ដូចជាការមិនបញ្ចេញឈ្មោះ ឬអត្តសញ្ញាណណាមួយរបស់អ្នកផ្តល់ចម្លើយ និងការរក្សាទុកទិន្នន័យដោយសុវត្ថិភាព។ អ្នកចូលរួមទទួលបានការធានាថាព័ត៌មានផ្ទាល់ខ្លួនត្រូវបានរក្សាការសម្ងាត់ ហើយចម្លើយដែលត្រូវបានប្រើនឹងមិនមានបន្សល់ដានដែលអាចត្រូវបានប្រើដើម្បីស្វែងរកម្ចាស់ចម្លើយឡើយ។ ចំណុចនេះមានសារៈសំខាន់ជាពិសេសនៅពេលអ្នកចូលរួមអាចមានការបារម្ភពីផលប៉ះពាល់ក្រោយការបង្ហាញទស្សនៈផ្ទាល់ខ្លួនលើប្រធានបទដែលមានលក្ខណៈរសើប។

### ៣.៤.៤. ការដោះស្រាយទំនាក់ទំនងឥទ្ធិពលនៃអំណាច

បរិបទប្រវត្តិសាស្ត្រកម្ពុជាធ្លាប់ជួបប្រទះពេលចលាចលនយោបាយ និងការគាបសង្កត់ដែលអាចជះឥទ្ធិពលដល់របៀបយល់ឃើញរបស់បុគ្គលទូទៅលើអំណាច និងទំនាក់ទំនងឥទ្ធិពលនៃអំណាច។ វិធីសាស្ត្រស្ទង់មតិឆ្លើយតបបញ្ហាឥទ្ធិពលនៃអំណាចនេះដោយធានាថាអ្នកចូលរួមមិនមានការបង្ខិតបង្ខំ ឬរងសម្ពាធដើម្បីផ្តល់ចម្លើយណាមួយ។ ចំណុចនេះសំខាន់ជាពិសេសនៅពេលធ្វើសម្ភាសបែបក្រុមពិភាក្សា ព្រោះសម្ពាធពីមិត្តរួមក្រុមអាចជះឥទ្ធិពលលើចម្លើយរបស់អ្នកចូលរួមម្នាក់ៗ។ ការបង្កើតបរិយាកាសសុវត្ថិភាព និងគាំទ្រដល់អ្នកចូលរួមផ្តល់ព័ត៌មាន ដើម្បីចែករំលែកមតិដោយស្មោះត្រង់គឺចាំបាច់ណាស់ដើម្បីឱ្យទិន្នន័យប្រមូលបាន មានភាពត្រឹមត្រូវ។

### ៣.៤.៥. បរិយាបន្នភាព និងភាពតំណាង

វិធីសាស្ត្រស្ទង់មតិដែលមានគោលការណ៍ក្រមសីលធម៌តម្រូវឱ្យមាន ដើម្បីធានាបាននូវបរិយាបន្នភាព និងភាពតំណាងនៃក្រុមប្រជាសាស្ត្រទាំងអស់។ យោងតាមវិសមាមាត្រនៅក្នុងសំណាកគំរូ គួរមានការយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមតំណាងតិច ដូចជាស្ត្រី ជនជាតិភាគតិច ឬសាសនាភាគតិច។ ការណ៍នេះពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមគោលដៅ និងការគាំទ្របន្ថែម ដើម្បីជួយសម្រួលក្រុមទាំងនេះឱ្យចូលរួម។ ការធានាឱ្យមានតំណាងចម្រុះជួយផ្តល់នូវការយល់ដឹងសព្វជ្រុងជ្រោយអំពីបញ្ហា ស.ស.ជ និងជៀសវាងការមិនរាប់បញ្ចូលក្រុមជាក់លាក់ណាមួយ។

### ៣.៤.៦.កាត់បន្ថយភាពលម្អៀងតាមទំនោរសង្គម

ភាពលម្អៀងតាមទំនោរសង្គម គឺនៅពេលអ្នកចូលរួមផ្តល់ព័ត៌មានផ្តល់ចម្លើយដែលពួកគេជឿថាសង្គមអាចទទួលយកបានជាជាងតាមជំនឿពិតរបស់ពួកគេ។ នេះគឺជាកង្វល់ដ៏ធំមួយដែលពាក់ព័ន្ធនឹងក្រមសីលធម៌នៃការស្រាវជ្រាវ។ ដើម្បីកាត់បន្ថយបញ្ហានេះ វិធីសាស្ត្រស្ទង់មតិបានរួមបញ្ចូលភាពអនាមិក ការផ្តល់បរិយាកាសគ្មានការវិនិច្ឆ័យ និងការប្រើប្រាស់បច្ចេកទេសសួរដោយប្រយោល។ ការបណ្តុះបណ្តាលអ្នកសម្របសម្រួលនិងអ្នកធ្វើការស្ទង់មតិឱ្យស្គាល់ និងដោះស្រាយសញ្ញាមិនស្រួល ឬស្ទាក់ស្ទើរ ជួយឱ្យទទួលបានចម្លើយកាន់តែសុក្រឹត។

### ៣.៤.៧. ព័ត៌មានត្រឡប់ និងទំនួលខុសត្រូវ

ការអនុវត្តការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ រួមមានការផ្តល់មតិត្រឡប់ដល់សហគមន៍ដែលពាក់ព័ន្ធនឹងការស្ទង់មតិ។ អ្នកចូលរួមគួរទទួលបានដំណឹងអំពីរបកគំហើញ និងរបៀបប្រើប្រាស់មតិរួមចំណែករបស់ពួកគេ។ ការណ៍នេះអាចប្រព្រឹត្តទៅបាន តាមរយៈការប្រជុំសហគមន៍ របាយការណ៍ ឬសេចក្តីសង្ខេបស្រាវជ្រាវដែលប្រើប្រាស់បាន។ ការរក្សាទំនួលខុសត្រូវដល់អ្នកចូលរួមគឺជាការគោរពដល់មតិរួមចំណែករបស់ពួកគេ ហើយជំរុញឱ្យមានទំនុកចិត្ត និងតម្លាភាពក្នុងដំណើរការស្រាវជ្រាវ។

ការរួមបញ្ចូលធាតុក្រមសីលធម៌ទាំងនេះទៅក្នុងវិធីសាស្ត្រស្ទង់មតិគឺមានសារៈសំខាន់សម្រាប់ធ្វើការស្រាវជ្រាវអំពី ស.ស.ជ នៅកម្ពុជា ប្រកបដោយការគោរព បរិយាបន្ន និងគួរឱ្យទុកចិត្ត។ ការដោះបញ្ហាទិដ្ឋភាពទាំងនេះគឺជាការការពារអ្នកចូលរួម បង្កើនគុណភាពទិន្នន័យ និងធានាថារបកគំហើញក្រោយស្រាវជ្រាវមានភាពជឿជាក់ និងមានក្រមសីលធម៌។



# ៤.

# ការវិភាគទិន្នន័យ

# ៤.១. ទិន្នន័យប្រជាសាស្រ្ត

ទិន្នន័យប្រជាសាស្រ្តប្រមូលបានពីអ្នកចូលរួមផ្តល់ព័ត៌មានតាមការស្ទង់មតិ បានរំលេចចេញទិដ្ឋភាពលម្អិតអំពីលក្ខណៈចម្រុះនៅក្នុងសហគមន៍គោលដៅក្នុងប្រទេសកម្ពុជា។ ព័ត៌មាននេះមានសារៈសំខាន់ក្នុងការយល់ដឹងពីទស្សនៈ និងបទពិសោធន៍ខុសៗគ្នាអំពីសេរីភាពសាសនា និងជំនឿ (ស.ស.ជ) និងធានាថារបកគំហើញក្នុងការសិក្សាគឺមានលក្ខណៈសព្វជ្រុងជ្រោយ និងលក្ខណៈតំណាងជាទូទៅ។

## ៤.១.១. យេនឌ័រ

របាយយេនឌ័រនៅក្នុងគំរូបង្ហាញថាភាគច្រើននៃអ្នកចូលរួមផ្តល់ព័ត៌មានជាបុរស ក្នុងនោះបុរសមាន៨២នាក់ ធៀបនឹង៤៤នាក់ជាស្ត្រី។ តំណាងយេនឌ័រនេះបង្ហាញពីការចូលរួមទាំងបុរស និងស្ត្រីក្នុងការស្ទង់មតិ ដែលអនុញ្ញាតឱ្យមានការវិភាគប្រកបដោយតុល្យភាពអំពីបញ្ហា ស.ស.ជ ពីទស្សនៈតំណាងក្រុមទាំងពីរ។

## ៤.១.២. ជាតិពន្ធុ

សមាសភាពជាតិពន្ធុក្នុងសំណាកគំរូបង្ហាញពីភាពចម្រុះច្រើន។ ភាគច្រើននៃអ្នកចូលរួមផ្តល់ព័ត៌មានមានខ្មែរ (៧៥នាក់) បន្ទាប់មកជនជាតិដើមភាគតិច (៣៣នាក់) និងជនជាតិចាម/ខ្មែរឥស្លាម(១៨នាក់)។ ភាពចម្រុះជាតិសាសន៍នេះគឺមានសារៈសំខាន់សម្រាប់ដកស្រង់បទពិសោធន៍ពីក្រុមជនជាតិផ្សេងៗគ្នា និងការយល់ដឹងថាតើបញ្ហា ស.ស.ជ ប្រែប្រួលបែបណានៅក្នុងសហគមន៍ទាំងនេះ។

### ៤.១.៣. សាសនា

មានអត្តសញ្ញាណសាសនាផ្សេងៗគ្នាច្រើនក្នុងចំណោមអ្នកចូលរួមផ្តល់ព័ត៌មាន ដែលបង្ហាញពីភាពចម្រុះសាសនានៅក្នុងសហគមន៍គោលដៅ។ ក្រុមអ្នកចូលរួមផ្តល់ព័ត៌មានភាគច្រើនគឺពុទ្ធសាសនិក(៥៦នាក់) បន្ទាប់មកគឺគ្រិស្តបរិស័ទ(៣៧នាក់)។ បន្ថែមពីលើនេះ មានអ្នកកាន់ សាសនាឥស្លាមចំនួន១៨នាក់ អ្នកកាន់ជំនឿជនជាតិដើមភាគតិច១៤នាក់ និងអ្នកកាន់ជំនឿបាហៃ១នាក់។ ភាពចម្រុះខាងសាសនានេះធានាថាការសិក្សាមានសមាសភាពផ្សំខុសៗគ្នាច្រើនត្រង់បទពិសោធន៍ និងទស្សនៈសាសនា។

### ៤.១.៤. មុខរបរ

របាយមុខរបរ/តួនាទីរបស់អ្នកចូលរួមផ្តល់ព័ត៌មានបង្ហាញថាមុខរបរចិញ្ចឹមជីវិតមានលក្ខណៈផ្សេងៗពីគ្នា។ ភាគច្រើនជាកសិករ(៨៧នាក់) ដែលនេះបញ្ជាក់ថាសហគមន៍គោលដៅនៃការស្ទង់មតិមានជីវិភាពទូទៅជាកសិកម្ម។ មុខរបរ/តួនាទីផ្សេងទៀតរួមមានសិស្ស(៧នាក់) គ្រូបង្រៀន(៧នាក់) អ្នកដឹកនាំសាសនា ឬអ្នកប្រតិបត្តិសាសនា(៨នាក់) និងមន្ត្រីរាជការ(៤នាក់)។ លើសពីនេះ អ្នកចូលរួមផ្តល់ព័ត៌មានចំនួន១៣នាក់ចូលក្នុងចំណាត់ថ្នាក់មុខរបរ/តួនាទីផ្សេងៗ រួមមានអ្នកលក់ មន្ត្រីរដ្ឋបាល សង្ឃរាជ និងអាចារ្យ។ ភាពខុសគ្នានៃមុខរបរ/តួនាទីនេះរំលេចពីការយល់ដឹងស៊ីជម្រៅថាតើតួនាទីវិជ្ជាជីវៈ និងស្ថានភាពសេដ្ឋកិច្ចសង្គមខុសៗគ្នាផ្សារភ្ជាប់គ្នានឹងបទពិសោធន៍ ស.ស.ជ បែបណា។

សរុបមក ទិន្នន័យប្រជាសាស្ត្របានពីសំណាកគំរូនៃអ្នកផ្តល់ព័ត៌មាន បង្ហាញពីភាពចម្រុះនៃយេនឌ័រ ជាតិពន្ធុ សាសនា និងភាពចម្រុះនៃមុខរបរ/តួនាទី។ ភាពជាតំណាងសព្វជ្រុងជ្រោយនេះគឺជាមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវ ដែលធានាថាការវិភាគ

លើ ស.ស.ជ នៅកម្ពុជារំលេចពីបទពិសោធន៍ និងទស្សនៈផ្សេងៗគ្នានៅក្នុងសហគមន៍គោលដៅ។

# ៤.២. ភាពលម្អៀងនៃសំណាកគំរូប្រជាសាស្ត្រ

របាយប្រជាសាស្ត្រក្នុងសំណាកគំរូស្ទង់មតិ បានបង្ហាញជាថ្មីយ៉ាងច្បាស់នូវដែនកំណត់ខ្លះៗ ធៀបទៅនឹងប្រជាសាស្ត្រទាំងមូលនៃប្រទេសកម្ពុជា ដែលនេះប៉ះពាល់ដល់លទ្ធភាពក្នុងការទាញយកសេចក្តីសន្និដ្ឋានទូទៅ និងភាពជាតំណាងត្រឹមត្រូវ នៃលទ្ធផលស្រាវជ្រាវស្តីពីសេរីភាពសាសនា និងជំនឿ (ស.ស.ជ) នៅក្នុងប្រទេស។

## ៤.២.១. វិសមមាត្រយេនឌ័រ

សំណាកគំរូបង្ហាញពីវិសមាមាត្រយេនឌ័រខ្ពស់ ក្នុងនោះចំនួនបុរសមានច្រើន(៨២នាក់) ធៀបនឹងស្ត្រី(៤៤នាក់)។ ក្នុងចំណោមប្រជាជនកម្ពុជាទូទៅ អាត្រាយេនឌ័រមានតុល្យភាពជាងនេះ។ តំណាងលើសលុបនៃចំនួនបុរសនេះ អាចបំភ័ន្តដល់របកគំហើញ ព្រោះមិនបានដកបទពិសោធន៍ និងទស្សនៈរបស់ស្ត្រីទាក់ទងនឹងបញ្ហា ស.ស.ជ ស្មើគ្នានឹងបុរស។ បទពិសោធន៍របស់ស្ត្រី ដែលអាចមានភាពខុសប្លែកគ្នាខ្លាំងពីបុរស អាចនឹងត្រូវបានបង្ហាញតិចតួច ជាហេតុបង្កឱ្យការយល់ដឹងស៊ីជម្រៅអំពីទិដ្ឋភាពនៃ ស.ស.ជ មិនមានលក្ខណៈពេញលេញ។

### ៤.២.២. ភាពតំណាងជាតិពន្ធុ

សមាសភាពជាតិពន្ធុក្នុងសំណាកគំរូក៏បង្ហាញពីដែនកំណត់ផងដែរ។ នៅក្នុងសំណាកគំរូឃើញមានជនជាតិខ្មែរ(៧៥នាក់) ជនជាតិចាម/ខ្មែរឥស្លាម(១៨នាក់) និងជនជាតិដើមភាគតិច(៣៣នាក់)។ សមាមាត្រនេះមិនសមស្របទាំងស្រុងជាមួយនឹងប្រជាសាស្ត្រទូទាំងប្រទេសទេ។ ក្រុមជនជាតិខ្មែរជាចំនួនភាគច្រើននៃប្រជាជនកម្ពុជា ចំណែកជនជាតិដើមភាគតិច និងជនជាតិចាម/ខ្មែរឥស្លាមជាក្រុមភាគតិច។ ភាពតំណាងជនជាតិដើមភាគតិចលើសក្នុងសំណាកគំរូ អាចបង្ហាញពីបទពិសោធន៍ និងបញ្ហាប្រឈមរបស់ពួកគេច្រើនហួសពេក ជាហេតុអាចធ្វើឱ្យលុបលើបរិបទទូទៅ ដែលប៉ះពាល់ដល់ការស្វែងយល់ពីស្ថានភាពរបស់ជនជាតិខ្មែរភាគច្រើន និងក្រុមជនជាតិភាគតិចដទៃទៀត។

### ៤.២.៣. អត្តសញ្ញាណសាសនា

អត្តសញ្ញាណសាសនារបស់អ្នកចូលរួមផ្តល់ព័ត៌មាន បង្ហាញពីភាពតំណាងលើសទៅលើក្រុមសាសនាមួយចំនួន។ ឧទាហរណ៍ ខណៈពេលពុទ្ធសាសនាមានអ្នកប្រតិបត្តិភាគច្រើនលើសលុបនៅកម្ពុជា សំណាកគំរូរួមមានចំនួនខ្ពស់សម្រាប់គ្រិស្តបរិស័ទ(៣៧នាក់) និងឥស្លាមសាសនិក(១៨នាក់) បើប្រៀបធៀប ទៅនឹងសមាមាត្រជាក់ស្តែងរបស់ពួកគេនៅក្នុងចំនួនប្រជាជនទូទាំងប្រទេស។ វិសមាមាត្រនេះ អាចបង្កជាការសង្កត់ធ្ងន់លើបទពិសោធន៍របស់សាសនាភាគតិចទាំងនេះលើសលុប ដែលអាចបំភ័ន្តលើរបកគំហើញទាំងមូលពាក់ព័ន្ធនឹង ស.ស.ជ។ ការមានអ្នកផ្តល់ចម្លើយពីជំនឿបាហៃតែម្នាក់ក៏បង្កភាពស្មុគស្មាញដល់ភាពតំណាងនៃចម្រុះសាសនាផងដែរ។

### ៤.២.៤. របាយមុខរបរ/តួនាទី

របាយមុខរបរបង្ហាញភាពតំណាងលើសលុបទៅលើកសិករ(៨៧នាក់) ដែលអាចឆ្លុះបញ្ចាំងថា សហគមន៍គោលដៅមានមុខរបរចម្បងជាកសិករ ប៉ុន្តែមិនតំណាងឱ្យភាពចម្រុះនៃមុខរបរក្នុងប្រទេសទាំងមូលបានត្រឹមត្រូវនោះទេ។ ក្រុមមុខរបរធំៗផ្សេងទៀត ដូចជាមុខរបរនៅក្នុងទីប្រជុំជន និងវិស័យឧស្សាហកម្មត្រូវបានតំណាងតិចតួច។ វិសមាមាត្រនេះបានដាក់កំហិតលើលទ្ធភាពនាការសិក្សាក្នុងការសន្និដ្ឋានរួមទៅលើរបកគំហើញក្នុងបរិបទសេដ្ឋកិច្ចសង្គមខុសៗគ្នា ព្រោះបទពិសោធន៍របស់អ្នកធ្វើការផ្សេងពីកសិកម្មមិនត្រូវបានស្រង់យកគ្រប់គ្រាន់។

### ៤.២.៥. លទ្ធភាពនៃការសន្និដ្ឋានជារួម និងភាពតំណាង

ដោយមើលឃើញវិសមាមាត្រប្រជាសាស្ត្រទាំងនេះ លទ្ធភាពនៃការសន្និដ្ឋានរួមលើលទ្ធផលស្រាវជ្រាវនេះគឺមានដែនកំណត់។ សំណាកគំរូនេះអាចនឹងមិនឆ្លុះបញ្ចាំងត្រឹមត្រូវអំពីក្រុមប្រជាជនទូទៅក្នុងប្រទេសកម្ពុជា ជាហេតុបង្កឱ្យមានភាពលម្អៀងដែលអាចកើតមានក្នុងការយល់ដឹងពីស្ថានភាព ស.ស.ជ។ ភាពតំណាងលើសលុប ឬភាពតំណាងតិចពេកនៃក្រុមជាក់លាក់មួយចំនួន អាចធ្វើឱ្យខូចទ្រង់ទ្រាយនៃទិដ្ឋភាពទាំងមូលដែលធ្វើឱ្យពិបាកក្នុងការប្រើរបកគំហើញនេះជាតំណាងទូទាំងប្រទេស។ ដែនកំណត់ទាំងនេះទាមទារការបកស្រាយដោយប្រុងប្រយ័ត្នទៅលើរបកគំហើញ ហើយរំលេចពីតម្រូវការឱ្យមានការរៀបចំសំណាកគំរូនិងភាពតំណាងដែលមានតុល្យភាព សម្រាប់ការស្រាវជ្រាវបន្តនាពេលអនាគត។



# ៥.

# របកគំហើញនៃការស្រាវជ្រាវ

ផ្នែកនេះបង្ហាញពីរបកគំហើញចម្បងៗ ដែលស្វែងយល់ពីសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) ក្នុងទិដ្ឋភាពសំខាន់ៗមួយចំនួន។ ទីមួយគឺពិភាក្សាអំពីការអនុវត្តច្បាប់ ស.ស.ជ នៅកម្រិតមូលដ្ឋាន។ បន្ទាប់មកគឺពិនិត្យស្ថានភាពបច្ចុប្បន្នរបស់ ស.ស.ជ នៅក្នុងសហគមន៍សាសនា ឬជំនឿផ្សេងៗ ហើយស្វែងយល់ពីទំនាក់ទំនងឥទ្ធិពលនៃ ស.ស.ជ នៅក្នុងទំនាក់ទំនងអន្តរជំនឿ។ ជាចុងក្រោយ គឺគូសបញ្ជាក់ពីសារៈសំខាន់ និងភាពចាំបាច់នៃការលើកកម្ពស់ និងរក្សាការការពារ ស.ស.ជ។

## ៥.១. បទបញ្ញត្តិ និងការអនុវត្តច្បាប់ ស.ស.ជ នៅមូលដ្ឋាន

កិច្ចសម្ភាសមួយទល់មួយ (Key Information Interviews) អំពីសេរីភាពសាសនាឬជំនឿ ត្រូវបានធ្វើឡើង ជាមួយអាជ្ញាធរខេត្តចំនួន១១នាក់ នៃមន្ទីធម្មការ និងសាសនា នៅក្នុងខេត្តចំនួន៦ផ្សេងៗគ្នា។ អ្នកចូលផ្តល់បទសម្ភាន៍ទាំងអស់សុទ្ធតែជាបុរស ដោយក្នុងនោះមានពុទ្ធសាសនិកចំនួន១០នាក់ និងគ្រិស្តសាសនិកចំនួន១នាក់។ បើនិយាយពីជាតិពន្ធ បុគ្គល៩នាក់ជាជនជាតិខ្មែរ ចំណែកឯ៣នាក់ទៀតជាជនជាតិដើមភាគតិច។ អ្នកចូលរួមផ្តល់ព័ត៌មានមានអាយុចន្លោះពី៣០ឆ្នាំ ទៅ៥៣ឆ្នាំ ដែលនេះផ្តល់នូវទស្សនៈយល់ឃើញចម្រុះតាមដំណាក់កាលផ្សេងៗគ្នានៃអាជីពការងាររបស់ពួកគេ។ ជារួម ទិន្នន័យប្រជាសាស្ត្រនេះផ្តល់នូវការយល់ដឹងសព្វជ្រុងជ្រោយពីក្រុមសំណាកគំរូនេះ ដោយក្នុងនោះមានបញ្ជាក់ពីឯកសណ្ឋានភាពនៃយេនឌ័រនិងមុខរបរ/តួនាទី ព្រមទាំងបង្ហាញពីភាពចម្រុះនៃជំនឿសាសនា និងអត្តសញ្ញាណជាតិពន្ធ។

### ៥.១.១. ការអនុវត្ត និងការយល់ដឹងអំពីបទប្បញ្ញត្តិពាក់ព័ន្ធ

ការធ្វើសម្ភាសមួយទល់មួយជាមួយអាជ្ញាធរមកពីមន្ទីរធម្មការនិងសាសនា ផ្តល់នូវការយល់ដឹងពីការប្រតិបត្តិសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) និងឆ្លុះបញ្ចាំងពីទស្សនៈផ្សេងៗ និងចម្រុះគ្នា ដែលចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងបទប្បញ្ញត្តិជាតិ ការអនុវត្តនៅកម្រិតខេត្ត និងបទពិសោធន៍ជាក់ស្តែង។

នៅថ្នាក់ខេត្ត គេទទួលស្គាល់ការធានាសេរីភាពសាសនាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ អ្នកផ្តល់ព័ត៌មានម្នាក់បាននិយាយយ៉ាងខ្លីថា *"រដ្ឋធម្មនុញ្ញមាត្រា៤៣ចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិជឿលើសាសនាណាមួយ និងស្មើភាពចំពោះមុខច្បាប់។ នេះជា*

*ច្បាប់កំពូលរបស់ប្រទេស។”* នេះបង្ហាញពី ការយល់ដឹងជាមូលដ្ឋានថាក្របខ័ណ្ឌច្បាប់គឺការពារសេរីភាពសាសនា។

ទោះបីជាមានការទទួលស្គាល់ពីរដ្ឋធម្មនុញ្ញនេះក៏ដោយ គម្លាតនៅតែមានពេលអនុវត្តច្បាប់ទាំងនេះជាក់ស្តែង។ ជាឧទាហរណ៍ បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធមួយចំនួនមិនត្រូវបានចងចាំបានល្អឬបកស្រាយបានច្បាស់លាស់ក្នុងចំណោមអាជ្ញាធរខេត្តទាំងនេះឡើយ។ អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បានកត់សម្គាល់ថា *“មានច្បាប់ចែងពីរដ្ឋាភិបាល តែខ្ញុំអត់ច្បាស់”* នេះបង្ហាញពីចន្លោះប្រហោងរវាងច្បាប់ និងការអនុវត្ត ឬការយល់ដឹងនៅថ្នាក់ខេត្ត។

ការបកស្រាយនៅមានលក្ខណៈលាយឡំ ចំពោះការសាងសង់អគារសាសនា ឬការចុះបញ្ជីស្ថាប័នសាសនា។ ខណៈពេលអ្នកខ្លះថាមិនចាំបាច់បង់ប្រាក់សម្រាប់ការចុះឈ្មោះក្នុងន័យបង្ហាញពីជំហរគាំទ្រពីរដ្ឋាភិបាល អ្នកខ្លះទៀតថាតម្រូវឱ្យមានការបង់ប្រាក់ ឬតម្រូវឱ្យមាននីតិវិធីច្បាស់លាស់។ ភាពមិនស៊ីសង្វាក់គ្នានេះត្រូវបានរំលេចតាមមតិយោបល់ដូចជា *“មិនមានយកទេ”* និង *“ព័ត៌មាននេះមិនច្បាស់លាស់”* ដែលបង្ហាញពីកង្វះឯកសណ្ឋានភាពនៅក្នុងរបៀបដែលបទប្បញ្ញត្តិទាំងនេះត្រូវបានបង្ហាត់បង្ហាញនិងអនុវត្ត។

ការផ្សព្វផ្សាយជំនឿសាសនា និងការផ្តល់ហិរញ្ញប្បទានសម្រាប់គោលបំណងសាសនា ក៏បង្ហាញពីបទពិសោធន៍ផ្សេងៗគ្នាផងដែរ។ ខណៈពេលអ្នកចូលរួមផ្តល់ព័ត៌មានខ្លះបានប្រាប់ថា មិនចាំបាច់បង់ប្រាក់សម្រាប់សកម្មភាពសាសនាមួយចំនួន ក៏នៅមានករណីភាន់ច្រឡំទាក់ទងនឹងដំណើរការដែលតម្រូវឱ្យបង់ប្រាក់។ នេះបង្ហាញថា ខណៈពេលដែលក្របខ័ណ្ឌច្បាប់អាចនឹងផ្តល់ការគាំទ្រ ការអនុវត្តនៅថ្នាក់មូលដ្ឋានអាចនឹងមានបញ្ហា ជាក់ស្តែងមានការលើកឡើងម្តងហើយម្តងទៀតពីអ្នកផ្តល់ព័ត៌មានថា *“ព័ត៌មាននេះមិនច្បាស់លាស់។”*

មានការទទួលស្គាល់ជាទូទៅអំពីបរិយាបន្ន និងការគាំទ្រពីរដ្ឋាភិបាល ទៅលើការដឹកនាំសាសនា និងការចូលរួមរបស់ថ្នាក់ដឹកនាំសាសនានៅកម្រិតខេត្ត។ អ្នកចូលរួមផ្តល់ព័ត៌មានបានលើកឡើងថា អ្នកដឹកនាំសាសនាអាចចូលរួមក្នុងដំណើរការធ្វើការសម្រេចចិត្ត ដូចជាការសាងសង់ផ្លូវ និងសេវាសង្គមជាដើម។ ចំណុចនេះត្រូវបានបង្ហាញតាមការដកស្រង់ថា "ការចូលរួមគ្រប់សាសនាទាំងអស់ដូចជាការធ្វើផ្លូវជាដើម" ហើយ "ចូលរួមជាមួយកាកបាទក្រហម ធ្វើផ្លូវ ចូលរួមជាមួយសង្គម[គាំទ្រពេលមាន]កូវីដ១៩" ដែលនេះបង្ហាញពីកម្រិតនៃសមាហរណកម្មខេត្ត និងការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ទាំងអស់គ្នា ដោយមិនប្រកាន់ពីសាសនា។

ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តសិទ្ធិទាំងនេះនៅថ្នាក់មូលដ្ឋានមានភាពខុសៗពីគ្នា។ ក្រុមអ្នកផ្តល់ព័ត៌មានខ្លះបង្ហាញភាពជឿជាក់លើការគាំទ្ររបស់រដ្ឋាភិបាលចំពោះសាសនាទាំងអស់ ដូចអ្នកផ្តល់ព័ត៌មានម្នាក់បានរៀបរាប់ថា *"រដ្ឋាភិបាលជួយទាំងអស់ដោយមិនប្រកាន់ពីសាសនារបស់ពួកគេឡើយ"* ប៉ុន្តែ ចម្លើយផ្សេងទៀតឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ ឬកង្វះចំណេះដឹងអំពីបទប្បញ្ញត្តិមួយចំនួន។ នេះបង្ហាញថា ខណៈពេលច្បាប់គ្រប់គ្រងជារួមផ្តល់លក្ខណៈគាំទ្រ ការអនុវត្ត និងការយល់ដឹងតាមមូលដ្ឋានអាចមិនស៊ីសង្វាក់គ្នានឹងការគាំទ្រនេះ។

សរុបមក ការវិភាគតាមប្រធានបទខាងលើបង្ហាញឱ្យឃើញថា ខណៈពេលក្របខ័ណ្ឌច្បាប់ជាតិនៅក្នុងប្រទេសកម្ពុជាគាំទ្រដល់សេរីភាពសាសនា និងការចូលរួមរបស់ថ្នាក់ដឹកនាំសាសនានៅកម្រិតខេត្ត ការអនុវត្តជាក់ស្តែង និងការយល់ដឹងអំពីសិទ្ធិទាំងនេះមានភាពខុសប្លែកគ្នាក្នុងចំណោមអាជ្ញាធរដែលបានចូលរួមផ្តល់ព័ត៌មាន។ ចំណុចនេះទាមទារឱ្យមានការផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តស្របគ្នាឱ្យបានប្រសើរ ដើម្បីធានាថាគោលការណ៍ ស.ស.ជ ត្រូវបានយល់ និងអនុវត្តដូចៗគ្នាសម្រាប់សហគមន៍សាសនាផ្សេងៗគ្នា។

## ៥.១.២. ទិដ្ឋភាពច្បាប់ និងការអនុវត្ត ស.ស.ជ

### ក. តើច្បាប់កម្ពុជាមានចែងពីសេរីភាពសាសនា ឬជំនឿដែរឬទេ?

នេះគឺជាសំណួរមូលដ្ឋានសម្រាប់ការស្រាវជ្រាវនេះ។ ក្របខ័ណ្ឌច្បាប់នៅកម្ពុជាគាំទ្រសេរីភាពសាសនា ឬជំនឿ។ អ្នកផ្តល់សម្ភាសភាគច្រើនបញ្ជាក់ថា ពលរដ្ឋអាចប្រតិបត្តិសាសនារបស់ខ្លួនដោយគ្មានការហាមឃាត់ណាមួយពីផ្លូវច្បាប់ឡើយ ហើយការធានាពីរដ្ឋធម្មនុញ្ញនិងច្បាប់ គឺជួយការពារសេរីភាពសាសនា និងទប់ស្កាត់ការរើសអើងផ្អែកលើសាសនា។ ជាឧទាហរណ៍ មិនមានឧបសគ្គផ្លូវច្បាប់ ចំពោះការប្តូរជំនឿទេ ហើយជាទូទៅបុគ្គលម្នាក់ៗមានសេរីភាពក្នុងការអនុវត្តជំនឿតាមជម្រើសខ្លួន។ ចំណុចនេះមានបញ្ជាក់ក្នុងចម្លើយរបស់អាជ្ញាធរខេត្តនៃមន្ទីរធម្មការ និងសាសនា។

### ខ. តើច្បាប់រឹតបន្តឹង ស.ស.ជ នេះចំពោះសាសនាជាក់លាក់ណាមួយឬទេ?

ទោះបីជាមិនមានការរឹតបន្តឹងផ្លូវច្បាប់ណាមួយច្បាស់លាស់លើសាសនាជាក់លាក់ណាមួយក៏ដោយ តែហាក់ដូចជាមានការអនុវត្តមិនស្មើភាពគ្នាមកលើសាសនាផ្សេងៗ។ ពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ទទួលបានឯកសិទ្ធិខុសពីសាសនាដទៃ។ ឧទាហរណ៍ វត្តអារ៉ាមត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះជាអចិន្ត្រៃយ៍ដោយមិនចាំបាច់ចុះឈ្មោះឡើងវិញ។ កន្លែងគោរពថ្វាយបង្គំរបស់អ្នកកាន់សាសនាឥស្លាម ត្រូវចុះបញ្ជីមានកំណត់រយៈពេលដប់ឆ្នាំ ឯកន្លែងគោរពថ្វាយបង្គំរបស់គ្រិស្តបរិស័ទ ត្រូវចុះបញ្ជីមានកំណត់រយៈពេលពីរឆ្នាំ។ ការជ្រើសរើស និងការតែងតាំងថ្នាក់ដឹកនាំក្នុងព្រះពុទ្ធសាសនា គឺធ្វើឡើងតាមរយៈដំណើរការផ្លូវការ ដោយមានការបោះឆ្នោត និងមានពាក់ព័ន្ធនឹងបទដ្ឋានច្បាប់ ដែលខុសពីដំណើរការសម្រាប់ជ្រើសរើសថ្នាក់ដឹកនាំគ្រិស្តសាសនា និងសាសនាឥស្លាមដែលមានលក្ខណៈមិនសូវ

ផ្លូវការ។ ពិធីបុណ្យសាសនាដូចជាបុណ្យភ្ជុំបិណ្ឌត្រូវបានគោរពយ៉ាងទូលំទូលាយ និងប្រើជាថ្ងៃឈប់សម្រាកសាធារណៈ ប៉ុន្តែពិធីបុណ្យសាសនារបស់សាសនាផ្សេងពីសាសនារបស់រដ្ឋ ដូចជាបុណ្យណូអែល មិនទទួលបានការទទួលស្គាល់ដូចគ្នាឡើយ ដែលនេះបង្ហាញពីភាពខុសគ្នានៃការឱ្យតម្លៃទៅលើការប្រារព្ធពិធីបុណ្យសាសនារបស់សាសនានីមួយ។

### គ.តើមានការរឹតបន្តឹងដោយច្បាប់ទៅលើការបង្ហាញអំពីសាសនា ឬជំនឿណាមួយដែរឬទេ?

ទោះបីជាមានក្របខ័ណ្ឌច្បាប់រក្សាការពារសេរីភាពសាសនាក៏ដោយ ក៏មានការរឹតបន្តឹង និងបញ្ហាប្រឈមមួយចំនួនមកលើសហគមន៍សាសនា។ គំរូប្រវត្តិសាស្ត្រដូចជាការហាមប្រាមនាររបប ប៉ុល ពត មិនឱ្យជឿលើអបិយជំនឿ បង្ហាញពីព្រំដែនកំណត់ក្នុងអតីតកាលមកលើជំនឿសាសនា ទោះបីជាការហាមឃាត់ទាំងនេះនាពេលបច្ចុប្បន្នមិនត្រូវបានអនុវត្តក៏ដោយ។ ការចូលទៅកាន់ទីសក្ការៈអាចជួបបញ្ហាដោយសារពេលខ្លះគម្រោងអភិវឌ្ឍន៍បានរំលោភបំពាន ឬបំផ្លាញទីកន្លែងទាំងនេះ ដែលនេះគឺជាការរារាំងដោយប្រយោលដល់ការប្រតិបត្តិសាសនា។ បញ្ហាប្រឈម ឬការលម្អៀងនៅតាមមូលដ្ឋានអាចកើតមាននៅតំបន់ដែលមានការប្រមូលផ្តុំក្រុមសាសនាជាក់លាក់ ទោះបីជាមិនសូវមានការរាយការណ៍ពីការរើសអើងដោយចំហក៏ដោយ។ លើសពីនេះ ការមិនមានភាពច្បាស់លាស់ឬលម្អៀងក្នុងការផ្តល់ជំនួយ អាចមានការរើសអើងដោយអចេតនាប្រឆាំងនឹងក្រុមសាសនា ឬក្រុមដែលមានជីវភាពខ្សត់ខ្សោយមួយចំនួន ដែលនេះប្រៀបបាននឹងការរឹតត្បិតដោយប្រយោលលើការប្រតិបត្តិសាសនា។

### ឃ. តើមនុស្សអាចជួបជុំគ្នាដើម្បីគោរពបូជាឬថ្វាយបង្គំ ពិភាក្សា និងបង្រៀនសាសនាបានដោយសេរីឬទេ?

ការអនុវត្តបទប្បញ្ញត្តិច្បាប់មានភាពខុសប្លែកគ្នា ព្រោះអ្នកចូលរួមស្ទង់មតិបានបង្ហាញពីភាពលម្អៀងក្នុងការអនុវត្តច្បាប់ក្នុងមូលដ្ឋាន។ ខណៈពេលមនុស្សទូទៅអាចជួបជុំគ្នាដោយសេរីដើម្បីគោរពបូជា ថ្វាយបង្គំ ពិភាក្សា និងបង្រៀនសាសនារបស់ពួកគេ បញ្ហាប្រឈមនៅតែឃើញមាន។ សហគមន៍សាសនាមួយចំនួននៅតែជួបការលំបាក ក្នុងការចូលទៅកាន់ឬថែរក្សាកន្លែងសក្ការៈរបស់ពួកគេ ហើយមានការរាយការណ៍អំពីការយាយីក្នុងអំឡុងពេលប្រតិបត្តិជំនឿ ដោយមានការឃ្លាំមើលពីប៉ូលីស ដែលបង្កឱ្យមានបរិយាកាសបំភិតបំភ័យ។

### ង. តើពួកគេអាចជួល ឬទិញកន្លែងជួបជុំបានឬទេ? តើអ្នកគោរពបូជា និងទីសក្ការៈត្រូវរងការយាយីឬទេ?

ទាក់ទងនឹងលទ្ធភាពជួល ឬទិញកន្លែងជួបជុំ ក្រុមសាសនាភាគតិច ជាពិសេសគ្រិស្តសាសនិក ពុំប្រឈមនឹងការរឹតបន្តឹងផ្លូវច្បាប់ឡើយ ហើយអាចជួលកន្លែងធ្វើសកម្មភាពសាសនាបាន។ ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានៅតែមានពាក់ព័ន្ធនឹងសុពលភាពនៃការចុះឈ្មោះអគារ និងអង្គភាពសាសនា។ ជាក់ស្តែងវត្តអារ៉ាមព្រះពុទ្ធសាសនាទទួលបានការអនុញ្ញាតជាអចិន្ត្រៃយ៍បន្ទាប់ពីការចុះឈ្មោះរួច តែការចុះឈ្មោះដូចគ្នានេះមានកំណត់រយៈពេលសុពលភាពសម្រាប់កន្លែងគោរពថ្វាយបង្គំខាងសាសនាឥស្លាម និងគ្រិស្តសាសនា។ ការបៀតបៀនអ្នកគោរពបូជា និងទីគោរពបូជាឬថ្វាយបង្គំកើតមានឡើង តួយ៉ាងកន្លែងសក្ការៈរបស់ពួកគេត្រូវរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។ គ្រិស្តសាសនិកជាច្រើននៅតំបន់ជនបទខ្វះព្រះវិហារ ហើយជួបជុំគ្នានៅតាមផ្ទះឯកជន ប៉ុន្តែការជួបជុំទាំងនេះជួនកាលប្រឈមនឹងការរឹតបន្តឹង ដោយសារផ្ទះ

ផ្ទាល់ខ្លួនមិនត្រូវបានទទួលស្គាល់ថាជាអគារសាសនាដែលបានចុះបញ្ជី។ រដ្ឋាភិបាលមិនបានចុះបញ្ជីនិកាយគ្រិស្តសាសនា ឬព្រះវិហារថ្មីក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះទេ ហើយការទទួលសិទ្ធិអនុញ្ញាតសាងសង់ព្រះវិហារថ្មីៗគឺកម្រណាស់ ក្រោមហេតុផលថាតាមទិន្នន័យជំរឿន ចំនួនតិចតួចនៃអគារសាសនា គឺដោយផ្អែកលើភាគរយចំនួនប្រជាជន។

## ច. តើបុគ្គលទទួលបានសេរីភាពក្នុងការផ្សព្វផ្សាយសាសនាដែរឬទេ?

អ្នកចូលរួមផ្ដល់ព័ត៌មានភាគច្រើនបានបង្ហាញថា បុគ្គល ឬក្រុមដែលចង់ផ្សព្វផ្សាយសាសនារបស់ពួកគេ ត្រូវមានការអនុញ្ញាតឬរត់ការជាមុន។ ក្រុម និងបុគ្គលប្រឈមនឹងការរឹតបន្តឹងលើការផ្សព្វផ្សាយសាសនារបស់ពួកគេ ដែលតម្រូវឱ្យមានការអនុញ្ញាតពីអាជ្ញាធរដើម្បីចែកចាយសម្ភារៈផ្សព្វផ្សាយសាសនា។ នៅក្នុងខេត្តតាកែវមានការលើកឡើងថា បុគ្គលផ្សាយសាសនាដោយមិនមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ធ្លាប់ត្រូវប្រឈមនឹងបញ្ហា និងការពិន័យមួយចំនួន។ បើទោះបីជាទទួលបានការអនុញ្ញាតក៏ដោយ ក៏មានការកម្រិតលើរបៀបនិងកន្លែងផ្សព្វផ្សាយដែរ ដូចជាការរឹតបន្តឹងលើការផ្សាយពីផ្ទះមួយទៅផ្ទះមួយជាដើម។

សរុបមក ខណៈពេលដែលអាជ្ញាធរខេត្តយល់អំពីច្បាប់កម្ពុជាជាទូទៅក្នុងការអនុញ្ញាតឱ្យមានសេរីភាពសាសនា ឬជំនឿ គេឃើញមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តចំពោះក្រុមសាសនាភាគតិច និងការអនុវត្តច្បាប់ទាំងនេះ ដូចបានបង្ហាញរួចហើយក្នុងការស្ទង់មតិ។ បញ្ហាប្រឈមរួមមានការជួបជុំគ្នាដោយសេរីសម្រាប់ការគោរពបូជាឬថ្វាយបង្គំ ការផ្សព្វផ្សាយសាសនារបស់បុគ្គលឬក្រុម និងករណីមានការឃាឃី ជាពិសេសចំពោះសាសនាផ្សេងពីសាសនារបស់រដ្ឋ ដូចជាគ្រិស្តសាសនា និងប្រព័ន្ធជំនឿជនជាតិដើមភាគតិច។ បញ្ហាទាំងនេះបង្ហាញថា ការអនុវត្តច្បាប់ប្រហែលជាមិនសមធម៌តាមបំណងប៉ងរបស់ក្របខ័ណ្ឌច្បាប់ឡើយ។

# ៥.២. ស្ថានភាព ស.ស.ជ ក្នុងសហគមន៍សាសនា/ជំនឿផ្សេងៗគ្នា

ផ្នែកនេះវាយតម្លៃស្ថានភាពនៃសេរីភាពសាសនា ឬជំនឿ ក្នុងចំណោមសាសនាចម្រុះនៅក្នុងសហគមន៍គោលដៅ។ យើងពិនិត្យមើលទទ្ធភាពទទួលបានសេវាសង្គមរបស់ពួកគេ លទ្ធភាពចូលទៅកាន់និងរក្សាទីសក្ការៈ និងការសម្រួលសម្រាប់ការប្រតិបត្តិសាសនា និងជំនឿរបស់ពួកគេ។

## ៥.២.១. សេវាកម្ម និងការគាំទ្រស្មើភាពសម្រាប់សហគមន៍សាសនា ឬជំនឿផ្សេងគ្នា

ផ្នែកនេះដកស្រង់ចេញពីការស្ទង់មតិ និងការធ្វើសម្ភាសជាមួយអ្នកដឹកនាំសាសនា និងអ្នកដឹកនាំសហគមន៍ ដោយពិនិត្យមើលលទ្ធភាពទទួលបានសេវាសង្គម និងការគាំទ្រក្នុងសហគមន៍សាសនា និងជំនឿ។

អ្នកដឹកនាំសាសនាបានលើកឡើងពីប្រធានបទធំៗមួយចំនួន ទាក់ទងនឹងទំនាក់ទំនងរវាងមនុស្សដែលមានជំនឿខុសៗគ្នានៅក្នុងសហគមន៍របស់ខ្លួន និងបញ្ហាប្រឈមដែលជួបនៅពេលអនុវត្តជំនឿសាសនារបស់ពួកគេ។ ប្រធានបទដ៏លេចធ្លោមួយគឺការផ្តល់សេវា និងការគាំទ្រស្មើគ្នា។ អ្នកដឹកនាំសាសនានិងអ្នកដឹកនាំសហគមន៍បានទទួលស្គាល់ថា បុគ្គលម្នាក់ៗទទួលបានការអប់រំ ការថែទាំសុខភាព និងជំនួយសេដ្ឋកិច្ចស្មើៗគ្នា ដោយមិនគិតពីសាសនារបស់ពួកគេឡើយ។ អ្នកចូលរួមផ្តល់ព័ត៌មាន៩៦%បានរាយការណ៍ថា សេវាទទួលបានគឺស្មើៗគ្នា បើធៀបនឹងប្រជាជននៃសាសនាផ្សេងទៀត រួមទាំងការអប់រំ ការថែទាំសុខភាព និងការគាំទ្រផ្នែកសេដ្ឋកិច្ច។ អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បានចែករំលែកថា *"បានដូចគ្នា គ្រាន់តែថាការទទួលបានសេវាសង្គម យើងមិនមានប្រកាន់ទេ ព្រះពុទ្ធក៏ដោយ គ្រិស្តក៏ដោយ ឱ្យតែក្រ*

*បានដូចតែគ្នា គ្រាន់តែផ្នែកខាងក្រោមគាត់មិនបានមើលដិតដល់ ច្រឡំឱ្យអ្នកមាន អ្នកក្រ អត់ចឹងទៅ*" ហើយម្នាក់ទៀតបាននិយាយថា "*ទទួលបានសេវាកម្មស្មើៗគ្នា អត់មានប្រកាន់សាសនាណាទេ។*" នេះបង្ហាញពីកម្រិតមូលដ្ឋាននៃសមភាព សម្រាប់សេវាសង្គមចម្បងៗ ដែលជាកត្តាសំខាន់សម្រាប់រក្សាភាពចុះសម្រុងគ្នាក្នុងសង្គម។




ចម្លើយផ្តល់ដោយអ្នកចូលរួមស្ទង់មតិមួយចំនួនបង្ហាញពីភាពប្រសើរឡើងជាលំដាប់ជាពិសេសទាក់ទងនឹងការគាំទ្រផ្នែកសេដ្ឋកិច្ច។ នេះបង្ហាញថា វិសមភាពពីមុនកំពុងត្រូវបានដោះស្រាយ ដែលជាចំណុចឈានទៅដល់ការបែងចែកធនធានប្រកបដោយសមធម៌ជាងមុនសម្រាប់សហគមន៍សាសនាផ្សេងៗគ្នា។ ជាឧទាហរណ៍ គំនិតផ្តួចផ្តើមក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុដល់ក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ចាប់ផ្តើមមានលក្ខណៈបរិយាបន្នជាងមុន ដែលនេះឆ្លុះបញ្ចាំងពីវឌ្ឍនភាពក្នុងការដោះស្រាយវិសមភាពសេដ្ឋកិច្ច ដែលអាចកើតមាននាពេលកន្លងមក។ អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បានប្រាប់ថា "*ពីមុនមាន [គាំទ្រសេដ្ឋកិច្ចមិនស្មើគ្នា] តែឥឡូវអត់មានទេ។*"

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមជាមួយនឹងការគាំទ្រផ្នែកសេដ្ឋកិច្ចត្រូវបាន លើកឡើងម្តងម្កាល ដែលបង្ហាញថាលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុមិនរមែងតែងតែស្មើគ្នាឡើយ។ អ្នកចូលរួមផ្តល់ព័ត៌មានខ្លះលើកពីបញ្ហាដូចជាការចែកចាយមិនស្មើភាពគ្នា ឬកង្វះភាពច្បាស់លាស់អំពីរបៀបបែងចែកជំនួយសេដ្ឋកិច្ច។ ដូចអ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បាននិយាយថា *"អត់មានប្រកាន់សាសនាទេ តែមានការប្រកាន់បក្សពួកអ្នកខ្លះបាន ហើយអ្នកខ្លះអត់បាន។"* បញ្ហាប្រឈមទាំងនេះបង្ហាញថាចាំបាច់ត្រូវមានកិច្ចខិតខំបន្ថែមទៀត ដើម្បីធានាថាសមាជិកសហគមន៍ទាំងអស់ទទួលបានអត្ថប្រយោជន៍ស្មើៗគ្នាពីកម្មវិធីជំនួយសេដ្ឋកិច្ច។

សរុបមក ទោះបីជាមានបញ្ហាប្រឈម និងភាពមិនច្បាស់លាស់ខ្លះក៏ដោយ អ្នកចូលរួមផ្តល់ព័ត៌មានជាច្រើនបានសម្តែងការពេញចិត្តជារួមចំពោះកម្រិតសេរីភាពសាសនាឬជំនឿនៅថ្នាក់មូលដ្ឋាន។ ពួកគេបានរាយការណ៍ថាទទួលបានសេវាកម្ម និងការគាំទ្រស្មើៗគ្នា ដែលនេះជាការយល់ឃើញពីស្ថានភាពទូទៅក្នុងផ្លូវវិជ្ជមាន។ ការពេញចិត្តនេះឆ្លុះបញ្ចាំងពីអំណរទូទៅក្រោមកិច្ចខិតខំលើកកម្ពស់សេរីភាពសាសនា និងផ្តល់សេវាកម្មដោយសមធម៌ ដែលនេះជួយពង្រឹងសារៈសំខាន់នៃកិច្ចខិតខំជាបន្តបន្ទាប់ដើម្បីរក្សា និងលើកកម្ពស់លទ្ធផលវិជ្ជមានទាំងនេះ។

## ៥.២.២. សេរីភាពសាសនា ឬជំនឿ និងជនជាតិដើមភាគតិច (តាមការពិពណ៌នាពីអ្នកដឹកនាំសហគមន៍)

ជនជាតិដើមភាគតិចក្នុងសហគមន៍ព្រៃឈើនៅកម្ពុជាប្រឈមនឹងបញ្ហាច្រើនក្នុងការអនុវត្តជំនឿ និងពិធីប្រពៃណីរបស់ខ្លួន។ សម្ពាធពីទំនើបភាវូបនីយកម្ម គម្រោងអភិវឌ្ឍន៍ និងការជ្រៀតជ្រែកពីខាងក្រៅប៉ះពាល់យ៉ាងខ្លាំងដល់កន្លែងសក្ការៈ និងអត្តសញ្ញាណវប្បធម៌របស់ពួកគេ។ ផលប៉ះពាល់នៃការអភិវឌ្ឍទាំងនេះមានសង្ខេបនៅក្នុងពាក្យពេចន៍របស់អ្នកចូលរួមផ្តល់ព័ត៌មាន។

***“នៅក្នុងសហគមន៍ មិនមានកន្លែងគោរពបូជា បន់ស្រន់ ថ្វាយអ្នកតា។ អ្នកស្រុកបាត់ជំនឿម្តងបន្តិចៗនូវបុព្វបុរសរបស់ខ្លួន បាត់កេរវប្បធម៌ដូនតា។”***

ទិន្នន័យស្ទង់មតិបង្ហាញពីលក្ខណៈចម្រុះនៃបញ្ហាទាំងនេះ ដូចជាការគំរាមកំហែងដល់សេរីភាពសាសនារបស់ពួកគេ និងផលប៉ះពាល់អវិជ្ជមានលើសុខុមាលភាពផ្លូវស្មារតីរបស់ពួកគេពាក់ព័ន្ធនឹងព្រលឹងវិញ្ញាណ។

***“ប្រែប្រួលអាកាសធាតុ អស់ព្រៃ សត្វរត់ទៅស្រុកគេ ស្តាយអស់កន្លែងបន់ស្រន់សុំសុខ។”***

បញ្ហាធំបំផុតមួយគឺការបំផ្លិចបំផ្លាញព្រៃឈើ និងបឹងសក្ការៈ ដែលជាផ្នែកសំខាន់សម្រាប់ការប្រតិបត្តិខាងព្រលឹងវិញ្ញាណ និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច។ ការអត្ថាធិប្បាយនេះបង្ហាញពីទិដ្ឋភាពដ៏ក្រៀមក្រំ មិនត្រឹមតែការបាត់បង់ព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែជាការបំផ្លិចបំផ្លាញខាងវិញ្ញាណដែលបង្កមកពីការបាត់បង់បឹង និងព្រៃសក្ការៈផងដែរ។

*“ប្តូរទីកន្លែង (លំនៅឋាន និងទីសក្ការៈ)*
*ដោយសារយើងបាត់បង់ [ព្រៃឈើ] ច្រើន។”*

*“មានដូចជាផលវិបាកក្នុងការប្តូរទីកន្លែង និងមានការបាត់បង់ទីសក្ការៈច្រើន”*
*ហើយ “បាត់បង់រូបអ្នកតា ប្តូរទីតាំងលោកតា”*

ទីកន្លែងទាំងនេះច្រើនជាគោលដៅដែលគេធ្វើសកម្មភាពខុសច្បាប់ ដូចជាការកាប់បំផ្លាញព្រៃឈើ ការដករូបចម្លាក់ស័ក្តិសិទ្ធ និងការរឹបអូសយកដី។ ការចូលរួមក្នុងសកម្មភាពទាំងនេះពីសំណាក់ក្រុមអភិជន កងកម្លាំងប្រដាប់អាវុធ ប៉ូលិស និងក្រុមហ៊ុនឯកជន ធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរឡើង ដោយក្រុមហ៊ុនចិនបានចូលពាក់ព័ន្ធជាញឹកញាប់នៅក្នុងសកម្មភាពឈូសឆាយដី ដែលបំផ្លាញទីកន្លែងសក្ការៈក្នុងទីតាំងមូលដ្ឋាន។

> ***ការកាប់ព្រៃឈើ គឺអ្នកមានអំណាច មានទាហាន ប៉ូលីស ក្រុមហ៊ុន និងអាជ្ញាធរ។***

ការទន្ទ្រានយកទីសក្ការៈបង្កជាបញ្ហាសង្គម និងជម្លោះក្នុងសហគមន៍ទាំងនេះ។ ការរឹបអូសយកដីសហគមន៍ រួមទាំងការកាប់ដើមឈើស័ក្តិសិទ្ធ នាំឱ្យបាត់បង់កន្លែងវប្បធម៌ និងជំនឿសំខាន់ៗ។ ទង្វើនេះមិនត្រឹមតែរំខានដល់ទីតាំងសក្ការៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញអត្តសញ្ញាណវប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិចទៀតផង។ ភាពតានតឹងក្នុងសង្គមកាន់តែកើនឡើងទៀតដោយសារការយាយីពីអ្នកដទៃ ជាហេតុបន្ថែមកម្រិតជម្លោះ និងភាពតានតឹងមួយកម្រិតទៀត។

សហគមន៍ជនជាតិដើមភាគតិចក៏ប្រឈមនឹងបញ្ហាធំៗក្នុងការអនុវត្តជំនឿរបស់ខ្លួន ដោយសារកត្តាខាងក្រៅ។ ការរាំងស្ទះនៃពិធីប្រពៃណី និងការប្រតិបត្តិខាងព្រលឹងវិញ្ញាណ គឺកើតផ្ទាល់ចេញពីការកាប់ព្រៃឈើ និងសកម្មភាពអភិវឌ្ឍន៍។ ការឈូសឆាយដីខុសច្បាប់ដោយក្រុមហ៊ុនឯកជនក្នុងគោលបំណងដាំដុះប៉ះពាល់ដល់បរិស្ថានផង និងបំផ្លាញទីសក្ការៈផង ជាហេតុធ្វើឱ្យសហគមន៍ពិបាកចូលទៅដល់តំបន់សក្ការៈទាំងនេះសម្រាប់គោលបំណងសាសនា។ វិវាទលើកម្មសិទ្ធិដីធ្លីកាន់តែ

រាំងស្ទះដល់ការចូលទៅកាន់ទីសក្ការៈ ព្រោះរារាំងដល់ការប្រារព្ធពិធីប្រពៃណី និងការរក្សាការប្រតិបត្តិខាងព្រលឹងវិញ្ញាណ។

ការបាត់បង់សិទ្ធិចូលទៅកាន់កន្លែងសក្ការៈ និងផលប៉ះពាល់លើពិធីប្រពៃណីមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខុមាលភាពផ្នែកស្មារតីទាក់ទងនឹងព្រលឹងវិញ្ញាណរបស់សហគមន៍ទាំងនេះ។ ការបំផ្លិចបំផ្លាញដោយខុសច្បាប់នៃទីកន្លែងសក្ការៈ និងកង្វះលទ្ធភាពចូលទៅកាន់ទីសក្ការៈរារាំងមិនឱ្យជនជាតិដើមភាគតិចប្រតិបត្តិពិធីសាសនា និងរក្សាបេតិកភណ្ឌវប្បធម៌ និងអត្តសញ្ញាណរបស់ពួកគេ។ ការបាត់បង់កន្លែងវប្បធម៌ និងសាសនានេះធ្វើឱ្យបាត់បង់វប្បធម៌ និងអត្តសញ្ញាណកាន់តែច្រើន ដែលប៉ះពាល់ដល់ភាពចុះសម្រុងគ្នា និងភាពធន់ផ្នែកជំនឿព្រលឹងវិញ្ញាណរបស់សហគមន៍។

> *មានផលលំបាកជួនកាលយើងឈឺគ្រុនអី ថាខុសកូនចៅមិនបាន គោរពបូជាអ៊ីចឹងទៅបើបាត់អស់ហើយ។ គោរពយើងគោរព គ្រាន់តែវំព្វកតែអត់មានទីតាំងគោរពគាត់អ៊ីចឹងណា។*

ការបាត់បង់ការប្រតិបត្តិសាសនារបស់ខ្លួន មិនគ្រាន់តែបណ្តាលមកពីការបំផ្លាញជម្រកធម្មជាតិរបស់ពួកគេតែមួយមុខទេ។ លើសពីនេះ ជនជាតិដើមភាគតិចនៅក្នុងសហគមន៍ព្រៃឈើ ក៏ជួបប្រទះនឹងបញ្ហាជាក់លាក់មួយចំនួនទាក់ទងនឹង ស.ស.ជ ជាពិសេសទាក់ទងនឹងជំនឿ និងទំនៀមទម្លាប់ប្រពៃណីរបស់ពួកគេ។ សហគមន៍ទាំងនេះច្រើនតែពឹងផ្អែកលើការគោរពបូជាជំនឿទាក់ទងនឹងព្រលឹងវិញ្ញាណ ឬអ្នកតា ដែលបច្ចុប្បន្នក្លាយទៅជាភាគតិចនិងត្រូវបានផាត់ចេញ ដោយសារការប្រតិបត្តិសាសនាធំៗ។ គម្រោងអភិវឌ្ឍន៍ជារឿយៗរំលោភបំពានកន្លែងសក្ការៈ រំខានដល់ការប្រតិបត្តិសាសនា និងការតភ្ជាប់ទៅទីសក្ការៈរបស់ពួកគេ។ លើសពីនេះ គោលនយោបាយរបស់រដ្ឋាភិបាល

និងតវិយាបថសង្គមទាំងមូល ជួនកាលបានច្រានចោលជំនឿជនជាតិដើមភាគតិចដោយថានេះជាជំនឿបុព្វកាល ឬអន់ថយ ដែលធ្វើឱ្យកាន់តែប៉ះពាល់ដល់សេរីភាពសាសនានិងជំនឿរបស់ជនជាតិដើមភាគតិច។ ក្រុមជនជាតិដើមភាគតិចអាចស្វែងរកការគាំទ្រមួយចំនួនពីការការពារផ្លូវច្បាប់ ឬការតស៊ូមតិពីអង្គការមិនមែនរដ្ឋាភិបាល។ វិធានការទាំងនេះជារឿយៗមិនគ្រប់គ្រាន់ដើម្បីទប់ទល់សម្ពាធកើតចេញពីការធ្វើទំនើបកម្ម និងការខិតខំធ្វើឱ្យមនុស្សទាំងអស់កាន់សាសនាតែមួយ។ តាមអ្នកចូលរួមផ្តល់ព័ត៌មានបានរាយការណ៍ថា៖

*"យើងផ្លាស់ប្តូរទីកន្លែង ហើយបាត់បង់ព្រៃសក្ការៈរបស់យើង"*

បញ្ហាប្រឈមទាំងនេះកាន់តែធ្ងន់ធ្ងរឡើង ព្រោះមានការពាក់ព័ន្ធពីអង្គភាពខាងក្រៅដែលមានអំណាច និងដោយសារអសណ្តាប់ធ្នាប់សង្គម ដែលនេះទាមទារឱ្យមានវិធានការការពារបន្ទាន់ ដើម្បីរក្សាបូរណភាពវប្បធម៌ និងសាសនារបស់សហគមន៍តាមរយៈការការពារកន្លែងសក្ការៈរបស់ពួកគេ។

### ៥.២.៣. បញ្ហាប្រឈមក្នុងការប្រតិបត្តិជំនឿរបស់អ្នកមានជំនឿខុសៗគ្នា (តាមការពិពណ៌នាពីអ្នកកាន់សាសនាក្នុងមូលដ្ឋាន)

ក្នុងផ្នែកនេះ យើងពិនិត្យមើលទស្សនៈអ្នកប្រតិបត្តិក្នុងមូលដ្ឋានដែលមានជំនឿផ្សេងគ្នា ពាក់ព័ន្ធនឹងបញ្ហាប្រឈមដែលពួកគេជួបប្រទះក្នុងការប្រតិបត្តិជំនឿសាសនា និងពិធីសាសនារបស់ខ្លួន។ ការយល់ដឹងទាំងនេះបង្ហាញពីបញ្ហាសំខាន់ៗដែលមិនបានលើកឡើងដោយអ្នកដឹកនាំសហគមន៍ ដោយបំភ្លឺពីការលំបាកប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗក្នុងការរក្សាការប្រតិបត្តិសាសនា និងបេតិកភណ្ឌវប្បធម៌នៃសហគមន៍របស់ពួកគេ។

## ក. កង្វះសិទ្ធិចូលទៅកាន់ទីសក្ការៈ

អ្នកចូលរួមផ្តល់ព័ត៌មានជាច្រើនបង្ហាញការព្រួយបារម្ភអំពីកង្វះកន្លែងគោរពបូជាសមរម្យ ដែលបង្កើតការលំបាកក្នុងការរៀបចំពិធីសាសនាពិសេសៗ និងការជួបជុំប្រតិបត្តិជំនឿជាទៀងទាត់។ កង្វះខាតនេះបង្ខំឱ្យបុគ្គលមួយចំនួនស្វែងរកកន្លែងផ្សេងមកជំនួស ដែលជារឿយៗមិនសមស្រប សម្រាប់សកម្មភាពសាសនារបស់ពួកគេ ដែលនាំឱ្យមានអារម្មណ៍ថាត្រូវបានគេបណ្តេញចេញ និងអារម្មណ៍ខកចិត្ត។ ឧទាហរណ៍ នៅតាមភូមិមួយចំនួន សកម្មភាពសាសនាមានការរឹតបន្តឹង នៅពេលប្រារព្ធនៅតាមផ្ទះឯកជនដែលមិនបានចុះបញ្ជីជាកន្លែងសាសនាផ្លូវការ ដែលនេះបង្កជាភាពស្មុគស្មាញកាន់តែខ្លាំងដល់សមត្ថភាពប្រតិបត្តិជំនឿរបស់ពួកគេ។

*“ការបាត់បង់រូបអ្នកតា និងផ្លាស់ប្តូរទីកន្លែងលោកតា។”*

## ខ. ការបំផ្លិចបំផ្លាញ និងការបាត់បង់ទីកន្លែងសក្ការៈ

ការបំផ្លិចបំផ្លាញ និងការបាត់បង់ទីកន្លែងសក្ការៈ ដោយសារការកាប់បំផ្លាញព្រៃឈើ និងការឈូសឆាយដីដោយក្រុមហ៊ុននានា (តាមការពិពណ៌នាពីជនជាតិដើមភាគតិចថាជាអំពើខុសច្បាប់) ជាប្រធានបទលើកឡើងដដែលៗនៅក្នុងចម្លើយដែលផ្តល់ដោយក្រុមជនជាតិដើមភាគតិច។ ការបាត់បង់ទាំងនេះមិនត្រឹមតែរារាំងដល់ការប្រតិបត្តិសាសនាប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ខ្លាំងដល់អត្តសញ្ញាណវប្បធម៌ និងជំនឿលើព្រលឹងវិញ្ញាណនៃសហគមន៍ព្រៃឈើដែលរងផលប៉ះពាល់ផងដែរ។ ជាឧទាហរណ៍ ការឈូសឆាយព្រៃសម្រាប់គម្រោងអភិវឌ្ឍន៍បានបង្កឱ្យបាត់ភាពស័ក្តិសិទ្ធិនៃបឹង និងព្រៃឈើដែលមានសារៈសំខាន់ចំពោះជំនឿលើព្រលឹងវិញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច។

*“សកម្មភាពទាំងនេះ (ការកាប់បំផ្លាញព្រៃឈើ និងការឈូសឆាយដី) ប៉ះពាល់ដល់ជំនឿរបស់យើង ហើយយើងនឹងបាត់បង់វប្បធម៌ និងអត្តសញ្ញាណរបស់យើង។ កន្លែងដែលយើងប្រើដើម្បីគោរពបូជា រងការបំផ្លាញ។ យើងបាត់បង់ព្រៃឈើសក្ការៈ បឹងសក្ការៈ និងរបងប្រាសាទបុរាណ។ នៅសល់តែកូនភ្នំតូចៗ... ពេលខ្លះមានឈើគ្រុន ដោយសារខានអត់បានសែនព្រេន។ យើងថ្វាយបង្គំក្នុងចិត្ត តែយើងអត់មានកន្លែងសម្រាប់សែនព្រេនអារក្សអ្នកតាទេ។”*

*“[...] យើងបានត្រឹមគោរពបូជាក្នុងចិត្តប៉ុណ្ណោះ ប៉ុន្តែយើងមិនមាន កន្លែងដាក់លាក់សម្រាប់គោរពបូជាពួកគេទេ។”*

*“[ការបួងសួងរបស់យើង] លែងសូវសក្តិសិទ្ធិ លែងសូវពូកែ។”*

## គ. បញ្ហាប្រឈមក្នុងការប្រតិបត្តិពិធីសាសនា

ឧបសគ្គធំក្នុងការអនុវត្តពិធីសាសនារួមមានការដាក់កំហិតពីអាជ្ញាធរ ឬការជៀតជ្រែកពីកត្តាខាងក្រៅ។ ការរឹតបន្តឹងទាំងនេះរារាំងសហគមន៍មិនឱ្យចូលរួមក្នុងទំនៀមទំលាប់សាសនារបស់ពួកគេបានពេញលេញ ដែលបណ្តាលឱ្យមានការរំខាន និងការធ្លាក់ចុះភាពរស់រវើកនៃការអនុវត្តវប្បធម៌របស់ពួកគេ។ អ្នកចូលរួមផ្តល់ព័ត៌មានជាច្រើនលើកឡើងពីការខិតខំពឹងពាក់អាជ្ញាធរមូលដ្ឋាន ឬចាត់វិធានការផ្លូវច្បាប់ដើម្បីការពារ និងអភិរក្សទីកន្លែងសក្ការៈ។ នេះឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំតស៊ូជាបន្តបន្ទាប់ក្នុងការរក្សាទុកទីសម្គាល់វប្បធម៌ដ៏សំខាន់ទាំងនេះ។

*“កន្លែងដែលឆ្ងាយ គឺអាចចូលទៅគោរពបាន តែកន្លែងខ្លះគេមិនឱ្យចូល ដូច្នេះក៏មិនអាចចូលទៅគោរពបាននោះទេ។”*

## ឃ. ផលប៉ះពាល់លើសុខុមាលភាពសហគមន៍

ការបាត់បង់ទីកន្លែងសក្ការៈ និងប្រពៃណីមានផលប៉ះពាល់លើសុខុមាលភាពរបស់សហគមន៍យ៉ាងខ្លាំង។ អ្នកចូលរួមផ្តល់ព័ត៌មានរាយការណ៍ពីភាពសោកសៅ ការខកចិត្ត និងការព្រួយបារម្ភអំពីការធ្លាក់ចុះនៃជំនឿ និងអត្តសញ្ញាណវប្បធម៌។ ការបំផ្លាញមូលដ្ឋានខាងវិញ្ញាណនិងវប្បធម៌ទាំងនេះ ប៉ះពាល់ដល់ស្មារតី និងភាពចុះសម្រុងរបស់សហគមន៍ ដែលឈានដល់ការបាត់បង់ និងការផ្តាច់ទំនាក់ទំនងពីមរតកបន្សល់ពីដូនតារបស់ពួកគេ។

> ***យើងសោកស្តាយព្រោះយើងគ្មានកន្លែងសក្ការៈទៀតទេ...***
> ***ខ្ញុំបានត្រឹមតែសោកស្តាយមិនថាតែព្រៃឈើនោះទេ***
> ***សូម្បីតែក្នុងដីក៏មិនសល់ផង។ ខ្ញុំពិតជាស្តាយ។***

## ង. កង្វល់ផ្នែកបរិស្ថាន

កង្វល់ផ្នែកបរិស្ថាន ដូចជាការកាប់បំផ្លាញព្រៃឈើ និងបម្រែបម្រួលអាកាសធាតុ បង្កភាពស្មុគស្មាញដល់បញ្ហាប្រឈមរបស់សហគមន៍សាសនា។ កត្តាទាំងនេះគម្រាមកំហែងដល់ទីកន្លែងសក្ការៈ ជាហេតុធ្វើឱ្យកាន់តែលំបាកក្នុងការការពារ និងអភិរក្សតំបន់ទាំងនេះសម្រាប់មនុស្សជំនាន់ក្រោយ។ ភាពវិចវិលនៃបរិស្ថានធម្មជាតិដែលជាជម្រកនៃទីសក្ការៈទាំងនេះ ធ្វើឱ្យមានការលំបាកក្នុងការថែរក្សាប្រពៃណីជំនឿ។

*“មានការឈូសឆាយដីព្រៃ មានក្រុមហ៊ុន ធ្វើឱ្យមានការបាត់បង់ច្រើន។”*

*“ការប្រែប្រួលអាកាសធាតុ ការបាត់បង់ព្រៃឈើ
សត្វព្រៃនឹងរកទីជម្រកនៅក្នុងប្រទេសផ្សេងៗ។”*

*“បាត់បង់កន្លែងគោរពបូជា បាត់បង់អត្តសញ្ញាណ
របស់ជនជាតិដើមភាគតិច បាត់បង់កន្លែងឃ្វាលគោ ឃ្វាលក្របី
ហើយយើងបាត់បង់ដើមច្បោះជ័ររាប់ម៉ឺនដើម ហើយបាត់បង់មុខរបរ
យើងធ្វើស្រែចំការធ្វើឱ្យជីវភាពធ្លាក់ចុះ ដោយសារយើងធ្លាប់ប្រកបមុខរបរ
មានដីមានព្រៃមានបន្លែគ្រប់ប្រភេទក្លាយជាអស់។ ពឹងទៅលើអី!”*

ទិន្នន័យនេះបង្ហាញពីបញ្ហាដែលអ្នកចូលរួមប្រឈមក្នុងការរក្សាសេរីភាពខាងជំនឿ និងការការពារកន្លែងសក្ការៈរបស់ពួកគេ។ ចម្លើយទទួលបានគឺសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការប្រឹងប្រែងរួមគ្នារវាងសហគមន៍ អ្នកដឹកនាំសាសនា និងអាជ្ញាធរ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ តាមរយៈការធ្វើការរួមគ្នា ក្រុមទាំងនេះអាចជួយធានាបានថាការប្រតិបត្តិជំនឿ និងអត្តសញ្ញាណវប្បធម៌ទទួលបានការគោរព និងថែរក្សាសម្រាប់មនុស្សជំនាន់ក្រោយ។

សរុបសេចក្ដីមក លទ្ធផលវាយតម្លៃបង្ហាញថា សេរីភាពសាសនា ឬជំនឿមានកម្រិតខ្ពស់នៅពេលពិចារណាអំពីសមភាពនៃសេវាសង្គមដែលផ្ដល់ដល់ក្រុមសាសនា ឬជំនឿនីមួយៗ។ អ្នកដឹកនាំសាសនាក្នុងប្រទេសកម្ពុជារាយការណ៍ថា មនុស្សកាន់ជំនឿណាក៏ដោយ ទទួលបានសិទ្ធិស្មើគ្នាសម្រាប់សេវាសំខាន់ៗដូចជា ការអប់រំ ការថែទាំសុខភាព និងការគាំទ្រផ្នែកសេដ្ឋកិច្ច។ ខណៈពេលមានភាពប្រសើរឡើងនៅក្នុង

ការគាំទ្រផ្នែកហិរញ្ញវត្ថុ យើងឃើញនៅមានបញ្ហាម្តងម្កាលពាក់ព័ន្ធនឹងការចែកចាយធនធានជំនួយ។ ជារួមមានការយល់ឃើញជាវិជ្ជមានអំពីសេរីភាពសាសនា និងការគាំទ្រស្មើៗគ្នានៅថ្នាក់មូលដ្ឋាន។ ទោះយ៉ាងណាក៏ដោយ ទាក់ទងនឹងការចូលទៅកាន់ទីកន្លែងសក្ការៈ សេរីភាពសាសនា ឬជំនឿរបស់សហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងបញ្ហាធំៗ។ ទំនើបភាវូបនីយកម្ម និងគម្រោង អភិវឌ្ឍន៍បានបំផ្លាញទីសក្ការៈបូជា ដែលប៉ះពាល់ដល់អត្តសញ្ញាណវប្បធម៌ និងការប្រតិបត្តិសាសនា នាំឱ្យមានវិវាទសង្គម និងការបាត់បង់បេតិកភណ្ឌវប្បធម៌។ អ្នកប្រតិបត្តិជំនឿផ្សេងៗក៏ជួបការលំបាកផងដែរជាមួយកន្លែងគោរពបូជាមិនគ្រប់គ្រាន់ ការធ្វើពិធីមានកម្រិត និងផលប៉ះពាល់បរិស្ថានដល់ទីកន្លែងសក្ការៈ ជាហេតុបង្ហាញថាត្រូវមានកិច្ចខិតខំរួមគ្នាដើម្បីការពារសេរីភាពសាសនា និងបេតិកភណ្ឌវប្បធម៌។

# ៥.៣. ស្ថានភាព ស.ស.ជ នៅក្នុងសហគមន៍សាសនា/ជំនឿផ្ទាល់ខ្លួន

ផ្នែកនេះស្វែងយល់ពីសេរីភាពសាសនា ឬជំនឿក្នុងចំណោមអ្នកកាន់សាសនា ឬជំនឿផ្សេងៗ ដោយពិនិត្យមើលសិទ្ធិរបស់ពួកគេក្នុងការប្តូរជំនឿ ស្វ័យភាពខាងរូបកាយ និងតួនាទីយេនឌ័រនៅក្នុងការប្រតិបត្តិសាសនា ឬជំនឿរបស់ពួកគេ។

## ៥.៣.១. ការប្រតិបត្តិទូទៅ៖ ជម្រើសនៃការផ្លាស់ប្តូរសាសនា ការកំណត់ការស្លៀកពាក់ ការសម្រេចចិត្តលើរូបកាយ

### ក. ជម្រើសនៃការប្តូរសាសនា

ការផ្លាស់ប្តូរសាសនាកំណើត និងការទទួលយកជំនឿផ្សេងទៀត ត្រូវបាន

បង្ហាញចេញពីការស្ទង់មតិ។ អ្នកចូលរួមផ្តល់ព័ត៌មាន៦៦% បានរាយការណ៍ថា ពួកគេមានសេរីភាពក្នុងការប្តូរទៅសាសនាផ្សេង។ តាមអ្នកចូលរួមផ្តល់ព័ត៌មានខ្លះ បានលើកឡើងថា *"អ្នកកាន់សាសនាព្រះពុទ្ធភាគច្រើនបានប្តូរទៅកាន់សាសនាយេស៊ូខ្លះដែរ"* ប៉ុន្តែ *"អត់មានធ្វើបាបទៅលើបុគ្គលដែលបានប្តូរទៅកាន់សាសនាផ្សេងទេ។"* ដូច្នេះហើយ មនុស្សអាចជ្រើសរើស និងប្តូរសាសនាខ្លួនដោយសេរី ហើយប្រកាន់ខ្ជាប់នូវសាសនា ឬជំនឿតាមជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកចូលរួមផ្តល់ព័ត៌មានច្បាស់ក្នុងចិត្តថា នេះជាជម្រើសផ្ទាល់ខ្លួន។ ក្រុមគ្រួសារ និងមិត្តភ័ក្តិអាចប្រឹក្សា ឬប្រឆាំង ប៉ុន្តែសិទ្ធិក្នុងការ 'ប្តូរសាសនា' គឺជារឿងជំនឿ និងជម្រើសផ្ទាល់ខ្លួន។ អ្នកចូលរួមផ្តល់ព័ត៌មានពីរនាក់បាននិយាយថា *"ជាទឹកចិត្តរបស់គាត់ យើងគ្មានសិទ្ធិឬបង្ខិតបង្ខំឡើយ"* ហើយ *"បើសិនជាមាន[អ្នកប្តូរ] យើងព្យាយាមនិយាយពីព្រោះបន្ទូលព្រះឱ្យគេវិលត្រឡប់មកវិញ ដោយមិនបង្ខិតបង្ខំដោយប្រការណាមួយទេ។"*

| សំណួរៈ តើសមាជិកសហគមន៍របស់អ្នកមាន សេរីភាពប្តូរទៅសាសនាផ្សេងទៀតដោយសេរីឬទេ? | គ្រិស្តសាសនា | ពុទ្ធសាសនា | ឥស្លាមសាសនា | ជនជាតិភាគតិចនិងព្រះពុទ្ធសាសនា | សរុប |
|---|---|---|---|---|---|
| បាទ | ២៤ | ៣៤ | ៨ | ១៣ | ៧៩(៦៦%) |
| ទេ | ១១ | ១១ | ៧ | ២ | ៣១(២៦%) |
| មិនដឹង | ០ | ៨ | ១ | ០ | ៩ |
| សរុប | ៣៥ | ៥៣ | ១៦ | ១៥ | ១១៩ |

តាមការស្ទង់មតិ កត្តាដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូរសាសនា គឺរាប់ចាប់ពីជំនឿ និងបទពិសោធន៍ផ្ទាល់ខ្លួន រហូតដល់ស្ថានភាពសេដ្ឋកិច្ច និងឥទ្ធិពលពីអ្នកដទៃ ដែលនេះឆ្លុះបញ្ចាំងពីភាពចម្រុះនៃការលើកទឹកចិត្តបុគ្គល និងឥរិយាបថសហគមន៍។

## ខ. ការកំណត់ការស្លៀកពាក់

| សំណួរៈ តើសាសនា ឬ ជំនឿរបស់អ្នកកំណត់របៀបស្លៀកពាក់ចាំបាច់ណាមួយឬទេ? | គ្រិស្តសាសនា | ពុទ្ធសាសនា | ឥស្លាមសាសនា | សាសនា និងព្រះពុទ្ធសាសនា | សរុប |
|---|---|---|---|---|---|
| បាទ | ១ | ២៥ | ១៧(៩៤%) | ៥ | ៤៨(៣៩%) |
| ទេ | ៣៤ | ២៨ | ១ | ៨ | ៧២(៥៩%) |
| មិនដឹង | ០ | ១ | ០ | ០ | ១ |
| សរុប | ៣៥ | ៥៤ | ១៨ | ១៣ | ១២១ |

ទិន្នន័យនេះបង្ហាញពីប្រធានបទនៃសេរីភាពផ្ទាល់ខ្លួនក្នុងបរិបទសាសនា និងវប្បធម៌ផ្សេងៗ។ ចំពោះការស្លៀកពាក់វិញ មានគោលការណ៍ណែនាំខ្លះ ដូចជាសេចក្តីណែនាំអំពីភាពថ្លៃថ្នូរ ជាពិសេសនៅក្នុងសហគមន៍ឥស្លាម។ តាមការបង្ហាញក្នុងតារាង អ្នកចូលរួមផ្តល់ព័ត៌មានពីសាសនាឥស្លាម៩៤% បានរាយការណ៍ថា មានរបៀបស្លៀកពាក់ចាំបាច់នៅក្នុងការប្រតិបត្តិសាសនារបស់ពួកគេ។ តាមការបញ្ជាក់ពីអ្នកចូលរួមផ្តល់ព័ត៌មាន *"កំណត់ស្លៀកពាក់ឱ្យជិត យ៉ូឱ្យសល់តែភ្នែក។ ហើយការស្លៀកពាក់បែបនេះហើយវាសំខាន់សម្រាប់សាសនាឥស្លាម។"* និងមួយទៀត *"តាមបុណ្យទានអីតម្រូវឱ្យស្លៀកសំពត់ហូល អាវប៉ាក់ អាវស តាមប្រពៃណី បើអ្នកបញ្ចូលរូបគាត់ស្លៀកស។"*

ទោះជាយ៉ាងណាក៏ដោយ បើនិយាយពីការយល់ឃើញ ឃើញថា៥៩% បញ្ជាក់ថារបៀបស្លៀកពាក់ជាជម្រើសបុគ្គល។ ការស្លៀកពាក់បែបប្រពៃណី និងវប្បធម៌ត្រូវបានគេផ្តល់តម្លៃតាមឱកាសពិសេសនានា ប៉ុន្តែក៏មានការទទួលយកទូទៅនូវរបៀបស្លៀកពាក់នានាតាមចំណូលចិត្ត។ តាមអ្នកចូលរួមផ្តល់ព័ត៌មានបានចែករំលែកថា *"[នៅក្នុងសាសនារបស់ខ្ញុំ] គេបើកសិទ្ធិសេរីភាពក្នុងការស្លៀកពាក់តាមចិត្ត តាមកាលៈទេសៈ"* ហើយ *"ពេលការស្លៀកពាក់កម្មវិធីផ្សេងៗយើងចង់ឱ្យជនជាតិយើង*

*បង្ហាញពីវប្បធម៌យើង ប្រពៃណីយើងដូចអាវមានអាវកម្ពុល ហោប៉ៅអាវពីរ អាវបំពង់ក៏បាន ប៉ុន្តែស្លៀកពាក់អត់ទាន់បានគ្រប់គ្នាទេ។ [ក្នុងពិធីគោរពបូជា]ស្លៀកធម្មតាៗ។ ”*

## គ. ការសម្រេចចិត្តលើរាងកាយ

តាមការធ្វើសម្ភាសមួយទល់នឹងមួយ (Key Informance Interview) អ្នកដឹកនាំសាសនាមានទស្សនៈផ្សេងៗគ្នាទាក់ទងនឹងការសម្រេចចិត្តផ្ទាល់ខ្លួនអំពីរូបកាយរបស់បុគ្គលម្នាក់។ ខណៈពេលសាសនាខ្លះមានគោលជំហរច្បាស់លើបញ្ហាខ្លះដូចជាការរំលូតកូន និងការពន្យារកំណើត ខ្លះទៀតទុកឱ្យបុគ្គលជាអ្នកជ្រើសរើសជាពិសេសនៅពេលគិតគូដល់សុខភាព និងផែនការគ្រួសារ។ ការស្ទង់មតិបានបង្ហាញស្របគ្នាពីស្វ័យភាព និងការបត់បែនតាមកាលៈទេសៈផ្ទាល់ខ្លួនសម្រាប់ករណីការសម្រេចចិត្តលើរាងកាយនេះ។ ខាងក្រោមនេះគឺជាចម្លើយមួយចំនួនដែលបានមកពីក្រុមសាសនា និងជំនឿផ្សេងៗគ្នា ដែលបង្ហាញពីទស្សនៈផ្សេងៗគ្នា។

អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បាននិយាយថា *“[នៅក្នុងសាសនាយើង] អត់អនុញ្ញាត [ឱ្យពន្លូតកូន] ទេ ព្រោះនេះជាការសម្លាប់ជីវិត។”*

*“ពន្យាកំណើតនេះអ៊ីចេះលោកគ្រូ មានករណីលើកលែងដែរ។*
*តាមពិតសារៈមហាម៉ាត់លោកមានប្រសាសន៍ថាឱ្យបានកូនច្រើន*
*ដើម្បីបន្តផៅសណ្តាន [...] តែមានករណីមានឧបសគ្គ គាត់កូនមួយកូនពីរ*
*អត់អីទេ តែចូលកូនបួនគាត់មានឧបសគ្គ គាត់មានទឹកនោមប្រៃទឹកនោមផ្អែម*
*គាត់ប្រសូតអត់បានត្រូវការវះ វាគ្រោះថ្នាក់ដល់អាយុជីវិត។*
*ចឹងលោកអាចឱ្យយើងពន្យាបាន។”*

*“យោងទៅតាម ជំនឿរបស់កួយ ជនជាតិកួយ
ត្រូវបានអនុញ្ញាតឱ្យប្រើវិធីពន្យារកំណើត។”*

*“សាសនាអនុញ្ញាតឱ្យមនុស្សរំលូតកូនបាន។”*

*“ការប្រើការពន្យារកំណើត អាស្រ័យលើគ្រួសារ និងជីវភាពរបស់ពួកគេ។”*

*“ការរំលូតកូនត្រូវបានអនុញ្ញាត។ មិនមានបញ្ហាអ្វីទេ។”*

សរុបមក ការស្ទង់មតិបានបង្ហាញថាក្នុងសហគមន៍សាសនា និងវប្បធម៌ចម្រុះដែលបានសិក្សានេះ មានការផ្តល់តម្លៃ និងគោរពដល់សេរីភាពផ្ទាល់ខ្លួនដល់បុគ្គលម្នាក់ៗក្នុងការស្លៀកពាក់ ការសម្រេចចិត្តលើរាងកាយ ឬការជ្រើសរើសជំនឿសាសនាដែលខ្លួនពេញចិត្ត។

## ៥.៣.២. ស.ស.ជ និងទិដ្ឋភាពយេនឌ័រ

ផលប៉ះពាល់នៃសេរីភាពសាសនា ឬជំនឿ (ស.ស.ជ) លើក្រុមងាយរងគ្រោះនៅក្នុងសហគមន៍កម្ពុជា បង្ហាញពីទំនាក់ទំនងឥទ្ធិពលដែលមានលក្ខណៈពហុវិស័យ និងមានការប្រឈម។ ផ្នែកនេះផ្តោតលើបទពិសោធន៍ជាក់លាក់របស់ស្ត្រី និងមនុស្សមានទំនោរផ្លូវភេទខុសៗគ្នាឬអ្នកស្រលាញ់ភេទដូចគ្នា។ ក្រុមនីមួយៗជួបប្រទះបញ្ហាផ្សេងៗពីគ្នាដែលរងឥទ្ធិពលផ្ទួបគ្នារវាងការបង្រៀនសាសនា បទដ្ឋានវប្បធម៌ និងឥរិយាបថសង្គម។ ពួកគេរួមគ្នាបង្កើតសិទ្ធិ និងការទទួលយករបស់ពួកគេនៅក្នុងសហគមន៍ខ្លួន។

## ក. ស.ស.៨ និងស្ត្រី

### យេនឌ័រ និងភាពជាអ្នកដឹកនាំសាសនានៅកម្ពុជា៖

ស្ត្រីនៅក្នុងប្រទេសកម្ពុជា ឆ្លងកាត់បរិយាកាសស្មុគស្មាញក្នុងបរិបទសាសនា។ តាមជំនឿផ្សេងៗគ្នា តួនាទីជាអ្នកដឹកនាំនៅមានកម្រិតសម្រាប់ស្ត្រី ដែលនេះឆ្លុះបញ្ចាំងពីភាពលម្អៀងផ្នែកយេនឌ័រ ដែលបានចាក់ឫសគល់យ៉ាងជ្រៅ។

### ផ្លូវមិនស្មើគ្នា៖

- **ពុទ្ធសាសនា៖** ទោះបីជាមានការសង្កត់ធ្ងន់លើសមភាពក៏ដោយ ក៏ស្ត្រីមិនមានឱកាសឈានទៅរកតួនាទីជាអ្នកដឹកនាំស្មើនឹងព្រះសង្ឃដែរ។
- **សាសនាឥស្លាម៖** នៅទីនេះ ការរឹតបន្តឹងរឹតតែតឹងរ៉ឹង ជារឿយៗគេហាមស្ត្រីមិនឱ្យដឹកនាំការថ្វាយបង្គំ ឬកាន់តួនាទីលេចធ្លោដូចជា អ៊ីម៉ាម ឬហាគីមឡើយ។
- **គ្រិស្តសាសនា៖** និន្នាការស្រដៀងគ្នានេះកំពុងកើតមាន ព្រោះស្ត្រីត្រូវបានហាមឃាត់មិនឱ្យធ្វើជាគ្រូគង្វាល ហើយជារឿយៗត្រូវបានគេមើលឃើញថាមានសិទ្ធិអំណាចខាងសាសនាតិចជាងបុរស។
- **ជំនឿខាងព្រលឹងវិញ្ញាណ៖** ខណៈពេលប្រពៃណីទុកភាពជាអ្នកដឹកនាំសហគមន៍ដល់បុរស អ្វីដែលគួរឱ្យចាប់អារម្មណ៍ តួនាទីរបស់ស្នងរូបជាន់អារក្សគឺសម្រាប់តែស្ត្រីប៉ុណ្ណោះ។

ការរឹតបន្តឹងភាពជាអ្នកដឹកនាំទាំងនេះក៏អមមកជាមួយនឹងគោលការណ៍ចែកមរតកដែលមានភាពលម្អៀងលើយេនឌ័រ ដោយផ្តល់អាទិភាពដល់បុរស ជាហេតុ

បង្កើនវិសមភាពសេដ្ឋកិច្ចបន្ថែមទៀត។ សម្រាប់ស្ត្រីតស្លាម យ៉ាងហោចណាស់មានពន្លឺសង្ឃឹមខ្លះៗទាក់ទងនឹងច្បាប់ចែកមរតក៖

*"និយាយពីរឿងមរតក [...] ខ្ញុំចាំមិនច្បាស់ ប្រហែលជាកូនប្រុសហ្នឹងត្រូវទទួលមរតកច្រើនជាងកូនស្រីបន្តិច។ តែទស្សនៈហ្នឹងខ្ញុំកំពុងតែគិតគូរ តើយើងអាច [ធ្វើ] វិសោធនកម្មច្បាប់ហ្នឹងបានឬអត់។ ដែលភាគច្រើនជំនាន់ក្រោយពួកម៉ាកខ្ញុំដែលរៀនបានខ្ពង់ខ្ពស់ ប្រឹក្សារឿងហ្នឹងថាយើងគួរ [ធ្វើ] វិសោធនកម្មច្បាប់ហ្នឹងកើតឬមិនកើត? ធ្វើដូចម្ដេចដើម្បីកូនប្រុសកូនស្រីរស់នៅក្នុងគ្រួសារតែមួយហ្នឹងឱ្យទទួលបានមរតគ្រួសារស្មើៗគ្នា។ ដោយសារហេតុអ្វី? ដោយសារហេតុថានៅពេលដែលឪពុកនៅរស់ជួនកាលទាំងកូនប្រុសហ្នឹងមិនបានបម្រើឪពុកហ្នឹងស្មើនឹងកូនស្រីទេ។"*

លើសពីនេះ ជំនឿប្រពៃណីបានបង្អាក់ស្ត្រីមិនឱ្យបន្តការអប់រំ ជាហេតុដាក់កំហិតដល់ការអភិវឌ្ឍផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ពួកគេ។ សាកលភាវូបនីយកម្ម និងបទដ្ឋានសង្គមបច្ចុប្បន្ន បានជំរុញឱ្យមានការផ្លាស់ប្ដូរឥរិយាបថបន្តិចម្ដងៗចំពោះការផ្ដល់ឱកាសអប់រំដល់ស្ត្រី ដោយឡែកការវិវត្តឥរិយាបថនេះនៅតែមានភាពយឺតយ៉ាវ និងមិនស៊ីសង្វាក់គ្នានៅក្នុងបរិបទសហគមន៍សាសនា។ អ្នកចូលរួមផ្ដល់ព័ត៌មានម្នាក់បាននិយាយថា៖

> ***[សិទ្ធិទទួលបានការអប់រំ រវាងក្មេងប្រុស និងក្មេងស្រី] មិនទាន់ស្មើគ្នាទេ។ ព្រោះគេគិតថាក្មេងស្រីមិនគួររៀនច្រើនទេ។***

*“[នៅក្នុងសាសនាខ្ញុំ មនុស្ស] មានគំនិតដូចគ្នា ព្រោះស្ត្រីគួរតែ ធ្វើការងារផ្ទះ មើលថែកូនចៅទៅល្អហើយ។”*

ខណៈពេលសាសនាមួយចំនួនបង្ហាញសញ្ញានៃការវិវត្តជំនឿដែលរងឥទ្ធិពលពីសកលភាវូបនីយកម្ម និងការផ្លាស់ប្តូរបទដ្ឋានសង្គម ការវិវត្តនេះមិនមានភាពជាប់លាប់ឡើយ។ លើសពីនេះ អន្តរកម្មនៃជំនឿវប្បធម៌ និងការបង្រៀនសាសនាបង្កភាពស្មុគស្មាញដល់តួនាទី និងសមភាពយេនឌ័រ ធ្វើឱ្យស្ត្រីពិបាកទទួលបានសមភាពពិត និងបរិយាបន្នក្នុងសហគមន៍សាសនារបស់ពួកគេ។

តាមអ្នកចូលរួមផ្តល់ព័ត៌មានបាននិយាយថា៖

*“នៅក្នុងសាសនារបស់ខ្ញុំមានការផ្លាស់ប្តូរផ្នត់គំនិតបែបនេះអស់ហើយ។ នៅក្នុងសាសនាឥស្លាម ស្ត្រីអាចមានតួនាទីក្លាយជាក្រុមប្រឹក្សាស្រុកក្រុមប្រឹក្សាឃុំ ហើយស្ត្រីខ្លះមានតួនាទីនៅក្នុងថ្នាក់រដ្ឋសភាក៏មានផងដែរ។ នេះក៏ដោយសារតែស្ត្រីបានរៀនសូត្រខ្ពង់ខ្ពស់។ ប៉ុន្តែក៏នៅតែមានចំនួនតិចជាងបុរសដែលបានសិក្សារៀនសូត្រ។ មានន័យថាបុរសទទួលបានការអប់រំច្រើនជាងស្ត្រី។ ភាគច្រើនគឺមានតែបុរសទេដែលអាចសិក្សាទៅដល់ក្រៅប្រទេសបាន។ ប្រសិនបើស្ត្រីវិញគឺមិនសូវមាននោះទេ។ ដោយសារតែឪពុកម្តាយមិនហ៊ានបណ្តោយឱ្យកូនស្រីទៅរៀនឆ្ងាយនោះទេ។”*

*“ខ្ញុំគិតថាច្បាស់ជាគេឱ្យតម្លៃទៅលើបុរសច្រើនជាង ព្រោះបុរសអាចដើរបានឆ្ងាយជាងស្ត្រី ដោយមានសុវត្ថិភាព។ ប៉ុន្តែស្ត្រីគឺពិបាកក្នុងការទៅខាងក្រៅជាងបុរស ដោយសារតែស្ត្រីត្រូវបានបិទសិទ្ធិសេរីភាពក្នុងការចេញក្រៅច្រើន។”*

*“ស្ត្រីមិនទទួលបានសិទ្ធិធ្វើអ្វីតាមចិត្តពេញលេញដូចជាបុរសនោះទេ។
ឧទាហរណ៍ បុរសអាចធ្វើការងារពេលយប់ ឬដើរពេលយប់បាន
តែស្ត្រីមិនអាចទេព្រោះអីខ្លាច។”*

សរុបមក ទិដ្ឋភាព ស.ស.ជ សម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា បង្ហាញពីវិសមភាព និងបញ្ហាប្រឈមធំៗ។ ស្ត្រីប្រឈមមុខនឹងភាពលម្អៀងយេនឌ័រត្រង់ការដាក់កំហិតលើតួនាទី និងសិទ្ធិនៅក្នុងបរិបទសាសនា។ យើងឃើញមានកម្រិតខុសគ្នា និងប្រភេទរើសអើងយេនឌ័រតាមសាសនា ហើយទម្រង់វិសមភាព និងការរឹតបន្តឹងនៅតែបន្តមាន។ អន្តរកម្មនៃការបង្រៀនសាសនា បទដ្ឋានវប្បធម៌ និងការវិវត្តឥរិយាបថសង្គម បានជួយឱ្យមានការផ្លាស់ប្តូរតួនាទីយេនឌ័រ និងការទទួលយកសមភាពយេនឌ័រនៅក្នុងសហគមន៍សាសនា។ បុគ្គលស្រលាញ់ភេទដូចគ្នាជួបប្រទះការរើសអើង និងការផាត់ចេញនៅក្នុងបរិបទដែលមិនមានការទទួលយកពីសង្គម។

ការដោះស្រាយបញ្ហាទាំងនេះទាមទារឱ្យមានការយល់ដឹងច្បាស់លាស់អំពីអន្តរកម្មរវាងការបង្រៀនសាសនា បទដ្ឋានវប្បធម៌ និងឥរិយាបថសង្គមដែលកំពុងវិវត្ត។ ការខិតខំរួមគ្នាក៏ចាំបាច់ត្រូវមានផងដែរ ដើម្បីលើកកម្ពស់បរិយាបន្ន និងការពារសិទ្ធិរបស់បុគ្គលទាំងអស់នៅក្នុងសហគមន៍ទាំងនេះ។

## ខ. ស.ស.ជ និងអ្នកស្រលាញ់ភេទដូចគ្នា

លទ្ធផលស្ទង់មតិបង្ហាញពីទិដ្ឋភាពស្មុគស្មាញនៃឥរិយាបថ និងការអនុវត្តចំពោះបុគ្គលស្រលាញ់ភេទដូចគ្នា នៅក្នុងសហគមន៍សាសនាផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។ ឥរិយាបថទាំងនេះ ដែលរងឥទ្ធិពលពីការបង្រៀនសាសនាបែបប្រពៃណី

ជារឿយៗបង្កឱ្យមិនសូវមានការទទួលយកពួកគេ បង្កជាការរើសអើង និងបង្កឱ្យមានការប្រព្រឹត្តិមិនស្មើភាពចំពោះពួកគេ។ នេះឆ្លុះបញ្ចាំងពីភាពលម្អៀងខ្លាំងដែលបង្កឧបសគ្គដល់ការផ្តល់សិទ្ធិ និងការទទួលយកបុគ្គលស្រលាញ់ភេទដូចគ្នា ។

នៅក្នុងសហគមន៍គ្រិស្តសាសនិក បុគ្គលស្រលាញ់ភេទដូចគ្នា មិនសូវមានការទទួលស្គាល់ឡើយ។ អ្នកចូលរួមផ្តល់ព័ត៌មានខ្លះបង្ហាញពីការយោគយល់ ប៉ុន្តែមិនមែនជាការទទួលស្គាល់ ឬផ្តល់ភាពស្មើគ្នាទាំងស្រុងឡើយ។ ការបកស្រាយខាងប្រពៃណីក្នុងការបង្រៀនរបស់គ្រិស្តសាសនិក ជារឿយៗបង្កជាការរឹតត្បិតបុគ្គលស្រលាញ់ភេទដូចគ្នាក្នុងការចូលរួមប្រតិបត្តិសាសនា។ អ្នកចូលរួមផ្តល់ព័ត៌មានជាច្រើនចាត់ទុកការក្លាយជាអ្នកស្រលាញ់ភេទដូចគ្នាជាអំពើបាបធ្ងន់ ដែលអាចជួបនឹងផលវិបាកធ្ងន់ធ្ងរមួយចំនួន មានដូចជាការបដិសេធមិនទទួលយក អំពើហិង្សា និងការបដិសេធមិនបញ្ចុះសពឱ្យ។ នេះឆ្លុះបញ្ចាំងពីកង្វះការទទួលយក និងការគោរពជាខ្លាំង។

*“ទំនាក់ទំនងផ្លូវភេទផ្សេងពីអាពាហ៍ពិពាហ៍ប្រុសស្រី ត្រូវបានចាត់ទុកថាជាការខកខានបំពេញគោលបំណងព្រះនៅក្នុងព្រះគម្ពីរសម្រាប់មនុស្សជាតិ។”*

បើដកជំនឿចេញ ចម្លើយផ្តល់ពីសហគមន៍អាចមានការប្រែប្រួល៖

សហគមន៍ឥស្លាមបង្ហាញទំនោរទទួលយកតិចតួចចំពោះបុគ្គលស្រលាញ់ភេទដូចគ្នា។ ខណៈពេលអ្នកចូលរួមផ្តល់ព័ត៌មានខ្លះអាចយោគយល់បុគ្គលស្រលាញ់ភេទដូចគ្នា តែការទទួលយកពេញលេញគឺកម្រមានណាស់។ កិច្ចខិតខំលើកកម្ពស់សិទ្ធិនិងសមភាពរបស់ស្ត្រី តែងតែកើតមានទទ្ទឹមគ្នានឹងវិសមភាពយេនឌ័រ និងនិន្នាការផ្លូវភេទ។ មតិភាគតិចនៃអ្នកចូលរួមផ្តល់ព័ត៌មានទទួលស្គាល់ថា បុគ្គលស្រលាញ់ភេទដូចគ្នាប្រឈមនឹងការរើសអើង អំពើហិង្សា ឬការបណ្តេញចេញពីសហគមន៍ខ្លួន ដែល

នេះបង្ហាញពីហានិភ័យ និងបញ្ហាប្រឈមធំៗដែលពួកគេជួបប្រទះ។

*“អត់ទេ! គេមិនឱ្យតម្លៃអ្នកស្រឡាញ់ភេទដូចគ្នាទេ។
បើរាប់អានគ្នាមិត្តភក្តិ សាច់ញាតិអី មិនអីទេ តែបើស្រឡាញ់គ្នាប្តីប្រពន្ធ
មិនបានទេ គេមិនឱ្យតម្លៃទេ។”*

*“មានមនុស្សស្រលាញ់ភេទដូចគ្នានៅក្នុងសហគមន៍ខ្ញុំ។
ប៉ុន្តែក្នុងសាសនា រឿងនេះត្រូវបានហាមប្រាមខ្លាំង។”*

នៅក្នុងសហគមន៍ពុទ្ធសាសនា ការបង្រៀនបែបប្រពៃណីអាចលើកមកពន្យល់បកស្រាយពីភាពខុសគ្នានៅក្នុងតួនាទីយេនឌ័រ ដូចជាការមិនរាប់បញ្ចូលស្ត្រីនៅក្នុងតួនាទីជាព្រះសង្ឃជាដើម។ គោលលទ្ធិក្នុងការបង្រៀនបែបនេះបន្តឥទ្ធិពលដល់ឥរិយាបថចំពោះបុគ្គលស្រលាញ់ភេទដូចគ្នា ដែលជារឿយៗគេផ្តោតទៅលើការអប់រំ និងការយល់ដឹងជាជាងការទទួលយកឬការបដិសេធទាំងស្រុង។ វិធីនេះអាចនាំឱ្យមានការទទួលយកបុគ្គលស្រលាញ់ភេទដូចគ្នា ប៉ុន្តែនៅមានកម្រិត ដោយការអប់រំអំពីបញ្ហាអ្នកស្រលាញ់ភេទដូចគ្នាត្រូវបានលើកទឹកចិត្ត ប៉ុន្តែការទទួលយកពួកគេទាំងស្រុងនៅតែមិនទាន់មានភាពប្រាកដ។

*“[...] នៅភូមិមានស្រីស្រឡាញ់ស្រី។ អ្នកភូមិទទួលយកនិងឱ្យតម្លៃគាត់
អត់មានអ្នករើសអើងគាត់ទេ។”*

*“ទេមិនអាចប្រើហិង្សា ឬបណ្តេញគេចេញទេ។ ជាសិទ្ធិរបស់គេ
បើគេស្រឡាញ់ [ភេទដូចគ្នា] ក៏ស្រឡាញ់ទៅ។”*

ទោះមានការលើកទឹកចិត្ត និងចម្លើយគាំទ្របែបសង្គមបរិយាបន្នក្តី បុគ្គលដែលមានអត្តសញ្ញាណភេទផ្សេងៗ និងអ្នកស្រឡាញ់ភេទដូចគ្នា នៅតែប្រឈមនឹងបញ្ហាច្រើននៅក្នុងសហគមន៍សាសនា។ សាសនាជាច្រើនប្រើទស្សនៈឆ្លងសីលធម៌មកវិនិច្ឆ័យបុគ្គលស្រលាញ់ភេទដូចគ្នា ជាហេតុឈានដល់ការផាត់ពួកគេចេញពីសង្គម និងមានការរើសអើងលើពួកគេ។ ចំណុចនេះឃើញមានក្នុងមធ្យោបាយផ្សេងៗ រួមទាំងការផាត់ចេញពីពិធីសាសនា និងព្រឹត្តិការណ៍សហគមន៍ ហើយបើក្នុងករណីធ្ងន់ធ្ងរវិញគឺការបំពានដោយពាក្យសម្តី ឬការបំពានលើរាងកាយ។ ទាំងការថ្កោលទោសពីខាងសាសនា រួមគ្នានឹងការប្រកាន់បញ្ហាកេរ្តិ៍អសោចខាងវប្បធម៌ បង្កើតជាបរិយាកាសរារាំងដល់បុគ្គលអ្នកស្រលាញ់ភេទដូចគ្នា ជាហេតុដាក់កំហិតលើលទ្ធភាពបង្ហាញអត្តសញ្ញាណរបស់ពួកគេដោយចំហ។ សហគមន៍មួយចំនួនអាចយោគយល់ដល់អ្នកស្រលាញ់ភេទដូចគ្នា ប្រសិនបើពួកគេមិនសូវជាបង្ហាញអត្តសញ្ញាណច្បាស់ៗពេក។ ប៉ុន្តែករណីបើកចំហខ្លាំង ជារឿយៗគឺរងពិន័យពីសង្គមខ្លាំង។ កិច្ចខិតខំលើកកម្ពស់ការទទួលយក និងការយោគយល់គឺកើតមានជាបណ្តើរៗ ហើយជាទូទៅខ្វះការគាំទ្រពីស្ថាប័នសាសនា ជាហេតុធ្វើឱ្យការតស៊ូមតិសម្រាប់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងបរិបទទាំងនេះមានភាពលំបាក។

អ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បាននិយាយថា *"បើសិនជាមានអ្នកស្រឡាញ់ភេទដូចគ្នាអ៊ីចឹងមែន ព្រះអង្គថាគឺជាអំពើបាប។ គឺជាទង្វើផិតក្បត់ មិនអាចឱ្យរួមភេទរវាងស្ត្រីហើយនឹងស្ត្រី ឬក៏បុរសជាមួយបុរសបានទេ។ បើសិនជាមានអ្នកស្រលាញ់ភេទដូចគ្នា គឺមិនមានការទទួលស្គាល់ទេ និងមានការបណ្តេញចេញឱ្យទៅរស់នៅតែពីរនាក់។"*

ជារួមទិន្នន័យស្ទង់មតិបានគូសបញ្ជាក់ថា ការបង្រៀន និងការប្រតិបត្តិសាសនានៅក្នុងប្រទេសកម្ពុជា មានឥទ្ធិពលខ្លាំងទៅលើឥរិយាបថចំពោះបុគ្គលស្រលាញ់ភេទ

ដូចគ្នា ដែលជារឿយៗបណ្តាលឱ្យមានការទទួលយកពួកគេនៅមានកម្រិត និងមានបញ្ហាប្រឈមធំៗ។ ភាពលម្អៀងដែលចាក់ឫសគល់ក្នុងសាសនាទាំងនេះ រួមចំណែកបង្កជាបរិយាកាសមួយដែលបុគ្គលស្រលាញ់ភេទដូចគ្នា ជួបការលំបាកក្នុងការទទួលបានការទទួលស្គាល់ សមភាព និងការគោរពនៅក្នុងសហគមន៍របស់ពួកគេ។ អន្តរកម្មនៃជំនឿ ប្រពៃណី និងសម្ពាធសង្គមសម័យទំនើបបណ្តាលឱ្យបុគ្គលស្រលាញ់ភេទដូចគ្នាបន្តជួបបទពិសោធន៍ទាំងនេះ ដែលនេះបង្ហាញពីតម្រូវការឱ្យមានការសន្ទនា និងការជម្រុញឱ្យមានបរិយាបន្ន និងការយោគយល់កាន់តែច្រើនជាងមុន។

សរុបសេចក្តីមក សេរីភាពសាសនា ឬជំនឿរបស់បុគ្គលនៅក្នុងការសិក្សានេះហាក់ត្រូវបានធានាយ៉ាងល្អនៅពេលពិនិត្យទៅលើជម្រើសផ្លាស់ប្តូរជំនឿ និងការសម្រេចចិត្តរបស់ពួកគេលើរូបកាយ។ អ្នកចូលរួមផ្តល់ព័ត៌មានភាគច្រើនមានអារម្មណ៍ថាមានសេរីភាពក្នុងការប្តូរទៅជឿសាសនាផ្សេង ដោយមិនប្រឈមនឹងការជំទាស់ ដែលនេះបញ្ជាក់ថាពួកគេមានសេរីភាពលើជម្រើសផ្ទាល់ខ្លួន។ ទោះបីពេលខ្លះក្រុមគ្រួសារ និងមិត្តភ័ក្តិអាចនឹងធ្វើការណែនាំក្តី ការសម្រេចចិត្តចុងក្រោយគឺឋិតលើបុគ្គលខ្លួនឯង។ ការកំណត់ទៅលើរបៀបស្លៀកពាក់មានភាពខុសប្លែកគ្នាតាមគោលការណ៍ណែនាំសាសនាមួយចំនួន ដូចជាការរក្សាភាពស្រគត់ស្រគំនៅក្នុងសាសនាឥស្លាម ប៉ុន្តែជារួមអ្នកចូលរួមផ្តល់ព័ត៌មានភាគច្រើនបង្ហាញពីសេរីភាពបុគ្គលថាមានជម្រើសស្លៀកពាក់ ក្នុងនោះសម្លៀកបំពាក់ប្រពៃណីគឺត្រូវបានប្រើជាញឹកញាប់សម្រាប់ឱកាសពិសេសៗ។ ជំនឿលើការសម្រេចចិត្តលើរាងកាយដូចជាការរំលូតកូន និងការពន្យារកំណើត មានភាពខុសប្លែកគ្នាទៅតាមសាសនា។ អ្នកខ្លះប្រឆាំងនឹងការរំលូតកូនយ៉ាងតឹងរ៉ឹង ដោយចាត់ទុកថាវាជាអំពើឃាតកម្ម ខណៈអ្នកផ្សេងទៀតទទួលយកការពន្យារកំណើតដោយសារកត្តាសុខភាព និងស្វ័យភាពផ្ទាល់ខ្លួន។ ស្ត្រីនៅក្នុងសហគមន៍សាសនាកម្ពុជាប្រឈមនឹងភាពលម្អៀងយេនឌ័រខ្លាំង ក្នុងនោះគឺការដាក់កំហិតលើតួនាទីខ្លួនក្នុងការដឹកនាំនៅក្នុងពុទ្ធសាសនា សាសនាឥស្លាម គ្រិស្តសាសនា

និងជំនឿខាងព្រលឹងវិញ្ញាណ។ បទដ្ឋានវប្បធម៌ និងគោលការណ៍បែងចែកកេរមរតក បង្កើតបន្ថែមនូវវិសមភាពខាងសេដ្ឋកិច្ច បើទោះបីជាមានការវិវត្តខ្លះដោយសារការផ្លាស់ប្តូរឥរិយាបថសង្គមក៏ដោយ។ បុគ្គលស្រលាញ់ភេទដូចគ្នាជួបការលំបាកក្នុងការទទួលយកពីសហគមន៍ ការរើសអើង និងការប្រកាន់ជ្រុលក្នុងបរិបទសហគមន៍សាសនា។ ការបង្រៀន ខាងប្រពៃណី ជារឿយៗឈានទៅដល់ការផាត់ពួកគេចេញពីការប្រតិបត្តិសាសនា និងការពិន័យពីសង្គម ជាហេតុតម្រូវឱ្យមានការជំរុញឱ្យមានឥរិយាបទ្ធ និងការតស៊ូមតិសម្រាប់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាច្រើនជាងមុន។

# ៥.៤. ទំនាក់ទំនងអន្តរជំនឿ

ផ្នែកនេះស្វែងយល់ពីទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងចំណោមក្រុមសាសនា ឬជំនឿផ្សេងៗគ្នា ដោយផ្តោតលើទំនាក់ទំនងរបស់ពួកគេ អន្តរកម្ម និងកត្តាផ្សាភ្ជាប់ទំនាក់ទំនងដូចជា ជំនឿប្រពៃណី ទំនៀមទម្លាប់ និងការទទួលយកការរៀនសូត្រពីគុណតម្លៃគ្នាទៅវិញទៅមក។

## ៥.៤.១. ទំនាក់ទំនងអន្តរជំនឿក្នុងសហគមន៍

ទំនាក់ទំនងអន្តរជំនឿនៅក្នុងសហគមន៍កម្ពុជាបង្ហាញពីភាពស្មុគស្មាញ ប៉ុន្តែមានភាពវិជ្ជមានច្រើន ដោយសម្គាល់បានតាមរយៈកិច្ចខិតខំប្រឹងប្រែងឱ្យមានកិច្ចសន្ទនា ការជំរុញឱ្យមានការគោរពគ្នាទៅវិញទៅមក និងការសិក្សាស្វែងយល់អំពីការប្រតិបត្តិសាសនារបស់គ្នាទៅវិញទៅមក។ ថ្វីបើមានឧបសគ្គក៏ដោយ មនោសញ្ចេតនាជារួមគឺការសហការគ្នាគោលដៅរួមគ្នា និងឆន្ទៈក្នុងការរួមចំណែកដល់ការចុះសម្រុងគ្នានៅក្នុងសហគមន៍។ ប៉ុន្តែមានភស្តុតាងពីអ្នកដឹកនាំសាសនា ចេញពីការសន្ទនាមួយទល់មួយ (KII) ដែលបង្ហាញថា

មានចំណុចព្រួយបារម្ភផងដែរទាក់ទងនឹងការយោគយល់គ្នា។




តាមតួលេខបង្ហាញក្នុងតារាងទិន្នន័យនេះ លើកលែងសាសនាឥស្លាមចេញ សាសនាភាគតិចផ្សេងទៀតបានបង្ហាញថាពួកគេប្រឈមនឹងការបៀតបៀនខ្លះ ក្នុងនោះអ្នកមានបញ្ហាបំផុតគឺអ្នកប្រតិបត្តិជំនឿខាងព្រលឹងវិញ្ញាណ។ អ្នកចូលរួមផ្តល់ព័ត៌មានជិត ២៧%បានជួបប្រទះការបៀតបៀនសាសនា ឬការរើសអើង។

## ៥.៤.២. ជំនឿ និងការប្រតិបត្តិប្រពៃណី

ទោះជាយ៉ាងណាក៏ដោយ ជំនឿ និងទំនៀមទម្លាប់ប្រពៃណីនៅតែជាផ្នែកមួយនៃសហគមន៍ជាច្រើន ដែលជាមធ្យោបាយប្រមូលផ្តុំវប្បធម៌ និងសង្គមសំខាន់ៗ។ ពិធីទាំងនេះមានសារៈសំខាន់សម្រាប់ការប្រាស្រ័យទាក់ទង និងការរៀបចំផែនការក្នុងសហគមន៍ ដោយជួយពង្រឹងសម្ព័ន្ធសង្គមតាមរយៈបេតិកភណ្ឌវប្បធម៌រួម។ ជាឧទាហរណ៍

នៅពេលធ្វើសម្ភាស អ្នកដឹកនាំសាសនាជាច្រើនបាននិយាយថា ពិធីសាសនា និងពិធីបុណ្យផ្សេងៗ ដូចជាពិធីបុណ្យសព និងបុណ្យណូអែល គឺជារឿងសំខាន់ក្នុងការនាំសាសនានានាជួបជុំគ្នា។ តាមអ្នកដឹកនាំសាសនាម្នាក់បាននិយាយៈ

*“[...] ហើយពេលខ្លះ ខាងសហគមន៍ក៏មានការរៀបចំពេលមានបុណ្យចូលឆ្នាំ និងថ្ងៃប្រសូតរបស់ពុទ្ធសាសនា យើងអញ្ជើញគ្រប់សាសនាមកជួបជុំ។ ឧទាហរណ៍ ពួកគាត់សាសនាផ្សេងៗមកជួបជុំគ្នា គាត់អាចបួងសួង អធិដ្ឋានផ្សេងៗគ្នា។”*

## ៥.៤.៣. ការអនុវត្តកិច្ចសន្ទនាអន្តរជំនឿ

កម្មវិធី និងការពិភាក្សាអន្តរជំនឿពាំនាំសមាជិកពីសាសនាផ្សេងៗគ្នាដើម្បីពិភាក្សាអំពីបញ្ហាសហគមន៍ កង្វល់សង្គម បញ្ហាប្រឈមបរិស្ថាន និងប្រធានបទសាសនា។ កម្មវិធីទាំងនេះបង្កើតវេទិកាសម្រាប់ការរៀនសូត្រពីគ្នា និងការសន្ទនាគ្នាទៅវិញទៅមក ដែលជួយឱ្យអ្នកចូលរួមស្វែងយល់ និងប្រៀបធៀបការបង្រៀនសាសនា ដូចជាភាពខុសគ្នារវាងទ្រឹស្តីពីភាសាបាលី និងភាសាសម្រាយជាដើម។ លើសពីនេះ សមាជិកសហគមន៍ជារឿយៗសហការលើសកម្មភាពរួមគ្នា ដើម្បីដោះស្រាយគោលដៅរួមទាក់ទងនឹងការបណ្តុះបណ្តាល ការអប់រំ និងសុខភាព ដោយសង្កត់ធ្ងន់លើតម្លៃ និងគោលបំណងដែលបង្រួបបង្រួមមនុស្សដែលមានជំនឿចម្រុះ។ អ្នកដឹកនាំសាសនាម្នាក់បាននិយាយថា *“ចាស! មួយរយៈមុនយើងមានកម្មវិធីមួយឈ្មោះថាអន្តរជំនឿ។ យើងអញ្ជើញសាសនាខុសៗគ្នាដើម្បីឱ្យយើងផ្សព្វផ្សាយនិងយល់ពីគ្នាទៅវិញទៅមក ដោយមិនគិតពីការរើសអើងសាសនាមួយទៅមួយ។ ពីកន្លងមកដល់ពេលដែលយើងធ្វើកម្មវិធី យើងតែងតែអញ្ជើញសាសនាផ្សេងៗនៅចូលរួមជាមួយគ្នាដោយមិនមានការរើសអើងអ្វីទេ ហើយអាចចងក្រងក្រុមបានទៀត។”* ម្នាក់ទៀតបាននិយាយថា *“យើងចង់*

*មានពិធីបុណ្យអន្តរសាសនាដែលនិយាយអំពីសាសនានីមួយៗដើម្បីឱ្យអ្នករាល់គ្នាបានយល់។”*

### ៥.៤.៤. ការគោរព និងសុខដុមរមនាអន្តរជំនឿ




ទោះបីជាមានការយាយី ឬការរើសអើងខ្លះក៏ដោយ ការចូលរួមក្នុងពិធីបុណ្យសាសនារបស់គ្នាទៅវិញទៅមកមិនមែនជារឿងចម្លែកទេ ហើយ ៥៧% នៃអ្នកដឹកនាំសាសនាដែលត្រូវបានធ្វើការស្ទង់មតិ បានចែករំលែកពីការចូលរួមក្នុងពិធីបុណ្យសាសនាផ្សេងទៀត។ ការចូលរួមអបអរសាទរពិធីបុណ្យផ្សេងពីសាសនាខ្លួន ជាពិសេសនៅពេលមានការបង្ហាញគំរូពីអ្នកដឹកនាំសាសនា គឺមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសុខដុមរមនាអន្តរជំនឿ និងការបង្ការការបៀតបៀន និងការរើសអើង។

សមាជិកសហគមន៍មានឆន្ទៈរៀនអំពីសាសនាផ្សេងទៀត ដោយសារចិត្តចង់យល់អំពីជំនឿ ការប្រតិបត្តិ និងហេតុផលជាមូលដ្ឋានរបស់ពួកគេ។ គំនិតផ្តួចផ្តើមក្នុងវិស័យអប់រំ

ដូចជាកម្មវិធីបណ្ដុះបណ្ដាលដែលបើកសម្រាប់បុគ្គលគ្រប់សាសនា គួសបញ្ជាក់ពីការប្ដេជ្ញាចិត្តនេះក្នុងការរៀនសូត្រផ្នែកអន្តរសាសនា។ សមាជិកសហគមន៍មួយចំនួនក៏ចូលរួមក្នុងពិធីសាសនា និងពិធីបុណ្យផ្សេងៗផងដែរ ដោយផ្ដល់ឱកាសក្នុងការរៀនសូត្រផ្ទាល់ និងពង្រឹងទំនាក់ទំនងអន្តរជំនឿ។ ពិធីបុណ្យរួមគ្នា ដូចជាការចែកអាហារ ឬអំណោយក្នុងពិធីបុណ្យសាសនា បង្ហាញពីការគោរពយ៉ាងជ្រាលជ្រៅ និងការចូលរួមក្នុងប្រពៃណីទៅវិញទៅមក។ អ្នកចូលរួមផ្ដល់ព័ត៌មានម្នាក់និយាយថា *"សកម្មភាពដែលនាំអ្នកប្រតិបត្តិសាសនាផ្សេងគ្នាមករួមគ្នាបានគឺ មានសកម្មភាពដាំដើមឈើរួមគ្នា សិក្ខាសាលា កម្មវិធីលែងកូនត្រី កម្មវិធីសិទ្ធិមនុស្ស សិទ្ធិនារីអីក៏ធ្វើបានឱ្យតែចង់ធ្វើ ហើយមានលុយ។"*

## ៥.៤.៥. ការសិក្សាអំពីជំនឿ និងការប្រតិបត្តិសាសនារបស់គ្នាទៅវិញទៅមក




សមាជិកសហគមន៍មានឆន្ទៈរៀនអំពីសាសនាផ្សេងទៀត ដោយសារចិត្តចង់យល់អំពីជំនឿ ការប្រតិបត្តិ និងហេតុផលជាមូលដ្ឋានរបស់ពួកគេ។ គំនិតផ្ដួចផ្ដើមក្នុងវិស័យអប់រំ

ដូចជាកម្មវិធីបណ្តុះបណ្តាលដែលបើកសម្រាប់បុគ្គលគ្រប់សាសនា គូសបញ្ជាក់ពីការប្តេជ្ញាចិត្តនេះក្នុងការរៀនសូត្រផ្នែកអន្តរសាសនា។ សមាជិកសហគមន៍មួយចំនួនក៏ចូលរួមក្នុងពិធីសាសនា និងពិធីបុណ្យផ្សេងៗផងដែរ ដោយផ្តល់ឱកាសក្នុងការរៀនសូត្រផ្ទាល់ និងការយល់ដឹងស៊ីជម្រៅ។ អ្នកដឹកនាំសាសនា ៨៧% បានប្រកាសថា ជំនឿរបស់ពួកគេមិនបានរារាំងខ្លួនមិនឱ្យសិក្សាសាសនា និងជំនឿរបស់អ្នកដទៃទេ។ នេះបង្ហាញពីការបើកចំហចំពោះឱកាសសិក្សាអន្តរជំនឿ។ តាមអ្នកផ្តល់ព័ត៌មានម្នាក់បានរាយការណ៍ថា៖

*“ពេលយើងនិយាយពីព្រះយេស៊ូទៅ គាត់ថាព្រះយេស៊ូហ្នឹងយ៉ាងម៉េច?*
*អ៊ីចឹងទៅគាត់មកវិហារមកថ្វាយបង្គំ គាត់ចង់ដឹងពីរបៀបនៃការថ្វាយបង្គំ*
*អ្នកជឿលើព្រះយេស៊ូរបៀបយ៉ាងម៉េច ហើយគាត់មកគាត់ឃើញ*
*របៀបរបបរាក់ទាក់របស់អ្នកជឿព្រះយេស៊ូទៅ យូរៗទៅគាត់ជឿព្រះយេស៊ូដែរទៅ។”*



## ៥.៤.៦. ការរៀនពីតម្លៃ និងឥទ្ធិពលសាសនាមកលើសហគមន៍មូលដ្ឋាន




ឥទ្ធិពលនៃតម្លៃសាសនាលើសហគមន៍មូលដ្ឋានមានសារៈសំខាន់ណាស់ ព្រោះរួមចំណែកដល់ការកសាងសហគមន៍ និងការអភិវឌ្ឍសង្គម។ ពិធីសាសនា និងព្រឹត្តិការណ៍នានាតែងជាឱកាសក្នុងការខិតខំធ្វើការរួមគ្នា ដូចជាការសាងសង់ផ្លូវ និងគំនិតផ្តួចផ្តើមទឹកស្អាត។ នេះបង្ហាញពីឥទ្ធិពលវិជ្ជមាននៃតម្លៃសាសនាមកលើសុខុមាលភាពសហគមន៍។ អ្នកដឹកនាំសាសនាម្នាក់ៗដែលចូលរួមផ្តល់ព័ត៌មានយល់ថា សាសនានីមួយៗលើកកម្ពស់ការសាងអំពើល្អ ការយល់ដឹង ការគោរព និងកិច្ចសហប្រតិបត្តិការ ដែលបញ្ជាក់ពីអត្ថប្រយោជន៍នៃការគោរព និងភាពសុខដុមរមនាជាលក្ខណៈសង្គមទូលាយ ហើយ៧៨% បង្ហាញពីឆន្ទៈបើកចំហរបស់ខ្លួនក្នុងការរៀនសូត្រអំពីសាសនាផ្សេងៗក្រៅពីសាសនាខ្លួន។ តាមអ្នកចូលរួមផ្តល់ព័ត៌មានមួយចំនួនបានរាយការណ៍ថា៖

*"ទីមួយការងារមនុស្សធម៌ ទីពីរមានការធ្វើផ្លូវថ្នល់អ៊ីចឹងទៅ មានការរួមគ្នា ចុះទៅត្រួតពិនិត្យមានការជំនួយខាងបងប្អូនឥស្លាមផង ខាងសាសនាព្រះពុទ្ធផងទើបបានកើតជាផ្លូវអ៊ីចឹងធ្វើជាសាធារណៈ។"*

*"បើមានការអីត្រូវការប្រមូលលុយ ពួកគាត់ចូលរួមរៃលុយគ្នា។ ឱ្យតែត្រូវការរៃលុយកសាងផ្លូវអីហ្នឹង ពួកគាត់មកចូលរួមជាមួយយើង។"*

សរុបមក ការវិភាគអំពីទំនាក់ទំនងអន្តរជំនឿនៅក្នុងសហគមន៍កម្ពុជា បង្ហាញពីទិដ្ឋភាពមួយ ក្នុងនោះការសទ្ធា ការគោរពគ្នាទៅវិញទៅមក និងឆន្ទៈក្នុងការសិក្សាអំពីជំនឿរបស់គ្នាទៅវិញទៅមក គឺជាប្រធានបទសំខាន់។ កិច្ចខិតខំទាំងនេះ និងឥទ្ធិពលវិជ្ជមាននៃតម្លៃសាសនាមកលើសុខុមាលភាពសហគមន៍ ឆ្លុះបញ្ចាំងពីមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការជំរុញការយល់ដឹង និងការសហការរវាងសហគមន៍សាសនាផ្សេងគ្នា។ ខណៈពេលបញ្ហាប្រឈមនៅតែមាន បំណងប្រាថ្នារបស់សមាជិកសហគមន៍ក្នុងការកសាងទំនាក់ទំនងរឹងមាំរវាងសាសនា គឺជាសក្ខីភាពមួយបង្ហាញពីភាពរឹងមាំ និងសក្តានុពលនៃទំនាក់ទំនងអន្តរជំនឿនិងសាសនា។

### ៥.៤.៧. កង្វះការយល់ដឹង និងទំនាក់ទំនង

ទោះមានទិដ្ឋភាពវិជ្ជមានទាំងនេះក៏ដោយ យើងនៅតែឃើញការយល់មិនត្រឹមត្រូវ និងបញ្ហាក្នុងការប្រាស្រ័យទាក់ទងគ្នារវាងក្រុមសាសនាផ្សេងៗគ្នា។ ចន្លោះប្រហោងចំណេះដឹងនេះ អាចនាំឱ្យមានការយល់ច្រឡំ ឬពិបាកទំនាក់ទំនង ជាពិសេសរវាងអ្នកកាន់សាសនាឥស្លាម និងពុទ្ធសាសនិក។ តាមអ្នកចូលរួមផ្តល់ព័ត៌មានម្នាក់បានសង្កត់ធ្ងន់អំពីសាសនាមួយផ្សេងទៀតថា,

*“យើងអត់ដែលរៀនពីគេ ព្រោះខុសសេចក្តីជំនឿរបស់យើង យើងអត់គោរព ប្រតិបត្តិតាមគេ ដូចជាសែនព្រេនអីចឹងយើងអត់មានជំនឿខាងហ្នឹង”*

ការយល់ឃើញចំពោះសាសនាផ្ទាល់ខ្លួនមានចាប់ពី,

*“ជំនឿនិងការគោរពមិនប៉ះពាល់ដល់បុគ្គលណាមួយទេ”* ហើយ *“នេះជាសិទ្ធិឬជំនឿសាសនា”* រហូតដល់គំនិតជ្រុល,

*“កាត់កាល់ចោល អត់ថាអ្វីទេ តែនៅតាមជំនឿ”*




អ្នកដឹកនាំសាសនាទទួលស្គាល់ថាកង្វះការសន្ទនា និងការយល់ដឹងអន្តរជំនឿនេះអាចបង្កជាភាពតានតឹង និងការយល់ច្រលំកាន់តែខ្លាំងនៅក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏សង្កត់ធ្ងន់ទៅលើកិច្ចខិតខំជាបន្តបន្ទាប់ដើម្បីដោះស្រាយវិវាទទាំងនេះ

តាមរយៈការសន្ទនា និងការប្រាស្រ័យទំនាក់ទំនង។ មេដឹកនាំសាសនាជាច្រើនជំរុញឱ្យមានកម្មវិធីអន្តរជំនឿ និងការសន្ទនាដោយផ្ទាល់ ដើម្បីលើកកម្ពស់ការយោគយល់ និងការគោរពគ្នាក្នុងចំណោមក្រុមសាសនាផ្សេងៗគ្នា។ តាមការបង្ហាញក្នុងតារាងទិន្នន័យ អ្នកដឹកនាំសាសនា៨៣%ដែលបានផ្តល់សម្ភាសបានបង្ហាញពីឆន្ទៈដោះស្រាយវិវាទសាសនានៅក្នុងសហគមន៍របស់ពួកគេ។ អ្នកផ្តល់ព័ត៌មានម្នាក់បាននិយាយថា *“ខ្ញុំចង់រៀនសូត្រពីជំនឿសាសនាអ្នកដទៃដើម្បីស្វែងយល់បន្ថែមទៀត។”*

*“យើងធ្លាប់មានមកហើយទាក់ទងនឹងអន្តរជំនឿ ហើយអង្គការលោកគ្រូក៏ធ្លាប់រៀបចំ ហើយពេលខ្លះ ខាងសហគមន៍ក៏មានការរៀបចំពេលមានបុណ្យ ចូលឆ្នាំ និងថ្ងៃប្រសូតរបស់ពុទ្ធសាសនា យើងអញ្ជើញគ្រប់សាសនាមកជួបជុំ។ ឧទាហរណ៍ ពួកគាត់សាសនផ្សេងៗ មកជួបជុំគ្នា គាត់អាចបួងសួង អធិដ្ឋានផ្សេងៗគ្នា។”*

សរុបមក ទស្សនៈរបស់អ្នកដឹកនាំសាសនាបង្ហាញទាំងបញ្ហាប្រឈម និងវិធានការបុរេសកម្មដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងជំនឿសាសនា និងពិធីសាសនានៅក្នុងសហគមន៍របស់ពួកគេ។ ខណៈពេលមានឧបសគ្គទៅលើទំនាក់ទំនងអន្តរជំនឿ ក៏មានកិច្ចខិតខំរួមគ្នាដើម្បីជំរុញការសន្ទនាការយល់ដឹង និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសហគមន៍សាសនាចម្រុះនៅថ្នាក់មូលដ្ឋាន។ កិច្ចខិតខំទាំងនេះមានសារៈសំខាន់ណាស់ក្នុងការកសាងសង្គមបរិយាបន្ន និងសុខដុមរមនាបន្ថែមទៀត ដោយសេរីភាពសាសនា និងសិទ្ធិរបស់បុគ្គលទាំងអស់ទទួលបានការគោរព និងការពារ។

សរុបមក ទំនាក់ទំនងអន្តរជំនឿនៅក្នុងសហគមន៍កម្ពុជាជាទូទៅមានភាពវិជ្ជមានដោយសារមានការខិតខំជំរុញការគោរព និងការយល់ដឹងគ្នាទៅវិញទៅមកតាមរយៈការសន្ទនា និងសកម្មភាពរួមគ្នា។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមាន ជាពិសេសគឺការ

យាយីដល់សាសនាភាគតិច និងអ្នកប្រតិបត្តិខាងព្រលឹងវិញ្ញាណ។ ពិធីប្រពៃណី និងពិធីបុណ្យគឺជាគន្លឹះក្នុងការនាំក្រុមសាសនារួមគ្នា លើកកម្ពស់ការរួបរួមវប្បធម៌ និងការរៀបចំផែនការសហគមន៍។ កម្មវិធីអន្តរជំនឿជួយឱ្យក្រុមសាសនាផ្សេងៗគ្នាសហការលើគោលដៅរួមក្នុងការអប់រំ សុខភាព និងកង្វល់សង្គម។ ការចូលរួមក្នុងពិធីបុណ្យ និងព្រឹត្តិការណ៍សាសនារបស់គ្នាទៅវិញទៅមកគឺជារឿងធម្មតា ដែលបង្ហាញពីវត្តមានគួរឱ្យកត់សម្គាល់នៃការគោរពគ្នាទៅវិញទៅមក។ កិច្ចខិតខំអប់រំ និងការបើកចិត្តក្នុងការសិក្សាអំពីជំនឿផ្សេងៗពង្រឹងភាពសុខដុមរមនាអន្តរជំនឿបន្ថែមទៀត ដោយមានអ្នកដឹកនាំជាច្រើនបង្ហាញឆន្ទៈក្នុងការរៀនអំពីជំនឿ និងការប្រតិបត្តិរបស់សាសនាផ្សេងៗ។

# ៥.៥. សារៈសំខាន់នៃការផ្សព្វផ្សាយ ស.ស.ជ

ផ្នែកនេះមានបំណងបំផុសគំនិត និងលើកទឹកចិត្តដល់ការលើកកម្ពស់សេរីភាពសាសនា ឬជំនឿ ដោយបញ្ជាក់ពីទិដ្ឋភាពវិជ្ជមាននៃការប្រតិបត្តិ ការបង្រៀន និងគុណតម្លៃសាសនា។ យើងស្វែងយល់ពីផលជះទៅដល់សង្គមតាមរយៈទិដ្ឋភាពទាំងនេះ ឥទ្ធិពលនៃតួនាទីរបស់អ្នកដឹកនាំសាសនា និងរបៀបរួមចំណែកដល់ការដោះស្រាយជម្លោះតាមរយៈការប្រតិបត្តិសាសនា។

## ៥.៥.១. ប្រយោជន៍សហគមន៍ក្នុងការប្រតិបត្តិសាសនា និងជំនឿ

> *ថែរក្សាគ្នាទៅវិញទៅមកនៅក្នុងសង្គម [សាសនា] អប់រំមនុស្សកុំឱ្យធ្វើបាបអ្នកដទៃ អប់រំមនុស្សឱ្យមានសីលធម៌ និងកុំរើសអើងគ្នា។*

ផ្នែកនេះបង្ហាញពីអត្ថប្រយោជន៍ជាច្រើនដែលសាសនា ឬជំនឿផ្តល់ដល់សហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ព័ត៌មានពីអ្នកដឹកនាំ និងសមាជិកសហគមន៍។ ព័ត៌មានដែល

ផ្តល់ឱ្យបង្ហាញពីការរួមចំណែកជាវិជ្ជមាននៃការប្រតិបត្តិសាសនាដល់ជីវិតសហគមន៍ ការលើកកម្ពស់ការសាងអំពើល្អ ការគោរពជំនឿ ការគោរពសិទ្ធិមនុស្ស និងការការពារបរិស្ថាន ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល ដោយមិនប្រកាន់ពីអត្តសញ្ញាណសាសនាទីមួយៗ។

## ក. ការលើកកម្ពស់អំពើល្អ និងសិទ្ធិមនុស្ស

ការប្រតិបត្តិសាសនាជំរុញខ្លាំងឱ្យសាងអំពើល្អ និងលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងសហគមន៍។ ក្រុមសាសនាជាច្រើនសង្កត់ធ្ងន់លើសកម្មភាពដែលការពារបរិស្ថាន ការគាំទ្រជនក្រីក្រ ការតស៊ូមតិដើម្បីសមភាពយេនឌ័រ និងការអប់រំមនុស្សអំពីសីលធម៌និងការគោរព។ អ្នកចូលរួមផ្តល់ព័ត៌មានជាច្រើនតាមក្រុមសាសនា និងជំនឿផ្សេងៗគ្នា បានផ្តល់ឧទាហរណ៍អំពីសមាជិកសហគមន៍ដែលចែកអំណោយដល់ជនខ្វះខាត ចូលរួមក្នុងកិច្ចខិតខំអភិរក្សបរិស្ថាន និងរៀបចំកម្មវិធីអប់រំដើម្បីជំរុញឱ្យមានឥរិយាបថសីលធម៌ និងការគោរពសិទ្ធិមនុស្ស។ អ្នកផ្តល់ព័ត៌មានម្នាក់បានរៀបរាប់ថា*“ផ្អែកលើការបង្រៀនពីព្រះយើងឱ្យតម្លៃមនុស្សស្មើៗគ្នា ហើយមនុស្សមានសិទ្ធិស្មើៗគ្នា។”*

## ខ. ការគោរពចំពោះជំនឿ

ការគោរពចំពោះជំនឿរបស់បុគ្គលម្នាក់ៗ គឺជាអត្ថប្រយោជន៍សំខាន់មួយទៀតដែលទទួលបានតាមការប្រតិបត្តិសាសនា។ សហគមន៍រក្សាសិទ្ធិបុគ្គលក្នុងការកាន់ជំនឿផ្ទាល់ខ្លួន និងចូលរួមសកម្មភាពសាសនាដោយមិនប្រឈមនឹងការរើសអើង។ សកម្មភាពដូចជាគំនិតផ្តួចផ្តើមកសាងសន្តិភាព និងកម្មវិធីអប់រំគឺជារឿងធម្មតា ហើយមានគោលបំណងលើកកម្ពស់ការយល់ដឹង និងការយោគយល់ចំពោះក្រុមសាសនា

ផ្សេងៗគ្នា។ កិច្ចខិតខំទាំងនេះជួយបង្កើតបរិយាកាសបរិយាបន្ន ដែលជំនឿនានាទទួលបានការគោរព និងឱ្យតម្លៃ។ ចំពោះការតបទៅនឹងសំណួរថាតើសាសនារបស់ពួកគេរួមចំណែកបែបណាដល់ការការពារសិទ្ធិមនុស្ស អ្នកចូលរួមផ្តល់ព័ត៌មានបានលើកឡើងថា *"គោរពសិទ្ធិនៃជំនឿរបស់អ្នកដទៃ"* ហើយម្នាក់ទៀតបាន និយាយថា *"ផ្អែកលើការបង្រៀនពីព្រះ យើងឱ្យតម្លៃមនុស្សស្មើៗគ្នា ហើយមនុស្សមានសិទ្ធិស្មើៗគ្នា។"*

## គ. សិទ្ធិទទួលបានការអប់រំ និងសិទ្ធរស់រានមានជីវិត

ការទទួលស្គាល់សិទ្ធិទទួលបានការអប់រំ និងសិទ្ធរស់រានមានជីវិត ត្រូវបានបង្ហាញយ៉ាងខ្លាំងនៅក្នុងការប្រតិបត្តិសាសនា។ សហគមន៍គាំទ្រយ៉ាងសកម្មនូវការអប់រំ ការងារទប់ស្កាត់អំពើហិង្សា និងការពារធនធានធម្មជាតិ ដើម្បីធានាសុខុមាលភាពរបស់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។ ជាឧទាហរណ៍ ក្រុមសាសនាអាចបើកកម្មវិធីអប់រំ តស៊ូមតិដើម្បីអហិង្សា និងចូលរួមក្នុងគម្រោងអភិរក្សបរិស្ថាន ដោយហេតុជួយលើកកម្ពស់គុណភាពជីវិតនៅក្នុងសហគមន៍។ អ្នកចូលរួមផ្តល់ព័ត៌មានបាននិយាយថា *"សាសនាលើកកម្ពស់សិទ្ធិក្នុងការសិក្សា ឬទទួលបានការអប់រំ និងសិទ្ធិរស់រាន។"*

## ឃ. ការការពារសហគមន៍ និងបរិស្ថាន

ការការពារសហគមន៍ និងបរិស្ថាន គឺជាប្រធានបទសំខាន់ក្នុងការប្រតិបត្តិសាសនា។ ការដាំដើមឈើ ការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងការគាំទ្រការអភិរក្សសត្វព្រៃជារឿងធម្មតា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្ហាញពីតួនាទីជំនឿសាសនា ក្នុងការជំរុញមនសិការទំនួលខុសត្រូវចំពោះបរិស្ថាន និងសហគមន៍រួម ធានាការអនុវត្តប្រកបដោយនិរន្តរភាពដែលផ្តល់ផលប្រយោជន៍ដល់មនុស្សរាល់គ្នា។ ជាឧទាហរណ៍

អ្នកផ្ដល់ព័ត៌មានម្នាក់បាននិយាយថា *"ការសែនព្រេនឡើងអ្នកតាហ្វឹង ជួយការពារឈើថ្កាត់ ជួយឱ្យសុខសប្បាយ ជួយព្រៃឈើគង់វង្ស យើងបន្ទែបង្កា ផ្លែឈើអីហ្វឹង សម្រាប់ក្មេងជំនាន់ក្រោយផង។"*

## ង. តម្លៃ និងសីលធម៌

ការបង្រៀនខាងសាសនាណែនាំសមាជិកសហគមន៍ឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ ជៀសវាងតរិយាបថបង្កគ្រោះថ្នាក់ និងលើកកម្ពស់សកម្មភាពវិជ្ជមាន ដែលផ្ដល់ផលប្រយោជន៍ដល់សង្គម។ អ្នកចូលរួមផ្ដល់ព័ត៌មានម្នាក់ថា *"សាសនាទាំងអស់មានតម្លៃ និងអត្ថប្រយោជន៍សម្រាប់មនុស្ស។ បើគ្មានសាសនា មនុស្សប្រហែលជាមិនដឹងអ្វីដែលល្អ ឬអាក្រក់នោះទេ។"* ការបង្រៀនទាំងនេះផ្ដល់ក្របខ័ណ្ឌសីលធម៌ដែលលើកទឹកចិត្តបុគ្គលម្នាក់ៗឱ្យចូលរួមក្នុងសកម្មភាពគាំទ្រផលប្រយោជន៍រួម។ ឧទាហរណ៍ មានគម្រោងសេវាសហគមន៍ កម្មវិធីអប់រំសីលធម៌ និងគំនិតផ្ដួចផ្ដើម ដើម្បីបង្ការអំពើហិង្សា និងលើកកម្ពស់សន្តិភាព។

សរុបមក ខណៈពេលមានចំណុចចាំបាច់ត្រូវមានការកែលម្អ និងមានកិច្ចសន្ទនាអន្តរជំនឿបន្ថែមទៀត ឃើញថាការប្រតិបត្តិសាសនា ឬជំនឿ ផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីការប្រតិបត្តិ និងជំនឿផ្សេងៗគ្នា ដោយសង្កត់ធ្ងន់ទៅលើអំពើល្អ ការគោរពសិទ្ធិ និងការការពារសុខុមាលភាពរបស់បុគ្គល និងបរិស្ថាន។ ការរួមចំណែកទាំងនេះបញ្ជាក់ពីឥទ្ធិពលវិជ្ជមាននៃការប្រតិបត្តិសាសនាទៅលើសហគមន៍ ដោយជំរុញសាមគ្គីភាព និងការទទួលខុសត្រូវរួមគ្នា។

## ៥.៥.២. ឥទ្ធិពលនៃការបង្រៀនសាសនា និងតម្លៃសាសនា

ឥទ្ធិពលនៃការបង្រៀនខាងសាសនាបង្កើតតម្លៃ និងការបង្ហាញតម្លៃនៅក្នុងសហគមន៍មូលដ្ឋាន។ តាមទិន្នន័យបង្ហាញថា តម្លៃសាសនាមានសារៈសំខាន់ក្នុងការដឹកនាំបុគ្គលឆ្ពោះទៅរកឥរិយាបថវិជ្ជមាន ជំរុញការគោរពគ្នាទៅវិញទៅមក និងរួមចំណែកដល់សុខុមាលភាពសង្គម។ ឥទ្ធិពលនៃការបង្រៀនសាសនាឃើញមានបង្ហាញក្នុងទិដ្ឋភាពផ្សេងៗក្នុងសហគមន៍ តាមរយៈការបង្ហាញពីសារៈសំខាន់នៃការបង្រៀនក្នុងការរៀបចំឥរិយាបថសីលធម៌ និងលើកកម្ពស់ភាពចុះសម្រុងគ្នាក្នុងសហគមន៍។

ការបង្រៀនសាសនាមានឥទ្ធិពលក្នុងការលើកកម្ពស់អំពើល្អ និងការលើកទឹកចិត្តនូវក្តីមេត្តា និងសប្បុរសធម៌។ បុគ្គលមកពីជំនឿផ្សេងៗគ្នាជឿថាសាសនាខ្លួនណែនាំឱ្យដើរតាមមាគ៌ាត្រឹមត្រូវ និងឆ្ពោះទៅឥរិយាបថសុទិដ្ឋិនិយម។ ជាឧទាហរណ៍ សមាជិកសហគមន៍ចូលរួមក្នុងការងារសប្បុរសធម៌ តាមគោលការណ៍បំផុសទឹកចិត្តពីសាសនារបស់ខ្លួន ដើម្បីជួយជនដែលត្រូវការជំនួយ។ ការប្តេជ្ញាចិត្តទូទៅក្នុងការសាងអំពើល្អនេះបង្ហាញឱ្យឃើញពីតួនាទីរបស់សាសនាក្នុងការបណ្តុះវប្បធម៌មេត្តា និងសប្បុរស។

ការបើកចំហចំពោះការអប់រំ និងការចែករំលែកក្នុងសហគមន៍ ឆ្លុះបញ្ចាំងពីឆន្ទៈក្នុងការរៀនសូត្រពីជំនឿ និងការប្រតិបត្តិសាសនារបស់គ្នាទៅវិញទៅមក។ វគ្គអប់រំ និងការជួបជុំចែករំលែក បានជួយបុគ្គលម្នាក់ៗទទួលបានការយល់ដឹងអំពីប្រពៃណីសាសនាចម្រុះ។ ការរៀនសូត្រពីគ្នានេះ ជំរុញការយល់ដឹងកាន់តែស៊ីជម្រៅ និងការគោរពចំពោះជំនឿផ្សេងៗគ្នា លើកកម្ពស់ភាពសុខដុមរមនា និងកាត់បន្ថយវិវាទសាសនា។ ជាឧទាហរណ៍ ការសន្ទនាអន្តរជំនឿ និងការប្រជុំសហគមន៍ អាចឱ្យ មនុស្សយល់ដឹងពីគុណតម្លៃរួមដែលសាសនាផ្សេងៗចែករំលែក ដែលជាចំណុច ពង្រឹងចំណងសហគមន៍។

តម្លៃសាសនាត្រូវបានមើលឃើញច្រើនតាមសកម្មភាពជួយសង្គម ដែលនេះបង្ហាញពីការអនុវត្តជាក់ស្តែងនូវអ្វីដែលបានបង្រៀនពីសាសនា។ សមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពដូចជា ការអភិរក្សបរិស្ថាន ការគាំទ្រការអប់រំ និងការងារសប្បុរសធម៌ផ្សេងៗទៀត ដែលជំរុញដោយជំនឿសាសនារបស់ពួកគេ។ ការរួមចំណែកដល់សង្គមនេះ បង្ហាញពីអំណាចផ្លាស់ប្តូរនៃគុណតម្លៃសាសនា ក្នុងការជំរុញឱ្យមានការបំប្លែងសង្គមជាវិជ្ជមាន។ ឧទាហរណ៍ រួមមានក្រុមសាសនារៀបចំការសម្អាត ការគាំទ្រសាលារៀនក្នុងមូលដ្ឋាន និងការផ្តល់ជំនួយក្នុងអំឡុងពេលមានវិបត្តិ ដែលចំណុចទាំងនេះបានចាក់ឫសគល់នៅក្នុងការប្តេជ្ញាចិត្តខាងជំនឿដល់ការលើកកម្ពស់សុខុមាលភាពសង្គម។

ការគោរពចំពោះភាពចម្រុះក៏ជាលទ្ធផលធំមួយកើតចេញពីការបង្រៀនសាសនាដោយបុគ្គលម្នាក់ៗទទួលស្គាល់តម្លៃសាសនាទាំងអស់ថារួមចំណែកដល់សុខុមាលភាពផ្ទាល់ខ្លួន និងសង្គម។ មនុស្សមកពីមជ្ឈដ្ឋានសាសនាផ្សេងៗគ្នា បង្ហាញការគោរពចំពោះជំនឿ និងការប្រតិបត្តិរបស់គ្នាទៅវិញទៅមក ជំរុញវប្បធម៌បរិយាបន្ន និងការគោរពគ្នាទៅវិញទៅមក។ ការគោរពចំពោះភាពចម្រុះនេះ ជួយបង្កើតសហគមន៍ដែលមានភាពចុះសម្រុងគ្នា និងយោគយល់គ្នាបន្ថែមទៀត ដែលក្នុងនោះមានតែសាទរភាពខុសគ្នាជាជាងការភ័យខ្លាច។

ការតម្រែតម្រង់ផ្លូវ និងភាពទៀងត្រង់ខាងសីលធម៌ដែលបានមកពីការបង្រៀនសាសនា ផ្តល់ក្របខ័ណ្ឌដឹកនាំជីវិតប្រកបដោយសីលធម៌ និងដោះស្រាយបញ្ហាប្រឈមក្នុងសហគមន៍។ គោលការណ៍សាសនាលើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗធ្វើការរួមចំណែកជាវិជ្ជមាន ដល់សហគមន៍របស់ពួកគេ ពង្រឹងតម្លៃសីលធម៌ និងឥរិយាបថប្រកបដោយសីលធម៌។ ជាឧទាហរណ៍ អ្នកដឹកនាំសាសនាដែលចូលរួមផ្តល់ព័ត៌មានតែងតែសង្កត់ធ្ងន់លើគោលការណ៍ដូចជា ភាពស្មោះត្រង់ សុចរិតភាព និងក្តីមេត្តា

ដោយណែនាំអ្នកប្រតិបត្តិឱ្យអនុវត្តគុណតម្លៃទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការណែនាំអំពីសីលធម៌នេះ ជួយបុគ្គលម្នាក់ៗរៀរចាកពីសង្គមដ៏ស្មុគស្មាញ និងរួមចំណែកជាវិជ្ជមានដល់សហគមន៍របស់ពួកគេ។

សរុបមក ទិន្នន័យបង្ហាញអំពីតួនាទីសំខាន់នៃតម្លៃសាសនាក្នុងការរៀបចំឥរិយាបថ និងសកម្មភាពរបស់បុគ្គលនៅក្នុងសហគមន៍មូលដ្ឋាន។ គុណតម្លៃទាំងនេះជំរុញឱ្យមានការឯកភាពគ្នា លើកកម្ពស់ការគិតប្រយោជន៍អ្នកដទៃ និងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនៃសង្គម ដោយបង្ហាញពីឥទ្ធិពលយូរអង្វែងនៃការបង្រៀនសាសនាលើជីវិតសហគមន៍។ ការប្រើតម្លៃទាំងនេះទៅក្នុងសកម្មភាពប្រចាំថ្ងៃ បញ្ជាក់ពីសារៈសំខាន់របស់សាសនាក្នុងការកសាងសហគមន៍ប្រកបដោយសីលធម៌ មេត្តាធម៌ និងភាពចុះសម្រុងគ្នា។

## ៥.៥.៣. ការរួមចំណែករបស់មេដឹកនាំសាសនាចំពោះសហគមន៍របស់ពួកគេ

អ្នកដឹកនាំសាសនាដើរតួនាទីយ៉ាងសំខាន់ក្នុងការតម្រែតម្រង់ជំនឿ ការប្រតិបត្តិ និងទំនាក់ទំនងអន្តរជំនឿនៅក្នុងសហគមន៍ខ្លួន។ ឥទ្ធិពលរបស់ពួកគេគឺមានលើសពីការណែនាំនៃសាសនាដើម្បីជំរុញការគោរពគ្នាទៅវិញទៅមក និងការយោគយល់គ្នាក្នុងចំណោមក្រុមជំនឿចម្រុះ។ ទិន្នន័យបានបង្ហាញពីទិដ្ឋភាពផ្សេងៗនៃភាពជាអ្នកដឹកនាំ ចាប់ពីគំនិតផ្តួចផ្តើមអប់រំ រហូតដល់ការដោះស្រាយវិវាទ ដោយសង្កត់ធ្ងន់ទៅលើការចូលរួមចំណែករបស់អ្នកដឹកនាំ ចំពោះកិច្ចសហប្រតិបត្តិការ និងសុខដុមរមនាក្នុងសហគមន៍។

អ្នកដឹកនាំសាសនាបានធ្វើការណែនាំ និងមានឥទ្ធិពលខ្លាំងដល់ជំនឿ និងការប្រតិបត្តិរបស់សាសនិកទូទៅ ដោយបុគ្គលជាច្រើនបានសម្តែងការពេញចិត្ត និង

សប្បាយរីករាយជាមួយនឹងការបង្រៀន និងពិធីនានាដែលធ្វើឡើងដោយអ្នកដឹកនាំរបស់ពួកគេ។ នេះបញ្ជាក់អំពីសារៈសំខាន់នៃភាពជាអ្នកដឹកនាំរឹងមាំ ក្នុងការរក្សាបានទូវសុចរិតភាពខាងជំនឿ និងវប្បធម៌នៅក្នុងសហគមន៍។ ជាឧទាហរណ៍ នៅក្នុងសហគមន៍ដែលមានអ្នកដឹកនាំដែលចូលរួមយ៉ាងសកម្មជាមួយអ្នកប្រតិបត្តិ យើងឃើញមានភាពត្រេកអរគួរឱ្យកត់សម្គាល់ និងការពេញចិត្តពីសមាជិកសហគមន៍។

ការយោគយល់ និងកិច្ចសហប្រតិបត្តិការអន្តរជំនឿ ក៏ត្រូវបានសម្របសម្រួលដោយអ្នកដឹកនាំសាសនា។ អ្នកដឹកនាំសាសនាលើកកម្ពស់ការគោរពគ្នាទៅវិញទៅមក និងការចូលរួមជាមួយជំនឿផ្សេងទៀត។ ករណីដែលមានបុគ្គលបង្ហាញឥរិយាបថវិជ្ជមានចំពោះការសិក្សា និងការគោរពសាសនាផ្សេងទៀតគឺបង្ហាញពីឆន្ទៈក្នុងការចូលរួមក្នុងកិច្ចសន្ទនាអន្តរជំនឿ។ ជាញឹកញាប់ ចំណុចនេះត្រូវបានជំរុញពីថ្នាក់ដឹកនាំដែលមានការពុះពារសម្រាប់អន្តរកម្មបែបនេះ ដោយជួយកាត់បន្ថយគម្លាតរវាងក្រុមសាសនាផ្សេងៗ។ ជាឧទាហរណ៍ អ្នកដឹកនាំរៀបចំព្រឹត្តិការណ៍អន្តរជំនឿ ឬការពិភាក្សារួមចំណែកក្នុងការដោះរនាំង និងជំរុញមនសិការរួបរួមគ្នា។

បញ្ហាប្រឈមក្នុងការអប់រំសាសនាក៏មានបញ្ជាក់តាមព័ត៌មានដែលផ្តល់ឱ្យដោយក្នុងនោះបង្ហាញពីសារៈសំខាន់នៃកម្មវិធីចែករំលែកចំណេះដឹង ដើម្បីបញ្ចៀសវិវាទនិងការយល់ច្រឡំក្នុងក្រុមអន្តរជំនឿ។ អ្នកដឹកនាំដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលគំនិតផ្តួចផ្តើមអប់រំទាំងនេះ ប៉ុន្តែចន្លោះប្រហោងខ្លះត្រូវការការបំពេញ។ កង្វះការអប់រំផ្នែកសាសនាច្រើននាំឱ្យមានជម្លោះ និងការខ្វែងគំនិតគ្នាតាមពាក្យសំដី ដែលនេះទាមទារឱ្យមានកិច្ចខិតខំអប់រំខ្លាំងបន្ថែមទៀត។ ការអប់រំសាសនាប្រកបដោយប្រសិទ្ធភាពអាចបង្ការការយល់ខុស និងជំរុញសហគមន៍ឱ្យមានការយល់ដឹង និងយោគយល់គ្នាឱ្យបានកាន់តែច្រើន។

ទំនៀមទម្លាប់វប្បធម៌ និងពិធីសាសនា ដែលដឹកនាំដោយអ្នកដឹកនាំសាសនា គឺជារឿងសំខាន់ក្នុងសហគមន៍ជំនឿ។ ទោះជាយ៉ាងណាក៏ដោយ ជម្លោះអាចកើតឡើងនៅពេលបុគ្គលគិតខ្លាំងដល់ទំនៀមទម្លាប់របស់ខ្លួនដោយមិនយល់ ឬគោរពទំនៀមទម្លាប់របស់អ្នកដទៃ។ អ្នកដឹកនាំជួយស្វែងយល់ភាពស្មុគស្មាញទាំងនេះដោយលើកទឹកចិត្តឱ្យមានការគោរពចំពោះការប្រតិបត្តិចម្រុះ និងជំរុញការសាទរដល់ភាពចម្រុះវប្បធម៌ និងសាសនា។ ជាឧទាហរណ៍ អ្នកដឹកនាំដែលសង្កត់ធ្ងន់លើតម្លៃនៃទំនៀមទម្លាប់ផ្សេងៗ ជួយបញ្ចៀសវិវាទ និងលើកកម្ពស់បរិយាកាសបរិយាបន្នកាន់តែច្រើន។

ការប្រាស្រ័យទាក់ទង និងការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព គឺសំខាន់ចាំបាច់សម្រាប់ដោះស្រាយការខ្វែងគំនិតគ្នារវាងក្រុមជំនឿ។ តួនាទីអ្នកដឹកនាំសាសនាមានសារៈសំខាន់ក្នុងការសម្របសម្រួលការសន្ទនា និងលើកកម្ពស់ការយោគយល់ដើម្បីទំនាក់ទំនងរវាងមនុស្ស និងអ្នកដឹកនាំនៃក្រុមជំនឿផ្សេងៗគ្នា ត្រូវបានកំណត់ដោយអន្តរកម្មសាំញ៉ាំរវាងការណែនាំ ឥទ្ធិពល ការអប់រំ ប្រពៃណីវប្បធម៌ និងការប្រាស្រ័យទាក់ទងគ្នា។ ការរួមចំណែករបស់មេដឹកនាំសាសនាគឺចាំបាច់សម្រាប់ការកសាងទំនាក់ទំនងវិជ្ជមាន ជំរុញការគោរព និងការយល់ដឹងគ្នាទៅវិញទៅមក និងការលើកកម្ពស់ភាពសុខដុមរមនា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសហគមន៍សាសនាផ្សេងៗគ្នា។

## ៥.៥.៤. គុណតម្លៃ និងការប្រតិបត្តិសាសនាសម្រាប់ការដោះស្រាយវិវាទ

ក្នុងការស្វែងយល់ពីរបៀបរក្សាការពារសិទ្ធិបុគ្គល និងដោះស្រាយវិវាទនៅក្នុងសហគមន៍កម្ពុជាតាមរយៈគុណតម្លៃសាសនា ច្បាស់ណាស់ដែលថាគុណតម្លៃទាំងនេះដើរតួនាទីសំខាន់ក្នុងការជំរុញឱ្យសង្គមមានសុខដុមរមនា និងប្រកបដោយបរិយាបន្នភាព។ ការសង្កត់ធ្ងន់លើការដោះស្រាយវិវាទដោយអហិង្សា ទំនួលខុសត្រូវផ្ទាល់ខ្លួន ការគោរពភាពចម្រុះ និងការខិតខំរួមគ្នា បង្ហាញឱ្យឃើញពីសារៈសំខាន់នៃការបង្រៀនខាងសាសនា និងការចូលរួមក្នុងសហគមន៍ក្នុងការបង្កើតបរិយាកាសមួយដែលគោរព និងការពារសិទ្ធិផ្ទាល់ខ្លួននិងសិទ្ធិសហគមន៍។

### ក. គុណតម្លៃដែលរួមចំណែកដល់សិទ្ធិសាសនា និងសិទ្ធិផ្ទាល់ខ្លួន

ការប្រកាន់យកការដោះស្រាយវិវាទដោយអហិង្សានៅក្នុងសហគមន៍សាសនាឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការការពារសិទ្ធិផ្ទាល់ខ្លួនដោយសន្តិវិធី។ ការពិភាក្សា និងការសន្ទនាជាចំណុចអាទិភាពក្នុងការដោះស្រាយវិវាទ និងការលើកកម្ពស់ការយល់ដឹងគ្នាទៅវិញទៅមក និងភាពសុខដុមរមនា។ វិធីសាស្ត្រនេះជួយដោះស្រាយវិវាទ ហើយពង្រឹងវប្បធម៌អហិង្សា និងការគោរពសិទ្ធិបុគ្គលដែលនេះមានសារៈសំខាន់សម្រាប់ការរក្សាភាពចុះសម្រុងគ្នាក្នុងសង្គម។

ការលើកទឹកចិត្តឱ្យមានទំនួលខុសត្រូវ និងគណនេយ្យភាពផ្ទាល់ខ្លួន គឺជាតម្លៃសាសនាដ៏សំខាន់មួយទៀត ដែលជួយការពារសិទ្ធិបុគ្គល។ តាមរយៈការជំរុញការឆ្លុះបញ្ចាំងខ្លួនឯង ការដាក់ខ្លួន និងក្តីមេត្តា ការបង្រៀនខាងសាសនាជំរុញឱ្យបុគ្គលម្នាក់ៗទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ ហើយចេះសុំការអភ័យទោស។ ការសង្កត់ធ្ងន់លើ

ទំនួលខុសត្រូវផ្ទាល់ខ្លួននេះ ជួយលើកកម្ពស់សិទ្ធិផ្ទាល់ខ្លួន និងលើកកម្ពស់វប្បធម៌នៃឥរិយាបថសីលធម៌ និងការគោរពគ្នាទៅវិញទៅមកនៅក្នុងសហគមន៍។

ជំនឿសាសនាក៏ដើរតួជាគោលការណ៍ណែនាំផងដែរក្នុងការបញ្ជាក់ពីសារៈសំខាន់នៃការគោរពសិទ្ធិ និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។ ជំនឿលើរឿងខុសនិងត្រូវដែលបង្កប់ជ្រៅក្នុងការបង្រៀនសាសនា ជួយពង្រឹងការការពារសិទ្ធិផ្ទាល់ខ្លួន ដោយលើកទឹកចិត្តបុគ្គលឱ្យប្រព្រឹត្តទង្វើដោយយុត្តិធម៌ និងមានសីលធម៌។ ក្របខ័ណ្ឌសីលធម៌នេះផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់បុគ្គលគ្រប់រូបនៅក្នុងសហគមន៍។

ការគោរពចំពោះភាពចម្រុះ និងបរិយាបន្នភាពគឺជាគុណតម្លៃមូលដ្ឋានដែលលើកកម្ពស់សិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលមកពីមជ្ឈដ្ឋានសាសនាផ្សេងៗគ្នា។ តាមការសង្កត់ធ្ងន់លើសារៈសំខាន់នៃការគោរពជំនឿ និងការប្រតិបត្តិផ្សេងៗគ្នា សហគមន៍សាសនាជាអ្នកជំរុញឱ្យមានបរិយាបន្នភាព និងការពារសិទ្ធិរបស់សមាជិកទាំងអស់។ ការគោរពភាពចម្រុះនេះជួយបង្កើតបរិយាកាសមួយ ដោយក្នុងនោះបុគ្គលម្នាក់ៗមានអារម្មណ៍ថាមានតម្លៃ ហើយមានគេទទួលស្គាល់ ដោយមិនប្រកាន់ពីអត្តសញ្ញាណសាសនារបស់ពួកគេឡើយ។

## ខ. លំនាំក្នុងការដោះស្រាយវិវាទសហគមន៍

ការចូលរួមយ៉ាងសកម្មរបស់សមាជិកសហគមន៍ក្នុងការដោះស្រាយវិវាទ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយការខ្វែងគំនិតគ្នា និងរក្សាភាពសុខដុមរមនា។ វិធីសាស្ត្ររបស់សហគមន៍ចំពោះការដោះស្រាយវិវាទនេះ ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការចូលរួមក្នុងការដោះស្រាយវិវាទ។ តាមរយៈការចូលរួមពីសមាជិកសហគមន៍ក្នុង

ដំណើរការដោះស្រាយវិវាទ សហគមន៍សាសនាអាចដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ភាពសុខដុមរមនាក្នុងសង្គម។

ការផ្តល់អាទិភាពដល់ការពិភាក្សា និងកិច្ចសហប្រតិបត្តិការ គឺជាវិធីសាស្ត្រសហការដែលជួយបង្ការវិវាទ និងលើកកម្ពស់ការគោរពគ្នាទៅវិញទៅមក។ តាមរយៈការប្រាស្រ័យទាក់ទងបើកចំហ និងការយោគយល់គ្នា បុគ្គលមកពីសាវតាសាសនាផ្សេងៗគ្នាអាចធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាទូទៅ និងកសាងទំនាក់ទំនងរឹងមាំ។ កិច្ចខិតខំសហប្រតិបត្តិការនេះ សង្កត់ធ្ងន់លើតម្លៃនៃទំនាក់ទំនងសហគមន៍ជាងការបែងចែកបក្សពួក ជាហេតុរួមចំណែកដល់ការរួមរស់ជាមួយគ្នាដោយសន្តិភាព។

ទោះបីជាមានភាពខុសប្លែកគ្នានៅក្នុងជំនឿសាសនាក៏ដោយ ឆន្ទៈក្នុងការសហការអភិវឌ្ឍសហគមន៍ និងគំនិតផ្តួចផ្តើមមនុស្សធម៌ ជំរុញឱ្យមានសាមគ្គីភាព និងការគាំទ្រគ្នាទៅវិញទៅមក។ កិច្ចខិតខំប្រឹងប្រែងរួមគ្នា និងការសហការគ្នារវាងបុគ្គលមកពីមជ្ឈដ្ឋានសាសនាចម្រុះ រួមចំណែកដល់ការរួមរស់ជាមួយគ្នាដោយសន្តិភាព និងការដោះស្រាយវិវាទដោយសន្តិវិធី។ គំនិតផ្តួចផ្តើមសហការទាំងនេះបញ្ជាក់ពីគុណតម្លៃរួមនៃមេត្តាធម៌ និងការផ្តល់ជំនួយ ដែលមានសារៈសំខាន់សម្រាប់បង្កើតសង្គមមួយប្រកបដោយសុខដុមរមនា។

គុណតម្លៃ និងលំនាំដែលរកឃើញតាមការស្ទង់មតិនេះ បង្ហាញពីតួនាទីសំខាន់នៃការបង្រៀនសាសនា និងការចូលរួមសហគមន៍ ដើម្បីជំរុញសិទ្ធិសាសនា និងបុគ្គល និងការដោះស្រាយវិវាទសហគមន៍។ តាមរយៈការប្រកាន់ខ្ជាប់ការដោះស្រាយវិវាទដោយអហិង្សា ទំនួលខុសត្រូវផ្ទាល់ខ្លួន ការគោរពចំពោះភាពចម្រុះ និងការសហការគ្នា សហគមន៍សាសនាដើរតួនាទីជាអ្នកបង្កើតសង្គមមួយប្រកបសុខដុមរមនា បរិយាបន្ន និងប្រកបដោយមេត្តាធម៌ ដោយក្នុងនោះសិទ្ធិបុគ្គល និងសហគមន៍ទទួលបានការ

គោរព និងការការពារ។ គុណតម្លៃរួម និងលំនាំទាំងនេះគឺជាគោលការណ៍ណែនាំដែលជំរុញភាពចុះសម្រុងគ្នាក្នុងសង្គម ការគោរពគ្នាទៅវិញទៅមក និងការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាពនៅក្នុងសហគមន៍សាសនា និងក្នុងបរិបទផ្សេងៗទៀត។

ជាចុងក្រោយ ផ្នែកនេះអាចសន្និដ្ឋានបានដូចខាងក្រោម។

ការប្រតិបត្តិសាសនាផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សហគមន៍តាមរយៈការលើកកម្ពស់អំពើល្អ សិទ្ធិមនុស្ស និងការគោរពជំនឿផ្សេងៗ។ ការប្រតិបត្តិសាសនាលើកទឹកចិត្តដល់ការការពារបរិស្ថាន ការគាំទ្រដល់ជនក្រីក្រ និងសមភាពយេនឌ័រ។ ឧទាហរណ៍ សមាជិកសហគមន៍ចែកអំណោយដល់ជនខ្វះខាត និងចូលរួមក្នុងកិច្ចខិតខំអភិរក្ស។ លើសពីនេះ ការបង្រៀនខាងសាសនាសង្កត់ធ្ងន់លើឥរិយាបថសីលធម៌ អហិង្សា និងការការពារសិទ្ធិបុគ្គល ជំរុញវប្បធម៌ចិត្តមេត្តា បរិយាបន្នភាព និងការគោរពគ្នាទៅវិញទៅមក។

ការបង្រៀនខាងសាសនាមានឥទ្ធិពលខ្លាំងទៅលើតម្លៃសហគមន៍ ព្រោះដឹកនាំបុគ្គលម្នាក់ៗឆ្ពោះទៅរកឥរិយាបថវិជ្ជមាន និងសុខុមាលភាពសង្គម។ ការបង្រៀនគឺលើកកម្ពស់ទង្វើល្អ និងសប្បុរសធម៌ ជំរុញការគោរពគ្នាទៅវិញទៅមក និងលើកទឹកចិត្តដល់ការរៀនសូត្រសាសនាទៅវិញទៅមក។ គុណតម្លៃសាសនាស្តែងចេញតាមសកម្មភាពផ្តល់ផលដល់សង្គម ដូចជាការអភិរក្សបរិស្ថាន និងការគាំទ្រផ្នែកអប់រំជាដើម។ ការបង្រៀនទាំងនេះផ្តល់នូវក្របខ័ណ្ឌសីលធម៌ ការលើកកម្ពស់ឥរិយាបថសីលធម៌ និងជួយបុគ្គលម្នាក់ៗក្នុងការរួមចំណែកជាវិជ្ជមានដល់សហគមន៍របស់ខ្លួន។

អ្នកដឹកនាំសាសនាដើរតួនាទីសំខាន់ក្នុងការតម្រែតម្រង់ជំនឿសហគមន៍ និងជំរុញទៅលើទំនាក់ទំនងអន្តរជំនឿ។ ពួកគេមានឥទ្ធិពលដល់ការលើកកម្ពស់ការគោរព និងការយោគយល់គ្នាទៅវិញទៅមក ការរៀបចំគំនិតផ្តួចផ្តើមអប់រំ និងការដោះស្រាយវិវាទនានា។ មេដឹកនាំខិតខំជំរុញឱ្យមានកិច្ចសន្ទនាអន្តរជំនឿ បង្ការការយល់ខុសលើគ្នា និងលើកទឹកចិត្តឱ្យមានការគោរពប្រពៃណីចម្រុះ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងការដោះស្រាយវិវាទដែលសម្របសម្រួលដោយអ្នកដឹកនាំសាសនា គឺចាំបាច់ណាស់សម្រាប់រក្សាភាពសុខដុមរមនា និងកិច្ចសហប្រតិបត្តិការក្នុងក្រុមសាសនា ឬជំនឿផ្សេងៗ។

តម្លៃសាសនាជួយដល់ការការពារសិទ្ធិបុគ្គល និងការដោះស្រាយវិវាទតាមរយៈការប្រកាន់ខ្ជាប់លើធម៌អហិង្សា ការទទួលខុសត្រូវផ្ទាល់ខ្លួន និងការគោរពភាពចម្រុះ។ ការចូលរួម និងការសហការក្នុងសហគមន៍ គឺជាគន្លឹះដោះស្រាយវិវាទ និងការលើកកម្ពស់សុខដុមរមនាក្នុងសង្គម។ តាមរយៈការផ្តល់អាទិភាពដល់ការពិភាក្សា កិច្ចសហប្រតិបត្តិការ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការអភិវឌ្ឍសហគមន៍ ការបង្រៀនខាងសាសនាជួយបង្កើតសង្គមដែលប្រកបដោយសុខដុមរមនា និងបរិយាបន្នភាពដែលគោរពសិទ្ធិផ្ទាល់ខ្លួន និងសិទ្ធិសហគមន៍។



# ៦.

# អនុសាសន៍

## ៦.១. គោលការណ៍គ្រឹះនៃយុទ្ធសាស្ត្រសម្រាប់ ស.ស.ជ

ការវិភាគទិន្នន័យសព្វជ្រុងជ្រោយដែលផ្តល់នៅក្នុងរបាយការណ៍នេះ (និងអនុសាសន៍ទូទៅសម្រាប់ការអភិវឌ្ឍសេរីភាពសាសនា និងជំនឿនៅកម្ពុជា) គឺមិនមានលក្ខណៈគ្រប់គ្រាន់ទេ។ អនុសាសន៍ទូទៅទាំងនេះ ត្រូវបូកបញ្ចូលជាមួយឧត្តមានុវត្តន៍ (ការអនុវត្តល្អប្រសើរ) ដែលចាក់ឫសគល់នៅក្នុងគោលការណ៍ពហុនិយមនៃការព្រមព្រៀង (Covenantal Pluralism) គោលការណ៍កិច្ចសន្ទនាអន្តរជំនឿ (Interfaith Dialogue) គោលការណ៍ជំហានឡើងទៅភាពចម្រុះ (Ladder of Diversity) និងគោលការណ៍នៃលក្ខខណ្ឌអនុញ្ញាត (Enabling Conditions)។ ពេលផ្សំជាមួយ ស.ស.ជ គោលការណ៍ទាំងបួននេះរំលេចនូវយុទ្ធសាស្ត្រដ៏មានអានុភាពសម្រាប់ការអភិវឌ្ឍសុខដុមរមនាសង្គមនៅក្នុងសង្គមដូចជាប្រទេសកម្ពុជាដែលមានភាពចម្រុះជាតិសាសន៍ និងសាសនាជាពិសេសក្រុមភាគតិចដែលមានភាគរយតិចធៀបនឹងក្រុមភាគច្រើន។ គោលការណ៍គ្រឹះទាំងនេះបានផ្តល់ជាគំនិតសម្រាប់ការពិភាក្សានៅក្នុងក្រុមការងារស្រាវជ្រាវស្ទួលសម្រាប់ការបង្កើតកម្រងសំណួរស្ទង់មតិ ហើយឥឡូវនេះផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការបង្កើតយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយ ដើម្បីជំរុញការអនុវត្តសេរីភាពសាសនា ឬជំនឿនៅក្នុងសហគមន៍គោលដៅ មុនពេលដំណើរការនេះអាចត្រូវអនុវត្តនៅថ្នាក់ជាតិ។ សហគមន៍គោលដៅក្លាយជា 'ដែនសិក្សា' ដែលអាចជាយុទ្ធសាស្ត្រជាតិសម្រាប់ ស.ស.ជ។

***ពហុនិយមនៃការព្រមព្រៀង*** (Covenantal Pluralism) សង្កត់ធ្ងន់លើការរួមរស់ជាមួយគ្នាដោយសន្តិភាពនៃក្រុមសាសនា វប្បធម៌ និងសង្គមផ្សេងៗគ្នានៅក្នុងសង្គមមួយ ដោយផ្អែកលើកិច្ចព្រមព្រៀងរួមដែលទទួលស្គាល់ និងគោរពអត្តសញ្ញាណ និងសិទ្ធិដោយឡែកពីគ្នារបស់ក្រុមនីមួយៗ។ វិធីសាស្ត្រនេះលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមក ការយោគយល់ និងកិច្ចសហប្រតិបត្តិការក្នុងសហគមន៍

ចម្រុះ ជំរុញឱ្យមានសម្ព័ន្ធសង្គមមួយដែលមានសុខដុមរមនា និងប្រកបដោយបរិយាបន្ន។ ជាឧទាហរណ៍ កិច្ចសន្ទនាអន្តរជំនឿលើកទឹកចិត្តឱ្យមានការសន្ទនាក្នុងន័យស្ថាបនា ក្នុងចំណោមអ្នកតំណាងប្រពៃណីសាសនាផ្សេងៗគ្នា ដែលបណ្តុះការយល់ដឹងពីគ្នា ការយោគយល់គ្នា និងកិច្ចសហប្រតិបត្តិការ។ ការគោរព និងការទទួលស្គាល់គ្នាទៅវិញទៅមកគឺពាក់ព័ន្ធនឹងការយោគយល់ និងការឱ្យតម្លៃចំពោះជំនឿ ការអនុវត្ត និងការរួមចំណែកក្នុងក្របខ័ណ្ឌគុណតម្លៃរួមមួយ។ គោលនយោបាយ និងរចនាសម្ព័ន្ធអភិបាលកិច្ចដែលមានបរិយាបន្ន នឹងបំពេញតម្រូវការរបស់ក្រុមទាំងអស់ ដោយធានាឱ្យមានភាពជាតំណាង និងការចូលរួមប្រកបដោយសមធម៌ នៅក្នុងដំណើរការសម្រេចចិត្ត។

ឧត្តមានុវត្តន៍ (ការអនុវត្តល្អប្រសើរ) ក្នុងការលើកកម្ពស់ពហុនិយមនៃការព្រមព្រៀង គឺក្រុមប្រឹក្សាអន្តរជំនឿដែលប្រមូលផ្តុំមេដឹកនាំសាសនាមកពីពុទ្ធសាសនា សាសនាឥស្លាម គ្រិស្តសាសនា និងក្រុមជនជាតិដើមភាគតិច និងក្រុមជំនឿសាសនាផ្សេងៗទៀត ដើម្បីពិភាក្សាអំពីបញ្ហាសហគមន៍ និងសម្របសម្រួលកិច្ចខិតខំអភិវឌ្ឍសង្គម។ ឧទាហរណ៍មួយទៀតគឺគំនិតផ្តួចផ្តើមអប់រំតាមសហគមន៍ ដែលលើកកម្ពស់ការយល់ដឹងពីប្រពៃណីសាសនាផ្សេងៗ ជួយលុបបំបាត់ការយល់ខុស និងលើកកម្ពស់ការគោរពភាពចម្រុះ។

***កិច្ចសន្ទនាអន្តរជំនឿ*** (Interfaith Dialogues) សំដៅលើអន្តរកម្មប្រកបដោយសហប្រតិបត្តិការ និងការស្ថាបនារវាងអ្នកតំណាងប្រពៃណីសាសនាផ្សេងៗ ទាំងកម្រិតថ្នាក់ដឹកនាំនិងសហគមន៍ ក្នុងគោលបំណងជំរុញការយល់គ្នា ស្វែងយល់ពីមូលដ្ឋានរួម ដោះស្រាយភាពខុសគ្នា និងកសាងស្ពានចម្លងការយល់ដឹងក្នុងសហគមន៍សាសនាចម្រុះ លើកកម្ពស់សន្តិភាព សុខដុមរមនា និងសាមគ្គីភាពសង្គម។ ការអនុវត្តពាក់ព័ន្ធនឹងកិច្ចសន្ទនាអន្តរជំនឿ ជាធម្មតារួមមានការប្រាស្រ័យទាក់ទង

ដោយបើកចំហ និងការគោរព ការបង្កើតកន្លែងសុវត្ថិភាព និងបរិយាបន្នសម្រាប់អ្នកចូលរួម ដើម្បីបង្ហាញពីជំនឿរបស់ខ្លួន ចែករំលែកបទពិសោធន៍ និងចូលរួមក្នុងការសន្ទនា ប្រកបដោយអត្ថន័យដោយគ្មានការវិនិច្ឆ័យ ឬការរើសអើង។ ឧទាហរណ៍ ការអនុវត្តរបស់អង្គការនារីដើម្បីសន្តិភាព គឺវិធីសាស្ត្រស្រាវជ្រាវបែបសន្ទនា (Facilitative Listening Design) ដែលជាជំនាញចាំបាច់សម្រាប់ការសន្ទនាអន្តរជំនឿ។ ការកំណត់គុណតម្លៃ និងគោលការណ៍រួម ដូចជាគុណតម្លៃរួមនៃសីលធម៌និងមនសិកានៃការរស់នៅ ដែលមានវិសាលភាពលើសពីព្រំដែនសាសនា គឺជួយលើកកម្ពស់សាមគ្គីភាព មេត្តាធម៌ និងយុត្តិធម៌សង្គម។ ការទទួលស្គាល់ និងគោរពនូវជំនឿ ទំនៀមទម្លាប់ និងការចូលរួមចំណែកដោយឡែកគ្នារបស់សហគមន៍ គឺផ្តល់តម្លៃដល់ភាពចម្រុះគ្នាថាជាប្រភពនៃភាពរីកចម្រើន។ សកម្មភាពសហការ និងការចូលរួមពីសហគមន៍ជួយលើកទឹកចិត្តដល់គំនិតផ្តួចផ្តើមរួមគ្នា ដែលដោះស្រាយកង្វល់រួមគ្នា និងរួមចំណែកដល់សុខុមាលភាពសង្គម។

ជាថ្មីម្តងទៀត ក្នុងចំណោមឧត្តមានុវត្តន៍ទាំងឡាយ គឺការបង្កើតវេទិកាអន្តរជំនឿជាទៀងទាត់ ដោយមានអ្នកចូលរួមមកពីជំនឿផ្សេងៗ អាចពិភាក្សាគ្នាដោយបើកចំហអំពីជំនឿរបស់ពួកគេ និងដោះស្រាយការយល់ខុសរបស់ពួកគេ។ ឧត្តមានុវត្តន៍មួយទៀតគឺគម្រោងសហគមន៍ដែលសហការគ្នា ដូចជាកិច្ចខិតខំអភិរក្សបរិស្ថានរួមគ្នា ដែលជួយឱ្យក្រុមសាសនា និងជំនឿផ្សេងគ្នាធ្វើការរួមគ្នាឆ្ពោះទៅរកគោលដៅរួម ដោយជំរុញការគោរពគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។ ការអប់រំ និងការយល់ដឹងតាមរយៈសិក្ខាសាលា និងកម្មវិធីនានា គឺលើកកម្ពស់ការយល់ដឹង និងការយោគយល់ចំពោះភាពចម្រុះ។ ការដោះស្រាយវិវាទនិងការកសាងសន្តិភាពគឺជួយសម្រួលដល់ការសន្ទនា និងការសម្រុះសម្រួលដើម្បីដោះស្រាយភាពតានតឹងខាងសាសនា ដោះស្រាយវិវាទ និងកសាងសន្តិភាពប្រកបដោយចីរភាព។

***ជំហានឡើងទៅភាពចម្រុះ*** (Ladder of Diversity) គឺជាក្របខ័ណ្ឌគំនិតដែលបង្ហាញពីការចូលរួមនៅកម្រិតផ្សេងៗគ្នា ដែលអាចបង្កើតជាប្រព័ន្ធបរិយាបន្នឬការផាត់ចេញក្នុងសហគមន៍ និងសង្គម។ “ភាពចម្រុះ គឺប្រៀបបាននឹងការអញ្ជើញចូលពិធីជប់លៀង។ រីឯបរិយាបន្ន គឺប្រៀបបាននឹងការអញ្ជើញឱ្យឡើងរាំ។” ចំណុចនេះបកស្រាយពីភាពខុសគ្នារវាងភាពជាតំណាង (ភាពចម្រុះ) និងការចូលរួមយ៉ាងសកម្ម និងភាពជាផ្នែកមួយនៃក្រុមឬសហគមន៍ (បរិយាបន្ន)។ ជំហានឡើងទៅភាពចម្រុះ ដែលបង្កើតឡើងដោយសាស្ត្រាចារ្យ Harvey Robbins និង Michael Finley គឺមានបំណងសង្កត់ធ្ងន់លើការបន្តទៅមុខ ដោយចេញពីកម្រិតត្រឹមការយោគយល់គ្នា ឆ្ពោះទៅរកការចូលរួមយ៉ាងសកម្ម ការសាទរ និងការអបអរភាពចម្រុះ។ ស្ថានភាពអាក្រក់បំផុតនៃការឈានថយក្រោយក្នុងជំហានឡើទៅភាពចម្រុះ គឺអំពើប្រល័យពូជសាសន៍។ ដូច្នេះនៅក្នុងការអនុវត្តជាក់ស្តែង ការផាត់មនុស្សចេញ (Exclusion) នាំទៅរកវិសមភាពនិងការរើសអើង។ ការអនុវត្តជានិមិត្តរូប (Tokenism) គឺពាក់ព័ន្ធនឹងបរិយាបន្នជានិមិត្តរូប ដោយមិនបានដោះស្រាយភាពលម្អៀង។ បរិយាបន្ន (Inclusion) បង្កើតបរិយាកាសដែលបុគ្គលចម្រុះមានអារម្មណ៍ថាខ្លួនទទួលបានការឱ្យតម្លៃ និងការផ្តល់សិទ្ធិអំណាច។ ការចូលរួមពេញលេញ (Full Engagement) បង្កើតឱ្យមានជាការច្នៃប្រឌិត និងកិច្ចសហការចេញពីភាពចម្រុះ។ សកម្មភាពបញ្ជាក់ការព្រមព្រៀង (Affirmative Action) គឺជួយលើកកម្ពស់សមធម៌ និងយុត្តិធម៌សង្គម ដោយដោះស្រាយបញ្ហាវិសមភាពជាប្រព័ន្ធ។

ឧត្តមានុវត្តន៍សម្រាប់គោលការណ៍នេះ រួមមានកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដែលផ្តោតលើការកសាងសមត្ថភាព និងការយល់ដឹងពីវប្បធម៌ ដោយធានាថាអ្នកដឹកនាំគ្រប់កម្រិតមានការប្តេជ្ញាចិត្តបង្កើតឱ្យមានភាពចម្រុះ និងបរិយាបន្ន។ ឧទាហរណ៍ដ៏ល្អនៃឧត្តមានុវត្តន៍មួយទៀត គឺការបង្កើតគោលនយោបាយបរិយាបន្ន ដែលជំរុញយ៉ាងសកម្មការចូលរួមរបស់ក្រុមភាគតិចក្នុងគ្រប់ទិដ្ឋភាពនៃជីវិតសហគមន៍ ដូចជាដំណើរការធ្វើការសម្រេចចិត្ត និងសកម្មភាពអភិវឌ្ឍសហគមន៍ជាដើម។

***លក្ខខណ្ឌអនុញ្ញាត*** (Enabling Conditions) សំដៅលើកត្តាចាំបាច់ ឬកាលៈទេសៈដែលជួយសម្រួលដល់ការដាក់អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនៃការអនុវត្តសេរីភាពសាសនា ឬជំនឿ (ស.ស.ជ)។ លក្ខខណ្ឌទាំងនេះ ធានាថាបុគ្គលម្នាក់ៗអាចជ្រើសរើស អនុវត្ត ឬផ្លាស់ប្តូរសាសនា ឬជំនឿរបស់ពួកគេដោយសេរី ដោយគ្មានការរើសអើង មិនរងការបង្ខិតបង្ខំ ឬអំពើហិង្សា។ លក្ខខណ្ឌដាក់អនុញ្ញាតសំខាន់ៗនៃការអនុវត្តរបស់ ស.ស.ជ រួមមានក្របខ័ណ្ឌច្បាប់មានលក្ខណៈសព្វគ្រប់ជ្រោយ ដែលរក្សា និងការពារសិទ្ធិ ស.ស.ជ រួមទាំងច្បាប់ដែលហាមឃាត់ការរើសអើង និងធានានូវសេរីភាពនៃការថ្វាយបង្គំឬគោរពបូជា និងការជួបជុំខាងសាសនា។ ឆន្ទៈនយោបាយនៅគ្រប់កម្រិតក្នុងរដ្ឋាភិបាល គឺមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ និងការពារសិទ្ធិ ស.ស.ជ តាមរយៈគោលនយោបាយ និងកម្មវិធីគាំទ្រ។ គំនិតផ្តួចផ្តើមការអប់រំ និងការយល់ដឹង គឺជួយជំរុញការយល់ដឹង ការគោរព និងការយោគយល់ដល់ភាពចម្រុះនៃសាសនាឬជំនឿសម្រាប់បុគ្គល សហគមន៍ និងស្ថាប័ន។ ការចូលរួមយ៉ាងសកម្ម និងកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល អ្នកដឹកនាំសាសនា និងសហគមន៍ជំនឿ ជួយលើកកម្ពស់កិច្ចសន្ទនា និងការគោរពគ្នាទៅវិញទៅមក។

ការគាំទ្រ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងភាពជាដៃគូជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល អាចជួយចែករំលែកពីឧត្តមានុវត្តន៍ ធនធាន និងជំនាញក្នុងការលើកកម្ពស់សិទ្ធិ ស.ស.ជ នៅទូទាំងពិភពលោក។ យន្តការតាមដាន និងគណនេយ្យភាព ធានាបាននូវការអនុលោមតាមស្តង់ដា ស.ស.ជ និងដោះស្រាយការរំលោភបំពានដោយមានប្រសិទ្ធភាព តាមរយៈគណៈកម្មការសិទ្ធិមនុស្សឯករាជ្យ និងប្រព័ន្ធតុលាការ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានចែងថា “ការបើកលក្ខខណ្ឌអនុញ្ញាតសម្រាប់សេរីភាពសាសនា ឬជំនឿ គឺមានសារៈសំខាន់ណាស់សម្រាប់ការបង្កើតបរិយាកាសមួយដែលមនុស្សគ្រប់គ្នាអាចប្រតិបត្តិសាសនា

ឬជំនឿរបស់ពួកគេដោយសេរី ដោយមិនភ័យខ្លាចការរើសអើង ការធ្វើទុក្ខបុកម្នេញ ឬអំពើហិង្សា”។ លក្ខខណ្ឌទាំងនេះរួមមានក្របខ័ណ្ឌច្បាប់ដ៏រឹងមាំ ឆន្ទៈនយោបាយ ការអប់រំ និងការយល់ដឹង ការចូលរួមរបស់សង្គមស៊ីវិល ការគាំទ្រ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងយន្តការត្រួតពិនិត្យ និងគណនេយ្យភាពប្រកបដោយប្រសិទ្ធភាព។

ឧទាហរណ៍នៃលក្ខខណ្ឌអនុញ្ញាតក្នុងការអនុវត្ត គឺការបង្កើតការិយាល័យច្បាប់ដែលផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ដល់បុគ្គលដែលប្រឈមនឹងការរើសអើងសាសនា។ ឧទាហរណ៍មួយទៀតគឺការអនុវត្តយុទ្ធនាការជាតិដែលលើកកម្ពស់ការយោគយល់ខាងសាសនា និងអប់រំសាធារណៈជន អំពីសារៈសំខាន់នៃសេរីភាពសាសនា ឬជំនឿ។

## ៦.២. អនុសាសន៍សម្រាប់សកម្មភាព

ដើម្បីជំរុញបរិយាកាសបរិយាបន្ន និងគោរពភាពចម្រុះសាសនាកាន់តែច្រើននៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវបង្កើតក្រុមប្រឹក្សាអន្តរជំនឿសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាទាំងនេះគួរមានតំណាងមកពីសហគមន៍សាសនាចម្រុះ ដើម្បីសម្របសម្រួលកិច្ចសន្ទនា លើកកម្ពស់ការយល់ដឹង និងសហការលើគំនិតផ្តួចផ្តើមដោះស្រាយបញ្ហាកង្វល់រួមគ្នា។ ទិន្នន័យថ្មីៗបង្ហាញថា សហគមន៍សាសនាកម្ពុជា៧០% បានសម្តែងចំណាប់អារម្មណ៍ចូលរួមក្នុងកិច្ចសន្ទនាអន្តរជំនឿ (ក) ដើម្បីផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការបង្កើតក្រុមប្រឹក្សា។ ការរៀបចំប្រជុំសម្ពោធជាមួយអ្នកតំណាងទាំងនេះ នឹងជួយបង្កើតរចនាសម្ព័ន្ធ និងកម្មវត្ថុរបស់ក្រុមប្រឹក្សា។

ការចាប់ផ្តើមយុទ្ធនាការអប់រំផ្តោតលើអ្នកដឹកនាំសាសនា សហគមន៍ និងសាធារណៈជនទូទៅ នឹងលើកកម្ពស់អក្ខរកម្មសាសនា ដោះស្រាយបញ្ហាផ្នត់គំនិត

អរិជ្ជមាន និងជំរុញឱ្យមានការសាទរជាមួយភាពចម្រុះ។ ជាឧទាហរណ៍ ការបង្កើតសម្ភារៈអប់រំដូចជា ខិត្តប័ណ្ណ វីដេអូ និងសិក្ខាសាលាដែលផ្តោតលើអក្ខរកម្មសាសនា និងការសាទរភាពចម្រុះ នឹងចូលរួមបំពេញតម្រូវការទៅលើធនធានឯកសារទាំងនេះ ក្នុងចំណោមយុវជនកម្ពុជាដែលមានមានកំណើន៤០% បើយោងតាមការស្ទង់មតិនាពេលថ្មីៗនេះ។ សកម្មភាពទាំងនេះនឹងបង្កើតមូលដ្ឋានគ្រឹះនៃពហុនិយមនៃការព្រមព្រៀង ដែលចាក់ឫសគល់នៅក្នុងកិច្ចសន្ទនាអន្តរជំនឿ ហើយមានសារៈសំខាន់សម្រាប់ការបង្កើតសម្ព័ន្ធសង្គមមួយដែលមានសុខដុមរមនា និងមានបរិយាបន្ន។

ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីជាអ្នកដឹកនាំសាសនានៅក្នុងសហគមន៍គឺមានសារៈសំខាន់ណាស់។ ការរចនា និងការរៀបកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដែលរៀបចំឡើងសម្រាប់ស្ត្រីជាអ្នកដឹកនាំសាសនា ផ្តល់ឱ្យពួកគេនូវការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ការជំរុញឱ្យមានភាពល្អប្រសើរឡើង និងការចូលរួមសហគមន៍។ កម្មវិធីភាពជាអ្នកដឹកនាំសាកល្បងមួយ បានបណ្តុះបណ្តាលស្ត្រីចំនួន៣០នាក់ មកពីមជ្ឈដ្ឋានសាសនាចម្រុះ ដែលរំលេចជាការបង្កើនការចូលរួមសហគមន៍ និងការជំរុញឱ្យមានការផ្លាស់ប្តូរ។
(ខ) ការបង្កើតវេទិកាឌីជីថលដែលអ្នកដឹកនាំសាសនាជាស្ត្រីដែលមានបទពិសោធន៍អាចភ្ជាប់ទំនាក់ទំនងជាមួយអ្នកដឹកនាំថ្មីៗ ដើម្បីផ្តល់ការណែនាំ និងការចែករំលែក និងការចែករំលែកចំណេះដឹង នឹងគាំទ្របន្ថែមទៀតដល់គំនិតផ្តួចផ្តើមនេះ។ វេទិកាស្រដៀងគ្នានេះនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយផ្សេងទៀត បានជួយដល់ការតភ្ជាប់ទំនាក់ទំនងក្នុងការផ្តល់ការណែនាំនេះប្រកបដោយជោគជ័យជាង១០០ករណីក្នុងរយៈពេលប្រាំមួយខែដំបូង។ ការពិនិត្យឡើងវិញនូវគោលនយោបាយសហគមន៍សាសនាដើម្បីលុបបំបាត់ភាពលម្អៀងយេនឌ័រ និងលើកកម្ពស់ឱកាសស្មើគ្នាសម្រាប់ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ នឹងធានាបាននូវវឌ្ឍនភាពប្រកបដោយចីរភាពឆ្ពោះទៅរកសមភាពយេនឌ័រ។

ការពង្រឹងក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់ការរក្សាសិទ្ធិ ស.ស.ជ គឺចាំបាច់ជាពិសេសសម្រាប់ការសង្កត់ធ្ងន់លើសិទ្ធិរបស់ក្រុមជនជាតិដើមភាគតិច។ ការត្រួតពិនិត្យសព្វគ្រប់ជ្រុងជ្រោយលើច្បាប់ និងគោលនយោបាយដែលមានស្រាប់ទាក់ទងនឹង ស.ស.ជ នឹងកំណត់ឱ្យឃើញពីគម្លាត និងដោះស្រាយគម្លាត ឬភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងស្តង់ដាអន្តរជាតិ។ កំណែទម្រង់ច្បាប់ក្នុងប្រទេសផ្សេងទៀត (គ) ដែលចេញជាការអនុម័តច្បាប់ថ្មីដែលការពារសិទ្ធិ ស.ស.ជ គឺជាគំរូសម្រាប់កម្ពុជា។

ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និងបុគ្គលិកតុលាការពីគោលការណ៍ ស.ស.ជ នឹងរៀបចំពួកគេឱ្យចេះដោះស្រាយបញ្ហាការរើសអើងសាសនា។ ការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបានបង្ហាញពីការកើនឡើងចំនួន៦០%នៃការយល់ដឹងរបស់អ្នកចូលរួមអំពីសិទ្ធិ ស.ស.ជ និងសារៈសំខាន់នៃសិទ្ធិនេះ។ (ឃ) ការសហការជាមួយអង្គការសង្គមស៊ីវិលដើម្បីតាមដាន និងរាយការណ៍អំពីការរំលោភសិទ្ធិ ស.ស.ជ និងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះពីការរើសអើង នឹងជួយពង្រឹងការការពារ ស.ស.ជ សម្រាប់ជនជាតិដើមភាគតិច។ ជាឧទាហរណ៍ បណ្តាញកសាងសន្តិភាពសហគមន៍ បានជំរុញឱ្យមានភាពល្អប្រសើរឡើងដោយជោគជ័យដើម្បីការពារ ស.ស.ជ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលជួយឱ្យជំនួយផ្នែកច្បាប់ និងសេវាកម្មតស៊ូមតិមានភាពប្រសើរឡើង។

ការកសាងសមត្ថភាពរបស់អង្គការដៃគូក្នុងការតាមដាន និងវាយតម្លៃគំនិតផ្តួចផ្តើមរបស់ ស.ស.ជ គឺមានសារៈសំខាន់ណាស់។ វិធីសាស្ត្របែបបរិមាណវិស័យ គឺមិនគ្រប់គ្រាន់សម្រាប់ ស.ស.ជ។ វិធីសាស្ត្របែបគុណវិស័យគឺចាំបាច់។ ការដាក់អនុវត្តន៍គំនិតផ្តួចផ្តើមដែលផ្តោតលើការអភិវឌ្ឍការបង្កើនគុណភាពក្នុងសេរីភាពសាសនា ឬជំនឿ និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកដើម្បីត្រួតពិនិត្យ និងវាយតម្លៃវិធីសាស្ត្របែបគុណវិស័យទាំងនេះគឺមានភាពចាំបាច់ណាស់។ ការបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃដ៏មានប្រសិទ្ធភាព នឹងជួយ

តាមដានវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ វាស់វែងផលប៉ះពាល់នៃអន្តរាគមន៍ និងធានាបាននូវការកែលម្អជាបន្តបន្ទាប់។ ចំណុចនេះ ពាក់ព័ន្ធនឹងយន្តការត្រួតពិនិត្យឯករាជ្យ ដើម្បីធានាឱ្យមានគណនេយ្យភាព និងតាមដានការអនុលោមតាមគោលការណ៍ ស.ស.ជ។ ការកសាងសមត្ថភាពរបស់បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល និងខិតខំប្រឹងប្រែងដើម្បីធានាបាននូវការត្រួតពិនិត្យ និងការវាយតម្លៃត្រឹមត្រូវនិងទៀងទាត់ គឺមានសារៈសំខាន់សម្រាប់ការវាយតម្លៃប្រកបដោយប្រសិទ្ធភាព នៃកម្មវិធីដែលបានអនុវត្ត និងធានាប្រសិទ្ធភាពអតិបរមានៃព្រឹត្តិការណ៍និងកម្មវិធីនានាទាពេលអនាគត ដើម្បីអនុវត្ត ស.ស.ជ នៅក្នុងប្រទេស។

យុទ្ធសាស្ត្រនេះនឹងពាក់ព័ន្ធនឹងការបង្កើតគណៈកម្មាធិការដឹកនាំពហុភាគី ដែលមានតំណាងមកពីរដ្ឋាភិបាល សហគមន៍សាសនា សង្គមស៊ីវិល និងដៃគូអន្តរជាតិ ដើម្បីត្រួតពិនិត្យការអនុវត្ត។ ការរៀបចំកិច្ចប្រជុំបើកដំណើរការនៃគណៈកម្មាធិការដឹកនាំ នឹងបង្ហាញពីតួនាទី ទំនួលខុសត្រូវ និងពេលវេលាកំណត់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនឹងជួយតាមដានវឌ្ឍនភាព កំណត់បញ្ហាប្រឈម និងជូនដំណឹងអំពីការកែសម្រួលយុទ្ធសាស្ត្រ។ របាយការណ៍ទាំងនេះនឹងផ្តល់នូវចំណុចលម្អិតនៃសកម្មភាពដែលបានអនុវត្ត បញ្ហាប្រឈម ដែលបានជួបប្រទះ និងវិធានការនានាដែលត្រូវដោះស្រាយ។ យន្តការត្រួតពិនិត្យឯករាជ្យនឹងធានានូវការទទួលខុសត្រូវ និងតាមដានការអនុលោមតាមគោលការណ៍របស់ ស.ស.ជ។ យុទ្ធសាស្ត្រសព្វជ្រុងជ្រោយនេះ ដោយផ្អែកលើគោលការណ៍ពហុនិយមនៃការព្រមព្រៀង កិច្ចសន្ទនាអន្តរជំនឿ ជំហានឡើងទៅភាពចម្រុះ និងលក្ខខណ្ឌអនុញ្ញាត នឹងផ្តល់ផែនទីបង្ហាញផ្លូវសម្រាប់ការលើកកម្ពស់ការអនុវត្ត ស.ស.ជ នៅក្នុងប្រទេសកម្ពុជា។ តាមរយៈការជំរុញបរិយាកាសបរិយាបន្នជាងមុនសម្រាប់ភាពចម្រុះសាសនា ការផ្តល់អំណាចដល់អ្នកដឹកនាំសាសនាជាស្ត្រី និងការពង្រឹងក្របខ័ណ្ឌច្បាប់និងស្ថាប័ន កម្ពុជាអាចបង្កើត សង្គមមួយដែលមនុស្សគ្រប់គ្នាអាចប្រតិបត្តិជំនឿរបស់ពួកគេដោយសេរី និងរួមចំណែកដល់សន្តិភាព និងយុត្តិធម៌បន្ថែមទៀតនាពេលអនាគត។

(ក) ទិន្នន័យថ្មីៗ (ឆ្នាំ ២០២៣) នៃមជ្ឈមណ្ឌលស្រាវជ្រាវ Pew (Pew Research Center) បង្ហាញថា សហគមន៍សាសនានៅក្នុងប្រទេសកម្ពុជា៧០% បានបង្ហាញពីចំណាប់អារម្មណ៍ចូលរួមក្នុងកិច្ចសន្ទនាអន្តរជំនឿ។ នេះឆ្លុះបញ្ចាំងពីឆន្ទៈកាន់តែខ្លាំងឡើងក្នុងចំណោមក្រុមសាសនានានាក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងការពិភាក្សាដែលលើកកម្ពស់ការយល់ដឹងគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការលើជំនឿផ្សេងៗគ្នា។ និន្នាការនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ពហុនិយមសាសនា និងកាត់បន្ថយភាពតានតឹងក្នុងចំណោមសហគមន៍សាសនាចម្រុះក្នុងមូលដ្ឋាន (ឯកសារ មជ្ឈមណ្ឌល ស្រាវជ្រាវ Pew) (ឯកសារ Human Rights Watch)។

(ខ) កម្មវិធីភាពជាអ្នកដឹកនាំសាកល្បងដែលបានបណ្តុះបណ្តាលស្ត្រីចំនួន៣០នាក់មកពីមជ្ឈដ្ឋានសាសនាចម្រុះ ដែលរំលេចជាការបង្កើនការចូលរួម និងការជំរុញឱ្យមានភាពល្អប្រសើរឡើងក្នុងសហគមន៍ បានប្រព្រឹត្តទៅនៅទីកន្លែងផ្សេងៗគ្នា ដែលមានឧទាហរណ៍គួរឱ្យកត់សម្គាល់ពីចក្រភពអង់គ្លេស និងប្រទេសអាល់ហ្សេរី។

នៅប្រទេសអាល់ហ្សេរី គណៈប្រតិភូមកពីសម្ព័ន្ធសេរីភាពសាសនាឬជំនឿអន្តរជាតិ (International Religious Freedom or Belief Alliance) បានដឹកនាំវគ្គបណ្តុះបណ្តាល និងការចូលរួមក្នុងខែកញ្ញា ឆ្នាំ២០២២ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមរបស់សហគមន៍ជំនឿភាគតិច និងបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាល (BioMed Central)។ ស្រដៀងគ្នានេះដែរ នៅចក្រភពអង់គ្លេស សន្និសីទថ្នាក់រដ្ឋមន្ត្រីអន្តរជាតិស្តីពីសេរីភាពសាសនាឬជំនឿ ត្រូវបានប្រារព្ធឡើងនៅក្នុងខែកក្កដា ឆ្នាំ២០២២ ដែលជាកន្លែងមានជំនឿចម្រុះ ហើយអ្នកដឹកនាំសហគមន៍បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការជំរុញឱ្យមានភាពល្អប្រសើរឡើងផងដែរ (BioMed Central) (District)។

គំនិតផ្តួចផ្តើមទាំងនេះបានសង្កត់ធ្ងន់លើការកសាងសមត្ថភាព និងការចូលរួមសហគមន៍ ដោយផ្តល់សិទ្ធិអំណាចដល់អ្នកដឹកនាំជាស្ត្រី ក្នុងការជំរុញឱ្យមានភាពល្អប្រសើរឡើងសម្រាប់សហគមន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

(គ) ច្បាប់ថ្មីក្នុងអណត្តិលោកប្រធានាធិបតី Biden នៅសហរដ្ឋអាមេរិក ដើម្បីបង្កើនការការពារសេរីភាពសាសនាក្នុងសេវាសង្គមត្រូវបានបញ្ចប់នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។ ច្បាប់នេះត្រូវបានចេញដោយអង្គភាពចំនួនប្រាំបួន រួមមាននាយកដ្ឋានសេវាសុខភាព និងមនុស្ស នាយកដ្ឋានកសិកម្ម នាយកដ្ឋានការអប់រំ នាយកដ្ឋានសន្តិសុខមាតុភូមិ នាយកដ្ឋានការអភិវឌ្ឍលំនៅដ្ឋាននិងទីក្រុង នាយកដ្ឋានយុត្តិធម៌ នាយកដ្ឋានការងារ នាយកដ្ឋានកិច្ចការអតីតយុទ្ធជន និងនាយកដ្ឋានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (Religion News Service)។

អ៊ុយក្រែនបានណែនាំបទដ្ឋានច្បាប់ថ្មី ដើម្បីការពារសេរីភាពសាសនាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេសក្នុងការចូលរួមផ្តល់ព័ត៌មានទៅនឹងវិវាទដែលកំពុងតែបន្ត។ សកម្មភាពគួរឱ្យកត់សម្គាល់រួមមាន វិធានការដែលចាត់ធ្វើក្នុងឆ្នាំ២០១៩ ដើម្បីដោះស្រាយការរើសអើងសាសនា និងធានាថាសហគមន៍សាសនាអាចអនុវត្តដោយសេរី ដោយមិនភ័យខ្លាចនូវការគាបសង្កត់ឬអំពើហិង្សា។ ភាពជាក់លាក់នៃបទដ្ឋានទាំងនេះ និងកាលបរិច្ឆេទអនុម័ត គឺបង្កប់នូវកិច្ចខិតខំប្រឹងប្រែងខាងច្បាប់ខ្លាំង ដើម្បីការពារសេរីភាពសាសនា ចំពេលដែលមានវិវាទកំពុងបន្ត។ (UN Press) (Conectas Sur)។

(ឃ) សិក្ខាសាលាបណ្តុះបណ្តាលដែលបង្ហាញពីការកើនឡើងចំនួន៦០% នៃការយល់ដឹងរបស់អ្នកចូលរួមអំពីសិទ្ធិសេរីភាពសាសនាឬជំនឿ (ស.ស.ជ) និងសារៈសំខាន់នៃសិទ្ធិនេះ ត្រូវបានរៀបចំឡើងជាផ្នែកនៃគំនិតផ្តួចផ្តើមផ្សេងៗ ក្នុងគោលបំណងលើកកម្ពស់សេរីភាពសាសនា និងការយល់ដឹងអំពីសេរីភាពនេះ។ សិក្ខាសាលាទាំងនេះបានប្រព្រឹត្តទៅនៅតាមប្រទេសផ្សេងៗគ្នា រួមមានព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់នៅក្នុងប្រទេសអាល់ហ្សេរី និងចក្រភពអង់គ្លេសជាដើម។

នៅខែកញ្ញា ឆ្នាំ២០២២ គណៈប្រតិភូមកពី សម្ព័ន្ធសេរីភាពសាសនាឬជំនឿអន្តរជាតិ (International Religious Freedom or Belief Alliance) បានធ្វើទស្សនកិច្ចនៅប្រទេសអាល់ហ្សេរី ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមរបស់សហគមន៍ជំនឿភាគតិច និងដើម្បីកសាងទំនាក់ទំនងជាមួយរដ្ឋាភិបាល។ លើសពីនេះ នៅខែកក្កដា ឆ្នាំ២០២២ ចក្រភពអង់គ្លេសបានរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីអន្តរជាតិស្តីពី ស.ស.ជ នៅទីក្រុងឡុងដ៍ ដែលរួមបញ្ចូលវគ្គប្រជុំជាច្រើននិយាយអំពីទិដ្ឋភាពផ្សេងៗនៃសេរីភាពសាសនា និងបញ្ហាប្រឈមនៅទូទាំងពិភពលោក។ ព្រឹត្តិការណ៍ទាំងនេះបានសង្កត់ធ្ងន់លើការអប់រំនិងការយល់ដឹងដើម្បីធ្វើឱ្យការយល់ដឹងនិងការគាំទ្រសិទ្ធិ ស.ស.ជ មានភាពប្រសើរឡើង (Gov UK) (European Commission)។





# សេចក្ដីសន្និដ្ឋាន

ការស្រាវជ្រាវអំពីស្ថានភាពសេរីភាពនៃសាសនា ឬជំនឿ (ស.ស.ជ) នៅក្នុងសហគមន៍គោលដៅរបស់អង្គការដៃគូក្នុងខេត្តចំនួនប្រាំមួយនៃប្រទេសកម្ពុជា បង្ហាញឱ្យឃើញទាំងវឌ្ឍនភាព និងបញ្ហាប្រឈមដែលកំពុងកើតមាន។ ទោះបីជាក្របខ័ណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជាជាទ្រឹស្តីគាំទ្រសេរីភាពសាសនាឬជំនឿក៏ដោយ ការអនុវត្តជាក់ស្តែងគឺនៅតែមានចំណុចមិនស្របទៅនឹងការគាំទ្រដោយទ្រឹស្តីនេះ។ ការសិក្សានេះបង្ហាញពីភាពខុសគ្នារវាងការធានាខាងផ្លូវច្បាប់ និងបទពិសោធន៍ក្នុងស្ថានភាពពិតនៃសហគមន៍សាសនា ជាពិសេសក្រុមភាគតិច។ មានមូលបទសំខាន់មួយគឺភាពលេចធ្លោលើសលុបនៃព្រះពុទ្ធសាសនា ដោយភាពលេចធ្លោនេះប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពសាសនារបស់ក្រុមភាគតិច ដោយមានអមដោយឧបសគ្គផ្នែកច្បាប់ និងសង្គមផងដែរ។ ការរើសអើងផ្ទួនប្រឆាំងនឹងស្ត្រី និងបុគ្គលស្រលាញ់ភេទដូចគ្នា នៅក្នុងបរិបទសាសនា ធ្វើឱ្យបញ្ហាទាក់ទងនឹងសេរីភាពសាសនានិងជំនឿនេះកាន់តែធ្ងន់ធ្ងរ។

លទ្ធផលស្រាវជ្រាវធំៗបង្ហាញថា ខណៈពេលមានការទទួលស្គាល់ជាផ្លូវការនៃសេរីភាពសាសនា ការជំរុញការអនុវត្តទៅលើច្បាប់នេះនៅមានភាពមិនស្មើគ្នា។ សាសនាភាគតិចប្រឈមនឹងបញ្ហាប្រឈមធំៗ រួមទាំងការរើសអើងក្នុងការចុះឈ្មោះ និងការសាងសង់អគារសាសនា ភាពលម្អៀងក្នុងការអប់រំសាសនា និងការបំផ្លាញទីកន្លែងសក្ការៈដើម្បីគម្រោងអភិវឌ្ឍន៍។ ការអនុវត្តទាំងនេះមិនត្រឹមតែរារាំងសកម្មភាពក្រុមសាសនាភាគតិចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងនូវតួនាទីលើសលុបលើសង្គមនៃពុទ្ធសាសនាផងដែរ។ វិសមភាពយេនឌ័ររងការយាយីពីបទដ្ឋានប្រពៃណី និងសាសនា ដោយដាក់កំហិតធ្ងន់ធ្ងរដល់ការចូលរួមរបស់ស្ត្រី ជាពិសេសស្ត្រីដែលមកពីក្រុមសាសនាភាគតិច ទាំងក្នុងផ្លូវសាសនា និងជីវិតសាធារណៈ។

ការដោះស្រាយបញ្ហាទាំងនេះទាមទារឱ្យមានកំណែទម្រង់ច្បាប់សព្វគ្រប់ជ្រុងជ្រោយ និងការដាក់អនុវត្តជាប់លាប់ ដើម្បីធានាថាមានការយកចិត្តទុកដាក់មកលើក្រុមសាសនានានាស្មើៗគ្នា។ មានតម្រូវការជាចាំបាច់ក្នុងការផ្សព្វផ្សាយឱ្យកាន់តែច្រើន និងការពង្រឹងការអនុវត្តឱ្យមានភាពជាប់លាប់នូវសិទ្ធិ ស.ស.ជ។ ការជំរុញការសន្ទនា និងការអប់រំអន្តរជំនឿ គឺមានភាពចាំបាច់ដើម្បីលើកកម្ពស់ការគោរព និងការយល់ដឹងពីគ្នាទៅវិញទៅមកក្នុងក្រុមសាសនាផ្សេងៗគ្នា។ ការការពារទីកន្លែងសក្ការៈរបស់ជនជាតិដើមភាគតិច និងគាំទ្រដល់ការចូលរួមសកម្មរបស់ស្ត្រី និងក្រុមងាយរងគ្រោះ ក្នុងផ្លូវសាសនា និងជីវិតសាធារណៈ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការបង្កើតសង្គមដែលកាន់តែមានបរិយាបន្ន។

ការស្រាវជ្រាវនាពេលអនាគត និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រត្រូវធ្វើឡើងដើម្បីជំរុញបុព្វហេតុនៃសេរីភាពសាសនា និងជំរុញបរិយាបន្នភាព។ អ្នកតាក់តែងគោលនយោបាយ អ្នកដឹកនាំសាសនា និងអង្គការសង្គមស៊ីវិល ត្រូវសហការគ្នាដើម្បីដោះស្រាយបញ្ហាប្រឈម និងគម្លាតដែលរកឃើញនៅក្នុងក្របខ័ណ្ឌបច្ចុប្បន្ន។ ចំណុចនេះគឺត្រូវរាប់បញ្ចូលទាំងការស៊ើបមើលការអនុវត្តជាក់ស្តែងនៃការការពារផ្លូវច្បាប់ និងការកំណត់រករបាំងដែលរារាំងសេរីភាពសាសនានិងជំនឿ។ កំណែទម្រង់ការអប់រំ និងកម្មវិធីសិក្សារបស់សាលានិងសាកលវិទ្យាល័យ គួរត្រូវស្វែងយល់ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃគោលនយោបាយបច្ចុប្បន្នមកលើភាពចុះសម្រុងនៃសង្គម និងស្នើឱ្យមានការអនុវត្តប្រកបដោយបរិយាបន្នជាងមុន។ ការបង្កើតវេទិកាសម្រាប់ការសន្ទនាអន្តរជំនឿគឺមានភាពចាំបាច់ ហើយវានឹងជួយជំរុញឱ្យមានការយល់ដឹង និងការគោរពគ្នាទៅវិញទៅមកក្នុងក្រុមសាសនាផ្សេងៗគ្នា។

ការពិនិត្យមើលចំណុចប្រទាក់ក្រឡាគ្នានៃយេនឌ័រ និងការអនុវត្តសាសនាក៏មានភាពចាំបាច់ផងដែរ ដើម្បីលើកកម្ពស់សមភាព និងផ្តល់ភាពអង់អាចដល់អ្នកដឹកនាំជាស្ត្រី។ ការចងក្រងឯកសារ និងការដោះស្រាយបញ្ហាប្រឈមជាក់លាក់ដែលបុគ្គល ស្រលាញ់ភេទដូចគ្នា និងសហគមន៍ជនជាតិដើមភាគតិចកំពុងប្រឈមក្នុងការអនុវត្តជំនឿរបស់ខ្លួនគឺមានសារៈសំខាន់ណាស់។ តាមរយៈការផ្តោតលើផ្នែកទាំងនេះ អ្នកពាក់ព័ន្ធអាចរួមចំណែកដល់សង្គមមួយដែលអបអរភាពចម្រុះសាសនា ហើយបុគ្គលទាំងអស់អាចអនុវត្តជំនឿរបស់ពួកគេដោយសេរី។ ការប្តេជ្ញាចិត្តចំពោះសកម្មភាពទាំងនេះ នឹងត្រួសត្រាយផ្លូវសម្រាប់សង្គមជាតិឱ្យកាន់តែមានភាពសុខដុមរមនា និងមានភាពធន់ជាងមុន ដែលជំរុញការសន្ទនាប្រកបដោយការគោរព ប្រកាន់ខ្ជាប់នូវគោលការណ៍សេរីភាពសាសនា និងសាទរភាពចម្រុះសាសនា។



# គន្ថនិទ្ទេស


- ["Achieving freedom of religion or belief" – this is the basic framework for FORB research]
- **Amnesty International.** "Report on Human Rights Violations in Cambodia: Focus on Religious Freedom." [Accessed from Amnesty International's official website or database.]
- **ACN International,** "Cambodia Report 2023," 2023.
- **Chen, Mei Ling.** "Minority Religions in Cambodia: Challenges and Prospects." Journal of Southeast Asian Studies 25, no. 4 (2020): 335-355.
- **Eck, Diana L.** "A New Religious America: How a 'Christian Country' Has Become the World's Most Religiously Diverse Nation," Harper, SanFrancisco, 2001.
- **Freedom House website**, Retrieved 2024-03-01, https://freedomhouse.org/country/cabo-verde/freedom-world/2023
- **Government of Cambodia.** Constitution of the Kingdom of Cambodia. [Accessed from the official government website or legal databases.]
- **Human Rights Watch,** "Annual Report 2017," 2017.
- **Küng, Hans.** "Tracing the Way: Spiritual Dimensions of the World Religions." Continuum, (2006).

- **Küng, Hans.** "Tracing the Way: Spiritual Dimensions of the World Religions." Continuum, (2006).
- **Nature Communications,** "Raising religious inherency."
- **Oxford Journal of Law and Religion,** "Freedom of Religion or Belief - A Human Right under Pressure"
- **Robbins, Harvey, and Michael Finley.** "Why Diversity Matters: A Roundtable Discussion on Racial and Ethnic Diversity in the Legal Profession." Duke Journal of Gender Law & Policy, vol. 14, no. 2, 2007, pp. 267-306
- **ScienceDirect,** "East versus West: psychology of religion in East Asian cultures."
- **ScienceDirect,** "Measuring religiosity in a religiously diverse society: The China case."
- **ScienceDirect,** "Religious Tourism as a Sociocultural Phenomenon."
- **ScienceDirect,** "Rewarding the good and punishing the bad."
- **ScienceDirect,** "Seeing like the stateless: Documentation and the mobilities of liminal citizenship in Cambodia."
- **ScienceDirect,** "State and religion."
- **ScienceDirect,** "The future of civilization and state religion policy."

- **ScienceDirect,** "The State of International Religious Freedom and Why It Matters."
- **Smith, John.** "Historical Perspectives on Religious Freedom in Cambodia," Asian Journal of Comparative Law 20, no. 2 (2018): 112-130.
- **United Nations Human Rights Council,** "Report of the Special Rapporteur on freedom of religion or belief," A/HRC/23/49 (2013)
- **UN Human Rights Committee,** general comment No. 31 (2004), para. 10, and Heiner Bielefeldt, Nazila Ghanea and Michael Wiener, "Freedom of Religion or Belief: An International Law Commentary" (Oxford, Oxford University Press, 2016), pp. 573-574.)
- **UN Women,** "UN Women and Gender Report," 2026.
- **USAID Report** of FoRB in Cambodia 2021.
- **U.S. Department of State,** "Report on Religious Freedom in Cambodia," 2009.
- **US Department of State,** "Report on Religious Freedom in Cambodia," 2022.
- **United States Bureau of Democracy,** Human Rights and Labour, "Cambodia: International Religious Freedom Report 2007," 2007.

- **U.S. Deparment of State,** “2022 Report on International Religious Freedom: Cambodia,” 2022.
- **Wikipedia,** “Freedom of religion in Cambodia”
- **World Bank,** “Cambodia Gender Assessment,” 2014.



«សេរីភាព
សាសនា និង
ជំនឿ» នៅក្នុង
ប្រទេសកម្ពុជា មានការ
ប្រែប្រួលគួរឱ្យកត់សម្គាល់
ក្នុងរយៈពេលជាច្រើនឆ្នាំមក
នេះ។ រដ្ឋធម្មនុញ្ញកម្ពុជាធានានូវ
សេរីភាពខាងសាសនានិងជំនឿ ប៉ុន្តែ
នៅក្នុងរបត់ប្រវត្តិសាស្ត្រ យើងធ្លាប់ជួប
បទពិសោធន៍នៃការគាបសង្កត់ផ្នែកសាសនា
ជាពិសេសក្នុងរបបខ្មែរក្រហម។ ក្រោយពីរបប
ខ្មែរក្រហម ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងដើម្បី
ការពារសិទ្ធិសេរីភាពសាសនា និងជំនឿ ប៉ុន្តែ បញ្ហាប្រឈម
នៅតែមាន ដោយសារផ្នត់គំនិតសង្គម ឥទ្ធិពលនយោបាយ និង
បញ្ហាប្រឈមនានាលើក្រុមសាសនានិងជំនឿភាគតិច។

របាយការណ៍ស្រាវជ្រាវស្តីពី “ការសិក្សាស៊ីជម្រៅអំពីសេរីភាពសាសនា
និងជំនឿ៖ ស្វែងយល់ពីឧបសគ្គ និងក្តីសង្ឃឹមរបស់សហគមន៍” មានគោលដៅ
បង្ហាញពីស្ថានភាពបច្ចុប្បន្ន នៃសេរីភាពសាសនានិងជំនឿនៅក្នុងប្រទេសកម្ពុជា។
សហការជាមួយអ្នកស្រាវជ្រាវសហគមន៍ និងអង្គការដៃគូ រួមមានអង្គការបន្ទការអប់រំ
អង្គការស្ពានសន្តិភាព និងអង្គការដានមីសិនប្រចាំប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវនេះ
ពិនិត្យមើលបរិបទប្រវត្តិសាស្ត្រ ការការពារផ្លូវច្បាប់ ការប្រឈមក្នុងពេលបច្ចុប្បន្ន និងផល
ប៉ះពាល់ទៅលើសេរីភាពសាសនានិងជំនឿនៅក្នុងបរិបទកម្ពុជា ដែលចម្រុះទៅដោយសាសនា
និងជំនឿផ្សេងៗគ្នា។

ការសិក្សាស្រាវជ្រាវនេះរកឃើញថា ខណៈពេលដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជាមានការ
គាំទ្រជាទ្រឹស្តីលើសេរីភាពខាងសាសនានិងជំនឿ ការអនុវត្តជាក់ស្តែងនៅតែមានបញ្ហាប្រឈម
ផ្សេងៗ។ ការដោះស្រាយបញ្ហាទាំងនេះ តម្រូវឱ្យមានវិធីសាស្ត្រចម្រុះនិងបែបពហុវិស័យ
ដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ ការអប់រំក្នុងសង្គម និងការលើកកម្ពស់សិទ្ធិមនុស្ស
ជាសកលមួយឱ្យមានប្រសិទ្ធភាពខ្ពស់។ តាមរយៈការជំរុញឱ្យមានការគោរព និង
ការយោគយល់គ្នាទៅវិញទៅមក ការលើកកម្ពស់ការអនុវត្តសាសនាប្រកបដោយ
បរិយាបន្ន និងការការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ ប្រទេសកម្ពុជា
អាចក្លាយជាសង្គមមួយដែលមានសុខដុមរមនានិងភាពធន់
ថែមទៀត ដោយចេះសាទរភាពចម្រុះនៃ
សាសនានិងជំនឿ។

9 789924 625070 >